សាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច

Universite Royale de Droit et Sciences Economiques

Royal University of Law and Economics

# សារណាបញ្ចប់ការសិក្សា

# បទល្មើសព្រហ្មទណ្ឌ

ស្រាវជ្រាវចាប់ពីថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២២ ដល់ថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០២២


តាក់តែងឡើងដោយ

និស្សិតឈ្មោះ ៖ **អ្នកស្រី សយ ម៉ានិច្ច**

**កញ្ញា អ៊ុង សុខវត្តី**

សាស្ត្រាចារ្យណែនាំ

**លោកស្រី ទី សុឃីតា**


ថ្នាក់បរិញ្ញាបត្រ នីតិសាស្រ្ត

ជំនាន់ទី២២

ឆ្នាំចូលសិក្សា ២០១៨

ឆ្នាំសរសេរសារណា ២០២២

# សេចក្តីថ្លែងអំណរគុណ

ក្រុមនាងខ្ញុំឈ្មោះ **សយ ម៉ានិច្ច** និង **អ៊ុង សុខវត្តី** ជានិស្សិតបរិញ្ញាបត្រ ផ្នែកនីតិសាស្រ្ត ឆ្នាំទី៤ ជំនាន់ទី២២ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ចក្នុងឆ្នាំសិក្សា ២០១៨ ២០២២។

**សូមគោរពលំអោនកាយវាចាចិត្ត សម្តែងនូវមហាកតញ្ញូតាធម៌ដឹងគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះ៖**

**លោកឪពុក សយ សុជាតិ** **លោកឪពុក អ៊ុង ចំរើន**

**អ្នកម្តាយ ឈូ គឹមហួយ** **អ្នកម្តាយ ឆាយ ចន្ធូ**

អ្នកមានគុណទាំងពីរដែលបានផ្តល់កំណើត តាំងពីពេលកូននៅកុមារភាពរហូតដល់កូនធំពេញវ័យ និងខិតខំចិញ្ចឹមបីបាច់ថែរក្សាទូន្មានប្រៀនប្រដៅ និងផ្តល់ដំបូន្មានល្អៗជួយជំរុញលើកទឹកចិត្តឲ្យកូនស្រឡាញ់ពេញចិត្តចំពោះការសិក្សារហូតមក តាំងពីថ្នាក់បឋមសិក្សារហូតឈានដល់ថ្នាក់បរិញ្ញាបត្រនេះ ។ និងបានទទួលបានការបណ្តុះ

បណ្តាល ទាំងផ្នែកពុទ្ធចក្រ និងអាណាចក្រ ជាពិសេស មុខវិជ្ជាដែលសង្គមត្រូវការនាបច្ចុប្បន្ននេះ ហើយលោកទាំងពីរបានព្យាយាមទាំងកម្លាំងកាយ ទាំងកម្លាំងចិត្ត និងជួយទំនុកបម្រុងគ្រប់បែបយ៉ាងទាំងបញ្ញា និងស្មារតីដើម្បីអោយកូនមានអនាគតភ្លឺស្វាង និងអភិវឌ្ឍខ្លួនក្លាយជាកូនល្អ ពលរដ្ឋល្អ នៅក្នុងសង្គមជាតិយើង។

ចំពោះ **សាស្ត្រាចារ្យ ទី សុឃីតា** ដែលបានខិតខំចំណាយពេលវេលាដ៏មានតម្លៃផ្តល់នូវគំនិត និងយោបល់ល្អៗ ក្នុងការកែសម្រួល នូវកំហុសខុសឆ្គងចំពោះការសេរសេរសារណារបស់ក្រុមយើងខ្ញុំកន្លងមក រហូតសម្រេចបាននូវស្នាដៃសារណាមួយនេះឡើង។

ជាចុងក្រោយក្រុមយើងខ្ញុំទាំងពីរនាក់ សូមថ្លែងអំណរគុណ និងសូមប្រសិទ្ធពរជ័យដល់វត្ថុសក្តិសិទ្ធិក្នុងលោកតាមជួយថែរក្សាដល់លោកទាំងអស់ដែលបានរៀបរាប់ខាងលើ សូមអោយជួបតែពុទ្ធិពរទាំង៤ប្រការគឺ អាយុ វណ្ណ សុខៈ ពលៈ និងកុំបីឃ្លៀងឃ្លាតឡើយ។

**អារម្ភកថា**

ក្នុងនាមខ្ញុំទាំងពីរនាក់ សិក្សាថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រអស់រយៈពេល៤ឆ្នាំ នៅសកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច បានផ្តល់ចំណេះដឹង បទពិសោធន៍ និងការអប់រំផ្នែកច្បាប់ ព្រមទាំងការទូន្មានល្អៗពីសាស្ត្រាចារ្យល្អៗ ដែលធ្វើឲ្យនាងខ្ញុំទាំងពីររូប មានឱកាស សរសេរសារណាអំពី**ប្រធានបទ បទល្មើសព្រហ្មទណ្ឌ** នេះឡើង ដូច្នេះហើយបានជាយើងខ្ញុំទាំងពីរបានសម្រេចជ្រើសរើសប្រធានបទនេះដោយសារប្រធានបទមួយនេះមានអត្ថន័យគ្រប់គ្រាន់ ដើម្បីឲ្យអ្នកសិក្សាផ្នែកនីតិសាស្ត្រទាំងអស់នៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច ងាយយល់ចំពោះប្រធានបទមួយនេះ។

យើងខ្ញុំទាំងពីរនាក់ សង្ឃឹមយ៉ាងមុតមាំថា សៀវភៅនេះបង្កើតឡើង ក្នុងគោលបំណងផ្សព្វផ្សាយវិស័យច្បាប់ ឲ្យកាន់តែទូលំទូលាយទៅកាន់សាធារណជន និងប្អូនៗដែលសិក្សាឆ្នាំបន្តបន្ទាប់ ដើម្បីជាពុទ្ធិខ្លះក្នុងការស្វែងយល់បន្ថែម លើសពីនេះទៅទៀត ពិតជាមានសេចក្តីសោមនស្សរីករាយណាស់ដែលបានសរសេរ និងរៀបរៀងសារណាបញ្ចប់ការសិក្សាក្រោមប្រធានបទ **បទល្មើសព្រហ្មទណ្ឌ** ក្រោមការណែនាំដោយ**សាស្ត្រាចារ្យ ទី សុឃីតា** ដែលអ្នកគ្រូបានចំណាយពេលវេលាដ៏មានតម្លៃក្នុងការចែករំលែកនូវចំណេះដឹង នឹងបទពិសោធន៍ និងដំបូងមានល្អៗសម្រាប់ពុទ្ធិដល់យើងខ្ញុំទាំងពីរ ។ ហើយយើងខ្ញុំទាំងពីរ ក៏សង្ឃឹមថាមិត្តនិស្សិត នឹងមិត្តអ្នកអានទាំងអស់ចូលរួមវាយតម្លៃ និងរិះគន់ក្នុងន័យស្ថាបនាឲ្យបានទាំងអស់គ្នា។

ជាចុងក្រោយ សង្ឃឹមថាការខិតខំប្រឹងប្រែងក្នុងការស្រាវជ្រាវប្រធានបទមួយនេះ នឹងជួយផ្តល់ជាប្រយោជន៍ដល់ប្អូនៗនិស្សិតជំនាន់ក្រោយយកមកសិក្សាស្រាវជ្រាវបន្ថែមទៀតដែលទាក់ទងទៅនឹងច្បាប់។

# មាតិកា

ទំព័រ

**សេចក្តីផ្តើម** ........................................ **១**

**ជំពូកទី១៖ សញ្ញាណទូទៅនៃបទល្មើសព្រហ្មទណ្ឌ**

១.១ និយមន័យ ........................................ ២

១.២ ភាពខុសប្លែកគ្នារវាងបទល្មើសព្រហ្មទណ្ឌ និងអំពើល្មើសផ្សេងៗទៀត ........................................ ២

១.២.១ ភាពខុសប្លែកគ្នារវាងបទល្មើសព្រហ្មទណ្ឌ និងអំពើល្មើសផ្នែករដ្ឋប្បវេណី ........................................ ២

១.២.២ ការបែងចែករវាងបទល្មើសព្រហ្មទណ្ឌ និងអំពើល្មើសផ្នែកវិន័យ ........................................ ៣

១.២ ធាតុផ្សំនៃបទល្មើសព្រហ្មទណ្ឌ ........................................ ៤

១.២.១ ធាតុផ្សំនីត្យានុកូលនៃបទល្មើស ........................................ ៥

ក. គោលការណ៍នីត្យានុកូលភាពនៃបទល្មើស នឹងទោស ........................................ ៥

ក.១ នីត្យានុកូលភាពនៃបទល្មើស ........................................ ៦

ក.២ នីត្យានុកូលភាពនៃទោស ........................................ ៦

ខ. ផលវិបាកនៃគោលការណ៍នីត្យានុកូលភាព ........................................ ៦

គ. វិសាលភាពនៃច្បាប់ព្រហ្មទណ្ឌទូទៅ ........................................ ៧

គ.១ ការអនុវត្តច្បាប់ព្រហ្មទណ្ឌនៅក្នុងពេលវេលា ........................................ ៧

គ.២ ការអនុវត្តច្បាប់ព្រហ្មទណ្ឌក្នុងលំហ ........................................ ៩

គ.៣ ការអនុវត្តច្បាប់កម្ពុជាដោយសារការប៉ះពាល់ផលប្រយោជន៍កម្ពុជា ........................................ ១២

១.៣.២ ធាតុផ្សំសត្យានុម័ត ឬ ធាតុសម្ភារៈ ........................................ ១២

ក. ធាតុផ្សំសម្ភារៈក្នុងបទល្មើសបានសម្រេច ........................................ ១៣

ក.១ដំណាក់កាលប្រព្រឹត្តបទល្មើស ........................................ ១៣

ក.២ការប្រព្រឹត្តបទល្មើស ( សកម្មភាព) ........................................ ១៤

ខ. ធាតុផ្សំសម្ភារៈក្នុងបទល្មើសមិនបានសម្រេច ........................................ ១៥

ខ.១ លក្ខខណ្ឌនៃអំពើប៉ុនប៉ងមានទោស ........................................ ១៥

ខ.២ ការផ្តន្ទាទោសចំពោះការប៉ុនប៉ងប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ ........................................ ១៧

១.៣.៣ ធាតុផ្សំអត្តនោម័ត ........................................ ១៧

ក. កំហុសចេតនា នឹង កំហុសអចេតនា ........ ១៨
ក.១ កំហុសចេតនា ........ ១៨
ក.២ កំហុសអចេតនា ........ ១៨
ខ. ការវាយតម្លៃកំហុសចេតនា នឹង កំហុសអចេតនា ........ ១៩

## ជំពូកទី២៖ ចំណាត់ថ្នាក់នៃបទល្មើសព្រហ្មទណ្ឌ

២.១ ការបែងចែករវាងបទលហុ បទមជ្ឈិម និងបទឧក្រិដ្ឋ ........ ២០
២.១.១ លក្ខណៈវិនិច្ឆ័យនៃការបែងចែក ........ ២០
ក. បទឧក្រិដ្ឋ ........ ២០
ខ. បទមជ្ឈិម ........ ២០
គ. បទលហុ ........ ២១
២.១.២ ផលប្រយោជន៍នៃការបែងចែក ........ ២១
ក.ផលប្រយោជន៍ទាក់ទងនឹងអាជ្ញាយុកាល ........ ២១
ខ.ផលប្រយោជន៍ទាក់ទងនឹងការអនុវត្តនីតិវិធី ........ ២២
គ.ផលប្រយោជន៍ទាក់ទងនឹងការកំណត់ប៉ុនប៉ង ........ ២២
ឃ.ផលប្រយជន៍ទាក់ទងននឹងការកំណត់ការផ្តើមគំនិតនិងការសមគំនិត ........ ២២
២.២ ចំណាត់ថ្នាក់បទល្មើសផ្អែកលើធាតុសត្យានុម័ត ........ ២៣
២.២.១ ចំណាត់ថ្នាក់ទៅតាមប្រភេទនៃអំពើសម្ភារៈ ........ ២៣
ក. សកម្មភាពក្នុងការប្រព្រឹត្តបទល្មើសសកម្ម ........ ២៣
ខ. សកម្មភាពក្នុងការប្រព្រឹត្តបទល្មើសអសកម្ម ........ ២៣
២.២.២ ចំណាត់ថ្នាក់ទៅតាមរយៈពេលប្រព្រឹត្តបទល្មើស ........ ២៤
ក. បទល្មើសភ្លាមៗ ........ ២៤
ខ. បទល្មើសបន្តរៀងហូរហែ ........ ២៤
គ. បទល្មើសអូសបន្លាយ ........ ២៥
២.៣ ចំណាត់ថ្នាក់ផ្អែកទៅលើបែបបទជាអត្តនោម័តក្នុងការប្រព្រឹត្តបទល្មើស ........ ២៥
ក. ចេតនាក្នុងការប្រព្រឹត្តបទល្មើស(ការមិនរាងចាល) ........ ២៥
ក.១អានុភាពនៃការមិនរាងចាល ........ ២៦
ក.២លក្ខខណ្ឌនៃការមិនរាងចាល ........ ២៦

ក.៣ ការប្រដូចបទល្មើស ដើម្បីបង្កើតឲ្យមានការមិនរាងចាល ..................................... ២៧
ខ.អចេតនាក្នុងកាប្រព្រឹត្តបទល្មើស ........................................................................ ២៨

## ជំពូកទី៣៖ ប្រភេទនៃបទល្មើសព្រហ្មទណ្ឌ

៣.១ បទល្មើសសំខាន់ៗដែលមានចែងក្នុងក្រមព្រហ្មទណ្ឌ ..................................... ២៩
៣.១.១ ការប៉ះពាល់ដល់ជីវិតមនុស្ស ............................................................ ២៩
ក. បទឃាតកម្ម ............................................................................ ២៩
ខ. បទមនុស្សឃាតដោយអចេតនា ............................................................ ២៩
៣.១.២ ការប៉ះពាល់ដល់បូរណភាពនៃបុគ្គល ................................................... ៣០
ក. បទទារុណកម្ម នឹងអំពើឃោរឃៅ ......................................................... ៣០
ខ. បទហិង្សាដោយចេតនា ................................................................. ៣០
គ. បទគំរាមកំហែង ......................................................................... ៣១
ឃ.បទបង្កឲ្យមានរបួសដោយអចេតនា ........................................................ ៣១
៣.១.៣ ការបំពានខាងផ្លូវភេទ .................................................................. ៣១
ក. បទរំលោភសេពសន្ថវៈ ..................................................................... ៣១
ក.១ បទប្រទូស្តកេរខ្មាស ...................................................................... ៣២
ក.២ បទបង្ហាញកេរភេទ ...................................................................... ៣៣
ក.៣ បទរុកកួនខាងផ្លូវភេទ ................................................................... ៣៣
ខ. បទល្មើសពាក់ព័ន្ធនឹងអំពើជួញដូរមនុស្សនឹងអំពើអាជីវកម្មផ្លូវភេទ ............................. ៣៣
ខ.១ សញ្ចារកម្ម ............................................................................ ៣៣
ខ.២ ការរួមភេទជាមួយអនីតិជនអាយុក្រោម១៥ឆ្នាំ ............................................ ៣៤
ខ.៣ ការទិញពេស្យាចារកុមារ ................................................................ ៣៤
៣.១.៤ ការប៉ះពាល់ដល់សេរីភាព ................................................................ ៣៥
៣.២ ការប៉ះពាល់សេចក្តីថ្លៃថ្នូរ ..................................................................... ៣៥
ក. បទប៉ះពាល់ដល់បូរណភាពនៃសាកសព នឹងប្រមាថទីបញ្ចុះសព ..................................... ៣៥
ខ. បទស្រវឹងជាក់ស្តែង ......................................................................... ៣៦
គ. បទហៅអ្នកដទៃនៅទីសាធារណៈ .......................................................... ៣៦
៣.៣ ការប៉ះពាល់ដល់គ្រួសារ ....................................................................... ៣៦

ក. បទទ្វេពន្ធភាព ..................................................... ៣៦
ខ. បទរួមភេទជាមួយអនីតិជនដោយបុព្វញាតិ ..................................................... ៣៦
៣.៤ បទល្មើសប្រឆាំងនឹងទ្រព្យសម្បត្តិ ..................................................... ៣៧
ក. អំពើលួច..................................................... ៣៧
ខ. បទកំហែងយក ..................................................... ៣៧
គ. បទគំរាមកំហែងផែកក្ដី ..................................................... ៣៨
ឃ. បទឆបោក ..................................................... ៣៨
ង. ការរំលោភលើទំនុកចិត្ត ..................................................... ៣៨
ច. បទទទួលផលចោរកម្ម..................................................... ៣៩
ឆ. បទបន្លំ..................................................... ៤០
ជ. បទធ្វើឲ្យខូចខាតដោយចេតនា..................................................... ៤០
៣.៥ ការប៉ះពាល់ដល់សន្តិសុខសាធារណៈ..................................................... ៤១
ក. ក្រុមជនប្រដាប់អាវុធ ..................................................... ៤១
ខ. បទល្មើសក្នុងវិស័យអាវុធ គ្រឿងផ្ទុះ នឹងគ្រាប់រំសេវ ..................................................... ៤១
គ. បទចូលរួមសមាគមជនទុច្ចរិត..................................................... ៤១
**សេចក្តីសន្និដ្ឋា**..................................................... **៤៣**
**អនុសាសន៍**..................................................... **៤៤**
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្ដីផ្ដើម

# សេចក្តីផ្តើម

នៅក្នុងការរស់នៅប្រចាំថ្ងៃ គ្មានអ្នកណាជៀសពីការមិនមានទំនាស់ មិនមានការប៉ះទង្គិចគ្នានោះទេ ដូចនេះបានជាប្រទេសទាំងអស់សុទ្ធតែមានច្បាប់ដោយបង្កើតចងក្រងនូវច្បាប់ដោយឡែកពីគ្នាទៅតាមប្រទេសផ្សេងៗគ្នា សម្រាប់ចាត់វិធានការទៅលើបទល្មើសដែលបានកើតឡើង ។

ការកំណត់មែកធាងនីតិព្រហ្មទណ្ឌជាច្រើនដូចជា នីតិព្រហ្មទណ្ឌទូទៅ នីតិព្រហ្មទណ្ឌពិសេស នីតិវិធីព្រហ្មទណ្ឌជាដើម ។ យ៉ាងណាមិញ បទល្មើសព្រហ្មទណ្ឌ គឺជាអំពើទាំងឡាយណាដែលត្រូវផ្តន្ទាទោសដោយច្បាប់ព្រហ្មទណ្ឌ ហើយក៏ជាកំហុសរបស់ចារីដែលប្រព្រឹត្ត ។ មួយវិញទៀត បទល្មើសនីមួយៗដែលបង្កដោយចារីសុទ្ធតែបង្កផលប៉ះពាល់ដល់ការរីកចម្រើនរបស់ប្រទេសជាតិនិងសង្គមទាំងមូល ។ ដូចនេះប្រជាពលរដ្ឋគ្រប់រូបត្រូវតែគោរពនិងប្រតិបត្តិទៅតាមច្បាប់កំណត់និងចែង ដើម្បីរក្សាស្ថេរភាព ភាពរីកចម្រើននៅក្នុងសង្គម ។

ក្រុមរបស់យើងខ្ញុំសម្រេចយកប្រធានបទ “ **បទល្មើសព្រហ្មទណ្ឌ** ” នោះមកបកស្រាយដើម្បីផ្តោតនៅលើនិយមន័យបទល្មើស ធាតុផ្សំនៃបទល្មើស ចំណាត់ថ្នាក់នៃបទល្មើស ការទទួលខុសត្រូវក្នុងរឿងព្រហ្មទណ្ឌ ។

លើសពីនេះទៅទៀត ចំណាត់ថ្នាក់នៃបទល្មើសដែលសំខាន់ជាងគេ ហើយត្រូវបានស្គាល់ច្រើន នោះគឺបទល្មើសបទលហុ បទមជ្ឈិម និងបទឧក្រិដ្ឋ ។

សារណាមួយនេះ បានរៀបចំឡើង ដោយការខិតខំស្វែករកឯកសារមេរៀនពីសាស្ត្រាចារ្យនៅក្នុងសកលវិទ្យាល័យ ។ ក្រុមនាងខ្ញុំបានស្វះស្វែងសាកសួរព័ត៌មានដែលទាក់ទងទៅនឹងប្រធានបទសារណាមួយនេះ ពីអ្នកជំនាញផ្នែកច្បាប់ ដើម្បីឲ្យយល់កាន់តែពិស្តាទៅលើប្រធានបទសារណានេះ ។ ដើម្បីឆ្លើយតបទៅនឹងប្រធានបទខាងលើ ក្រុមនាងខ្ញុំបានបែងចែកជា....ជំពូកធំៗ ដូចជា:

**ជំពូកទី១៖ សញ្ញាណទូទៅនៃបទល្មើសព្រហ្មទណ្ឌ**

**ជំពូកទី២៖ ចំណាត់ថ្នាក់នៃបទល្មើសព្រហ្មទណ្ឌ**

**ជំពូកទី៣៖ ប្រភេទនៃបទល្មើសព្រហ្មទណ្ឌ**

# ជំពូកទី១
# សញ្ញាណទូទៅនៃបទល្មើស

# ជំពូកទី១
# សញ្ញាណទូទៅនៃបទល្មើសព្រហ្មទណ្ឌ

## ១.១ និយមន័យ

បទល្មើសព្រហ្មទណ្ឌ គឺជាអំពើទាំងឡាយដែលត្រូវតែផ្តន្ទាទោសដោយច្បាប់ព្រហ្មទណ្ឌ ហើយក៏ជាកំហុសរបស់ចារីផ្ទាល់តែម្តង។ ផ្ទុយទៅវិញ ប្រសិនបើច្បាប់ពុំបានចាត់ទុកថាអំពើណាមួយជាបទល្មើសទេ អំពើនោះមិនអាចត្រូវចាត់ទុកថាជាបទល្មើសបានឡើយ ដោយអនុលោមតាម គោលការណ៍នីត្យានុកូលភាពដែលមានចែងនៅមាត្រា ៣ នៃក្រមព្រហ្មទណ្ឌ។

## ១.២ ភាពខុសប្លែកគ្នារវាងបទល្មើសព្រហ្មទណ្ឌ និង អំពើល្មើសផ្សេងៗទៀត

នៅក្នុងសង្គម មានអំពើដែលមនុស្សធ្វើជាច្រើនដែលបង្កភាពចរាចលដល់សង្គម ហើយច្បាប់ក៏បានរកវិធីចាត់វិធានការដើម្បីរក្សាស្ថិរភាពនៃទំនាក់ទំនងបុគ្គល។ គេក៏ឃើញមានអំពើល្មើសផ្នែករដ្ឋប្បវេណី នឹងអំពើល្មើសផ្នែកវិន័យ ដែលសុទ្ធសឹងតែជាអំពើបង្កាញគ្រោះថ្នាក់ដល់សង្គម។

### ១.២.១ ភាពខុសគ្នារវាងបទល្មើសព្រហ្មទណ្ឌ និង អំពើល្មើសផ្នែករដ្ឋប្បវេណី

អំពើល្មើសផ្នែករដ្ឋប្បវេណី ត្រង់មាត្រា ៧៤៣ កថាខណ្ឌទី១នៃក្រមរដ្ឋប្បវេណី បានចែងថា បុគ្គលដែលបំពានដោយខុសច្បាប់នូវសិទ្ធ ឬ ផលប្រយោជន៍របស់ជនដទៃ ដោយកំហុសចេតនា ឬ ដោយកំហុសអចេតនា ត្រូវទទួលខុសត្រូវក្នុងការសងការខូចខាតដែលកើតឡើងដោយអំពើនោះ។ រីឯបទល្មើសព្រហ្មទណ្ឌវិញ ត្រូវតែជាអំពើដែលច្បាប់បានចែងយ៉ាងច្បាស់លាស់ ថាជាបទល្មើសព្រហ្មទណ្ឌ។

សម្រាប់អំពើល្មើសផ្នែករដ្ឋប្បវេណី ព្យសនកម្មគឺជាកត្តាចាំបាច់ណាស់ ដើម្បីអាចអោយចៅក្រមពិចារណា លើការដាក់ទណ្ឌកម្មលើអ្នកប្រព្រឹត្តបាន។ ផ្ទុយទៅវិញ ការបង្កើតជាបទល្មើសព្រហ្មទណ្ឌ ពុំមែនសុទ្ធតែទាមទារអោយមាននូវព្យសនកម្មនោះទេ ដូចជា បទល្មើសជួញដូរគ្រឿងញៀន ឬ ការបើកបរលឿនខុសច្បាប់ជាដើម។

អំពើមួយអាចចាត់ទុកជាបទល្មើសព្រហ្មទណ្ឌ ប៉ុន្តែពុំមែនជាអំពើល្មើសផ្នែករដ្ឋប្បវេណីទេ ដូចជាការល្មើសដោយពុំព្រមឈប់ពេលភ្លើងស្តុបក្រហម និងការជួញដូរគ្រឿងញៀន ជាដើម។ ទន្ទឹមនឹងនេះ អំពើល្មើសផ្នែករដ្ឋប្បវេណីខ្លះថ្វីត្បិតតែជាអំពើខុសឆ្គង ប៉ុន្តែពុំមែនជាបទល្មើសព្រហ្មទណ្ឌទេ។

ផ្ទុយទៅវិញ អំពើមួយអាចត្រូវបានចាត់ទុកថាជាបទល្មើសព្រហ្មទណ្ឌផង ព្រមទាំងជាអំពើល្មើសផ្នែករដ្ឋប្បវេណីផងក៏បានដែរ ដូចជា៖ ឃាតកម្ម ឬ អំពើហិង្សាដោយចេតនាដល់តតិយជន ជាដើម។ ក្នុង

ករណីបែបនេះ អំពើល្មើសនាំឲ្យមានបណ្តឹងពីរប្រភេទគឺ **បណ្តឹងអាជ្ញា**[1] ( បណ្តឹងអាជ្ញាមានគោលបំណង ពិនិត្យអត្ថិភាពនៃបទល្មើសបង្ហាញឲ្យឃើញពីពិរុទ្ធភាព (ភាពមានកំហុស) នៃជនល្មើសនិង ផ្តន្ទាទោសពួ ជននេះ (តាមច្បាប់កំណត់)និង **បណ្តឹងរដ្ឋប្បវេណី**[2] (បណ្តឹងរដ្ឋប្បវេណីមានគោលបំណងធ្វើឲ្យបានជួស ជុលការខូចខាត ដែលបណ្តាលមកពីអំពើល្មើសដល់ភាគីរងគ្រោះ ហើយក្នុងគោលបំណងនេះ ឲ្យអ្នករង គ្រោះបានទទួលសំណងជម្ងឺចិត្តធួនល្មមនឹងព្យសនកម្មដែលខ្លួនបានទទួល។

### ១.២.២ភាពខុសគ្នារវាងបទល្មើសព្រហ្មទណ្ឌ និង អំពើល្មើសផ្នែកវិន័យ

អំពើល្មើសផ្នែកវិន័យ គឺជាអំពើដែលធ្វើឲ្យប៉ះពាល់ដល់ផលប្រយោជន៍សមូហភាពនៃក្រុមសង្គម ណាមួយ ដូចជា ពេទ្យ មេធាវី សារការី យោធិន និស្សិត ជាដើម ដោយអំពើទាំងនោះមិនត្រូវបានកំណត់ឲ្យ ច្បាស់លាស់ជាទូទៅទេ ។

មាត្រា ៥៩ នៃច្បាប់ស្តីពីលក្ខន្តិកៈមេធាវី ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ១៩៩៥ បានចែងថា ៖ ត្រូវទទួល ទណ្ឌកម្មជាបទវិន័យចំពោះមេធាវីណាដែលប្រព្រឹត្តនឹងវិធានវិជ្ជាជីវៈ ឬ ប្រព្រឹត្តអំពើណាមួយដែលប៉ះពាល់ ដល់សីលធម៌ ឬកិត្តិយសមេធាវី ទោះបីប្រព្រឹត្តក្រៅពីការប្រកបវិជ្ជាជីវៈរបស់ខ្លួនក៏ដោយ ។[3] ការកំណត់ យ៉ាងដូច្នេះពិតជាបានបង្ហាញឲ្យយើងឃើញថា អំពើល្មើសផ្នែកវិន័យសម្រាប់វិជ្ជាជីវៈមេធាវីពុំត្រូវបាន បញ្ជាក់ឲ្យច្បាស់ជាមុន ដូចក្នុងករណីនៃបទល្មើសព្រហ្មទណ្ឌទេ ពីព្រោះជាអំពើដែលបានបង្កឲ្យប៉ះពាល់ ដល់សីលធម៌ ឬ កិត្តិយសមេធាវីជាសញ្ញាមួយមានលក្ខណៈទូលំទូលាយណាស់ ។

ផ្ទុយទៅវិញ ទោះបីជាមានច្រើនយ៉ាងណាក៏ដោយ បទល្មើសព្រហ្មទណ្ឌក៏សុទ្ធសឹងតែជាអំពើដែល ច្បាប់បានកំណត់ទុកយ៉ាងណាច្បាស់លាស់ជាមុនរួចជាស្រេចអស់ហើយ បានសេចក្តីថា អំពើណាដែល ច្បាប់ពុំបានចែងទុកជាមុនថាជាបទល្មើសព្រហ្មទណ្ឌនោះ គឺពុំអាចចាត់ទុកវាជាបទល្មើសព្រហ្មទណ្ឌ ឡើយ នេះបើផ្អែកតាមគោលការណ៍នីត្យានុកូលភាពនៃបទល្មើស ។

---

[1] មាត្រា ២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ បណ្តឹងរដ្ឋប្បវេណី មានគោលបំណងពិនិត្យអត្ថិភាពនៃបទល្មើស បង្ហាញឲ្យ ឃើញពិរុទ្ធភាពនៃជនល្មើស និងផ្តន្ទាទោសជននេះតាមច្បាប់កំណត់

[2] មាត្រា ២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ បណ្តឹងរដ្ឋប្បវេណី មានគោលបំណងធ្វើឲ្យបានជួសជុលការខូចខាត ដែល បណ្តាលមកពីអំពើល្មើស ដល់ភាគីរងគ្រោះ ហើយក្នុងគោលបំណងនេះ ឲ្យអ្នករងគ្រោះបានទទួលសំណងជម្ងឺចិត្តធួនល្មម និង ព្យសនកម្មដែលខ្លួនបានទទួល

[3] មាត្រា ៥៩ នៃច្បាប់ស្តីពីលក្ខន្តិកៈមេធាវី ២២ សីហា ១៩៩៥

លើសពីនេះទៅទៀត អំពើល្មើសផ្នែកវិន័យបានធ្វើឲ្យប៉ះពាល់តែផ្នែកណាមួយនៃសង្គមតែប៉ុណ្ណោះ ពោលគឺក្រុមសង្គមដែលជនប្រព្រឹត្តល្មើសស្ថិតនៅ ។ ក៏ប៉ុន្តែបទល្មើសព្រហ្មទណ្ឌវិញ គឺជាអំពើដែលបានបង្កនូវការប៉ះពាល់ដល់សង្គមជាទូទៅ ។

ការដាក់ទណ្ឌកម្មលើអំពើល្មើសខាងវិន័យ ត្រូវធ្វើដោយស្ថាប័នពិសេសសម្រាប់ក្រុមសង្គមណាមួយ ដូចជាក្រុមប្រឹក្សាគណៈមេធាវីសម្រាប់ការដាក់វិន័យលើមេធាវី ឬ ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមសម្រាប់ការដាក់វិន័យលើចៅក្រមជាដើម ។ ចំណែកឯការដាក់ទណ្ឌកម្មផ្នែកព្រហ្មទណ្ឌដាក់ពន្ធនាគារអស់មួយជីវិតទៀតផង ។

ជាងនេះទៅទៀត ក៏ដូចជាបំណែងចែករវាងបទល្មើសព្រហ្មទណ្ឌ និង អំពើល្មើសផ្នែករដ្ឋប្បវេណីដែរ ការបែងចែករវាងអំពើល្មើសផ្នែកវិន័យ និងបទល្មើសព្រហ្មទណ្ឌឆ្លុះបញ្ចាំងឲ្យឃើញថា ក្នុងករណីខ្លះ អំពើមួយត្រូវចាត់ទុកជាបទល្មើសព្រហ្មទណ្ឌ ប៉ុន្តែពុំមែនជាអំពើល្មើសផ្នែកវិន័យទេ។

**ឧទាហរណ៍៖** អំពើលួចប្រព្រឹត្តដោយជនអនាថាម្នាក់ ។ ទន្ទឹមគ្នានេះ ពេលខ្លះអំពើមួយត្រូវចាត់ទុកជាអំពើល្មើសផ្នែកវិន័យ ក៏ប៉ុន្តែពុំត្រូវបានចាត់ចូលថាបទល្មើសព្រហ្មទណ្ឌណាមួយឡើយ ។

អំពើមួយចំនួនត្រូវចាត់ចូលជាអំពើល្មើសផ្នែកវិន័យផង និងជាបទល្មើសព្រហ្មទណ្ឌផង ដូចជាឃាតកម្មដែលបានប្រព្រឹត្តដោយវេជ្ជបណ្ឌិតម្នាក់ទៅលើអតិថិជនរបស់ខ្លួន ឬការរំលូតកូនដោយល្មើសនឹងច្បាប់ស្តីពីការរំលូតកូន ។ ល ។

យ៉ាងណាមិញ អំពើដែលច្បាប់កំណត់ថាជាបទល្មើសមានច្រើន ហើយមិនអាចរៀបរាប់ឲ្យអស់សេចក្តីក្នុងរយៈពេលដ៏ខ្លីបានទេ ពោលគឺមិនមានតែក្រមព្រហ្មទណ្ឌប៉ុណ្ណោះទេដែលកំណត់អំពីបទល្មើស ច្បាប់ជាច្រើនផ្សេងៗទៀតក៏កំណត់បទល្មើសដែរ ហើយជាងនេះទៅទៀត បទដ្ឋានគតិយុត្តដែលចេញដោយអង្គការនីតិប្រតិបត្តិ ក៏អាចកំណត់ពីបទលហុដែលត្រូវផ្តន្ទាទោសត្រឹមតែពិន័យជាប្រាក់បានដែរ (មាត្រា ១ កថាខណ្ឌទី២ នៃក្រមព្រហ្មទណ្ឌ) ។ [4] ដូច្នេះ ដើម្បីអាចរាប់បទល្មើសទាំងអស់បាន លុះត្រាតែពិនិត្យឲ្យបានគ្រប់ច្បាប់ និងបទដ្ឋានគតិយុត្តទាំងអស់ក្នុងគ្រប់វិស័យដែលពាក់ព័ន្ធ ទើបអាចដឹងបាន ។

## ១.៣ ធាតុផ្សំនៃបទល្មើសព្រហ្មទណ្ឌ

ជាគោលការណ៍ដែលមានចែងក្នុងមាត្រា២៣ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៧ ការចោទប្រកាន់ និងការផ្តន្ទាទោសជនណា ឬបុគ្គលណាមួយបានលុះត្រាតែ តុលាការបានរកឃើញ និងបានប្រកាសពិរុទ្ធភាពដាក់បន្ទុកលើជននោះជាមុនសិន។

[4] ក្រមព្រហ្មទណ្ឌ លេខ នស/រកម/១១០៩/០២២ ៣០ វិច្ឆិកា ២០០៩ មាត្រា១

ការប្រកាសពិរុទ្ធភាពលើជនណា ឬបុគ្គលណាមួយ អាចអនុវត្តបានលុះត្រាតែអំពើដែលប្រព្រឹត្ត នោះ មានធាតុផ្សំគ្រប់គ្រាន់ ដែលតុលាការអាចប្រកាសទោសលើជន ឬ បុគ្គលនោះបាន។ ផ្ទុយទៅវិញបើអំពើ ដែលប្រព្រឹត្តនោះពុំមានធាតុផ្សំគ្រប់គ្រាន់ ឬ ពុំមានភស្តុតាងដាក់បន្ទុកលើជនជាប់ចោទ ឬ បុគ្គលណាមួយនោះទេ តាមគោលការណ៍ តុលាការមិនអាចប្រកាសផ្តន្ទាទោសលើជន ឬបុគ្គលនោះបានទេ។ ដោយហេតុនេះ ជន ឬបុគ្គល ដែលត្រូវចោទប្រកាន់តាមផ្លូវតុលាការនោះ ក៏ត្រូវតែបានរួចពីបទប្រកាន់តាមផ្លូវច្បាប់ដែលមានចែងក្នុងមាត្រា ៣៥០ និងមាត្រា ៣៥១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧។

### ១.៣.១ ធាតុផ្សំនីត្យានុកូលនៃបទល្មើស

ធាតុនីត្យានុកូលបានសេចក្តីថា ដើម្បីកំណត់អំពើណាមួយ ជាបទល្មើសបានលុះត្រាតែមានចែងក្នុងច្បាប់ បើច្បាប់ពុំបានចែងទេនោះមិនអាចកំណត់ថាអំពើនោះ ឬ ជាបទល្មើសបានឡើយ។ ជាគោលការណ៍បទល្មើសឧក្រិដ្ឋ នឹង បទល្មើសមជ្ឈិម ត្រូវមានប្រភពចេញពីច្បាប់ ចំណែកបទលហុ អាចចេញពីអំណាចនីតិប្រតិបត្តិ ឬ មកពីអាជ្ញាធរសាធារណៈ។

ដើម្បីផ្តន្ទាទោសលើអំពើល្មើសណាមួយបានលុះត្រាតែមានច្បាប់ចែង ប៉ុន្តែនៅក្នុងករណីមួយចំនួនថ្វីត្បិតតែច្បាប់បានចែងហើយក៏ដោយ ក៏គេពុំទទួលខុសត្រូវខាងព្រហ្មទណ្ឌដែរដូចជា:

- វិបល្លាស្មារតី (មាត្រា៣១ នៃក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា)
- ការអនុញ្ញាតដោយច្បាប់ឬអាជ្ញាស្របច្បាប់(មាត្រា ៣២)
- ការការពារស្របច្បាប់(មាត្រា៣៣)
- ស្ថានភាពចាំបាច់(មាត្រា៣៥)
- អានុភាពនៃកម្លាំង ឬ ការបង្ខំ (មាត្រា៣៦)
- អនីតិភាព(មាត្រា៣៩)។

តាមគោលការណ៍ឯកត្តកម្មនៃការទទួលខុសត្រូវព្រហ្មទណ្ឌមានចែងមាត្រា២៤ នៃក្រមព្រហ្មទណ្ឌ បុគ្គលម្នាក់ៗត្រូវទទួលខុសត្រូវព្រហ្មទណ្ឌចំពោះអំពើផ្ទាល់ខ្លួនប៉ុណ្ណោះ ។

ធាតុផ្សំបទល្មើសព្រហ្មទណ្ឌមានបីគឺៈធាតុផ្សំនីត្យានុកូល ធាតុផ្សំសត្យានុម័ត និង ធាតុផ្សំអត្តនោម័ត។

#### ក. គោលការណ៍នីត្យានុកូលភាពនៃបទល្មើស និងទោស

ធាតុផ្សំនីត្យានុកូល គឺជាធាតុផ្សំទាក់ទងនឹងច្បាប់ (មាត្រា ៣ នៃក្រមព្រហ្មទណ្ឌ) ។ ជាក់ស្តែងមាត្រា៣ នៃក្រមព្រហ្មទណ្ឌ គឺជាបទបញ្ញត្តិមូលដ្ឋានដែលចែងពីគោលការណ៍នីត្យានុកូលភាព ដោយមាត្រានេះបានចែងថា មានតែអំពើដែលបង្កើតជាបទល្មើស នៅពេលដែលអំពើនោះមានចែងក្នុងបទប្បញ្ញត្តិព្រហ្មទណ្ឌជាធរមានប៉ុណ្ណោះ ទើបត្រូវផ្តន្ទាទោសព្រហ្មទណ្ឌបាន។ គោលការណ៍នីត្យានុកូលភាពនៃបទល្មើសនឹងទោស ត្រូវតែកំណត់ដោយច្បាប់យ៉ាងច្បាស់លាស់។ គោលការណ៍នីត្យានុកូលភាពត្រូវ

បានទទួលស្គាល់ដោយ **លិខិតតុបករណ៍អន្តរជាតិ**[5] ដែលមានតម្លៃងជារដ្ឋធម្មនុញ្ញតាមមាត្រា ៣១ នៃរដ្ឋធម្មនុញ្ញ ព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣ ផងដែរ។

**ក.១ នីត្យានុកូលភាពនៃបទល្មើស**

នីត្យានុកូលភាពនៃបទល្មើសមានន័យថា អំពើណាមួយដែលគេអាចចាត់ទុកជាបទល្មើសបាន គឺលុះត្រាតែអំពើនោះមានចែងយ៉ាងច្បាស់លាស់ក្នុងច្បាប់ថាជាបទល្មើស បើមិនដូច្នោះទេតុលាការមិនអាចផ្តន្ទាទោសជនប្រព្រឹត្តនោះបានឡើយ។ ដូច្នេះរាល់ការចោទប្រកាន់ និងការដាក់ទោសទាំងអស់ត្រូវតែផ្អែកលើច្បាប់។ គ្មានច្បាប់ចែង គ្មានបទល្មើស គ្មានទោសឡើយ។ [6]

មាត្រា២ (ក្រមព្រហ្មណ្ឌ) បានបែងចែកបទល្មើសជា ៣ប្រភេទគឺៈ

- បទល្មើសឧក្រិដ្ឋ
- បទល្មើសមជ្ឈិម
- បទល្មើសលហុ។ [7]

**ខ.២ នីត្យានុកូលភាពនៃទោស**

នីត្យានុកូលភាពនៃទោស មានន័យថា ទោសណាមួយអាចយកទៅអនុវត្តលើបុគ្គលណាម្នាក់បានលុះត្រាតែទោសនោះមានចែងទុកជាបទល្មើសព្រហ្មទណ្ឌ បើពុំនោះទេអាចអនុវត្តទោសលើបុគ្គលណាម្នាក់បានឡើយ។

នៅក្រមព្រហ្មទណ្ឌ មាត្រា៣ បានចែងថាមានតែអំពើដែលបង្កើតជាបទល្មើសនៅពេលដែលអំពើនោះមានចែងក្នុងបទប្បញ្ញត្តិព្រហ្មទណ្ឌជាធរមានប៉ុណ្ណោះទើបអាចត្រូវផ្តន្ទាទោសបាន។

**ខ. ផលវិបាកនៃគោលការណ៍នីត្យានុកូលភាព**

- ការបកស្រាយជាក់លាក់ត្រឹមត្រូវនៃនីតិព្រហ្មទណ្ឌ គឺដើម្បីអោយចៅក្រមអនុវត្តច្បាប់អោយបានត្រឹមត្រូវ ហើយការផ្តន្ទាទោសត្រូវតែឲ្យចំបទល្មើសដែលមានចែងក្នុងច្បាប់។
- ការបកស្រាយតាមពាក្យពេចន៍ គឺជាការបកស្រាយច្បាប់មួយប្រភេទដោយផ្អែកលើពាក្យពេចន៍ដែលបានចែងច្បាស់លាស់ក្នុងច្បាប់។
- ការបកស្រាយតាមគោលការណ៍ប្រហាក់ប្រហែល គឺភាគច្រើនគេងអនុវត្តនៅប្រទេសប្រកាន់របបសង្គមនិយម(កុំម្មុយនីស្ត) ហេតុនេះហើយបានជាគេឃើញមានច្បាប់នានា របស់ប្រទេសសង្គម

[5] លិខិតតុបករណ៍អន្តរជាតិ គឺជាលិខិតបទដ្ឋានអន្តរជាតិ ដែលបង្កើតឡើងរវាងរដ្ឋ ឬក៏រវាងរដ្ឋ និងអង្គការអន្តរជាតិ

[6] ហ៊ាង ឡេង នីតិព្រហ្មទណ្ឌទូទៅ (ភ្នំពេញ ២០១០)

[7] មាត្រា២ នៃក្រមព្រហ្មទណ្ឌ លេខ នស/រកម/១១០៩/០២២ ៣០ វិច្ឆិកា ២០០៩

និយមច្រើនតែសរសេរខ្លីៗ មិនសូវច្បាស់លាស់ដោយគេសំអាងថា នៅពេលមានការមន្ទិលសង្ស័យ គឺគេតែងតែលើកយកគោលការណ៍នេះមកបកស្រាយ។

– ការបកស្រាយតាមស្មារតីនៃអង្គប្រជុំរបស់រដ្ឋសភា គឺជាការបកស្រាយមួយបែបដោយពឹងផ្អែកលើការពិភាក្សាដេញដោយរបស់វាគ្មិន នៅពេលបញ្ចេញមតិក្នុងការអនុម័តសេចក្តីព្រាងច្បាប់ រឺសេចក្តីស្នើច្បាប់នានា។

ជាក់ស្តែងតាមគោលការណ៍ខាងលើ ដើម្បីអាចឲ្យគេចាត់ទុកថា អំពើមួយជាបទល្មើស ហើយត្រូវផ្តន្ទាទោសបាន លុះត្រាតែមានអត្ថបទច្បាប់បានចែងថា អំពើនោះជាបទល្មើស ហើយត្រូវទទួលទណ្ឌកម្មដែលច្បាប់បានកំណត់។

**គ. វិសាលភាពនៃច្បាប់ព្រហ្មទណ្ឌ**

ការអនុវត្តច្បាប់ព្រហ្មទណ្ឌ គឺជាការសំដែងប្រតិកម្មរបស់សង្គមឆ្លើយតបទៅនឹងជនល្មើសនឹងអំពើល្មើសក្នុងគោលដៅធានាអោយបាននូវភាពសុខស្ងប់ សណ្តាប់ធ្នាប់ នឹងរបៀបរៀបរយៈសាធារណៈ ជូនដល់សង្គមទាំងមូល។ ការអនុវត្តច្បាប់ព្រហ្មទណ្ឌចោទជាបញ្ហា២ ដែលត្រូវដោះស្រាយ គឺការអនុវត្តច្បាប់ព្រហ្មទណ្ឌនៅក្នុងពេលវេលា នឹងការអនុវត្តច្បាប់ព្រហ្មទណ្ឌនៅក្នុងលំហ។

**គ.១ការអនុវត្តច្បាប់ព្រហ្មទណ្ឌក្នុងពេលវេលា**

គោលការណ៍ច្បាប់មួយ គឺមានអនុភាពអនុវត្តតែក្នុងពេលអនាគត ពោលគឺចាប់ពីថ្ងៃចូលជាធរមានរហូតដល់ពេលនិរាករណ៍កែប្រែ រឺជំនួសដោយច្បាប់ថ្មី។ តាមមាត្រា៩៣ ថ្មី នៃរដ្ឋធម្មនុញ្ញ ឆ្នាំ១៩៩៣ បានបញ្ញត្តិថា ច្បាប់ដែលរដ្ឋសភាបានអនុម័ត និងព្រឹទ្ធសភាបានពិនិត្យច្បាប់សព្វគ្រប់រួចហើយៗ ត្រូវបានព្រះមហាក្សត្រប្រកាសអោយប្រើត្រូវចូលជាធរមាននៅភ្នំពេញ គឺមានរយៈពេល១០ថ្ងៃគត់ ក្រោយប្រកាសអោយប្រើ នឹងជាទូទាំងប្រទេស គឺមានរយៈពេល២០ថ្ងៃគត់ ក្រោយប្រកាសអោយប្រើ។ ប៉ុន្តែបើច្បាប់នេះបានចែងជាការប្រញាប់ ច្បាប់នេះត្រូវចូលជាធរមាន ភ្លាមនៅទូទាំងប្រទេស ក្រោយថ្ងៃប្រកាសអោយប្រើ។ ដូចនេះច្បាប់ក្នុងន័យទូទៅ និងច្បាប់ព្រហ្មទណ្ឌជាពិសេស អាចមានអនុភាពអនុវត្តតែទៅលើអំពើទាំងឡាយណាដែលកើតក្រោយថ្ងៃ ចូលជាធរមានរបស់ខ្លួនតែប៉ុណ្ណោះ ។[8] គោលការណ៍នេះហៅថា គោលការណ៍មិនប្រតិសកម្មនៃច្បាប់ព្រហ្មទណ្ឌ។ គោលការណ៏មិនប្រតិសម្មនៃច្បាប់ព្រហ្មទណ្ឌ មានគោលបំណងការពារសិទ្ធសេរីភាពរបស់ប្រជាពលរដ្ឋ ក្នុងអំពើផ្សេងៗដែលច្បាប់មិនទាន់ចាត់ទុកជាបទល្មើស ទោះបីជាថ្ងៃក្រោយមានច្បាប់ កំណត់អំពើនោះជាបទល្មើសក៏ដោយ ក៏អ្នកប្រព្រឹត្តមិនមានការភ័យដែរ ព្រោះច្បាប់ដែលចូលជាធរមាន មានអនុភាពអនុវត្តទៅលើសកម្មភាពប្រព្រឹត្តដែលកើតឡើងដែលច្បាប់ចូលជាធរមានប៉ុណ្ណោះ។

---

[8] មាត្រា៩៣ ថ្មី នៃរដ្ឋធម្មនុញ្ញ ១៩៩៣

គោលការណ៍មិនប្រតិសកម្មនៃច្បាប់ព្រហ្មទណ្ឌ ចាំបាច់ត្រូវតែសិក្សាពីការអនុវត្តគោលការណ៍នេះទៅលើច្បាប់ព្រហ្មទណ្ឌគ្រឹះ ឬច្បាប់សារធាតុ និងទៅលើច្បាប់ព្រហ្មទណ្ឌទម្រង់ ឬច្បាប់នីតិវិធី ។

➢ **ច្បាប់ព្រហ្មទណ្ឌគ្រឹះ ឬ ច្បាប់សារធាតុ**

ច្បាប់ព្រហ្មទណ្ឌគ្រឹះ ឬ ច្បាប់សារធាតុ គឺជាច្បាប់ដែលកំណត់ពីបទល្មើស និងពីទោសដែលត្រូវអនុវត្តលើបទល្មើស និងលក្ខខណ្ឌនៃការទទួលខុសត្រូវរបស់ចារី ។[9] ច្បាប់ព្រហ្មទណ្ឌគ្រឹះ ឬ ច្បាប់សារធាតុមានច្បាប់ព្រហ្មទណ្ឌជាតិ ច្បាប់ព្រហ្មទណ្ឌអន្តរជាតិ ដែលមានអនុភាពអនុវត្តក្នុងព្រះរាជាណាចក្រកម្ពុជា។ការអនុវត្តក្នុងពេលវេលានៃច្បាប់ព្រហ្មទណ្ឌគ្រឹះ ឬច្បាប់សារធាតុ តាមគោលការណ៍ពីរ៖ គោលការណ៍មិនប្រតិសកម្មនៃច្បាប់ព្រហ្មទណ្ឌថ្មីធ្ងន់ជាង និង គោលការណ៍ប្រតិសកម្មនៃច្បាប់ព្រហ្មទណ្ឌថ្មីស្រាលជាង។

**+ គោលការណ៍មិនប្រតិសកម្មនៃច្បាប់ព្រហ្មទណ្ឌធ្ងន់ជាង**

មាត្រា១០ កថាខណ្ឌទី២ នៃក្រមព្រហ្មទណ្ឌ និងមាត្រា១១ នៃសេចក្តីប្រកាសជាសកលស្តីពីសិទ្ធមនុស្ស និងមាត្រា១៥ នៃកតិសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធនយោបាយចែងថា គ្មានជនណាម្នាក់ត្រូវមានទោសពីបទល្មើសព្រហ្មទណ្ឌឡើយ ចំពោះអំពើ ឬការធ្វេសប្រហែសណាមួយដែលពុំមែនជាបទល្មើសព្រហ្មទណ្ឌ ដែលមាននៅក្រោមច្បាប់ជាតិ ឬច្បាប់អន្តរជាតិនៅខណៈពេលដែលអំពើនោះបានប្រព្រឹត្ត។

តាមគោលការណ៍មិនប្រតិសកម្មនៃច្បាប់ព្រហ្មទណ្ឌធ្ងន់ជាង ច្បាប់ថ្មីអាចអនុវត្តបានតែចំពោះអំពើល្មើសបានប្រព្រឹត្ត ចាប់ពីថ្ងៃច្បាប់ចូលជាធរមានតែប៉ុណ្ណោះ។ច្បាប់ថ្មីគ្មានអនុភាពអនុវត្តទេ។ មិនត្រូវដាក់ទោសធ្ងន់ជាងទោសដែលបានកំណត់នៅខណៈពេលដែលបទល្មើសព្រហ្មទណ្ឌបានប្រព្រឹត្ត។

**+គោលការណ៍ប្រតិសកម្មនៃច្បាប់ស្រាលជាង**

មាត្រា១០ កថាខណ្ឌទី១ នៃក្រមព្រហ្មទណ្ឌ ចែងថាៈ បទប្បញ្ញត្តិថ្មីដែលចែងអំពីទោសដែលស្រាលជាងត្រូវអនុវត្តភ្លាម។ ប៉ុន្តែការផ្តន្ទទោសដែលជាស្ថាពរហើយនោះ ត្រូវអនុវត្ត ទោះបីទោសដែលប្រកាសនោះធ្ងន់ធ្ងរយ៉ាងណាក៏ដោយ។

ច្បាប់ថ្មីស្រាលជាងមានអានុភាពអនុវត្ត ចំពោះបទល្មើសទាំងឡាយណាដែលបានកើតឡើងមុនពេលដែលច្បាប់ថ្មី ចូលជាធរមាន ហើយពុំត្រូវបានវិនិច្ឆ័យជាស្ថាពរឡើយ។ ប្រសិនបើមានសាលក្រម ឬ

[9] ច្បាប់ព្រហ្មទណ្ឌគ្រឹះ ឬ ច្បាប់សារធាតុ គឺជាច្បាប់ដែលកំណត់ពីបទល្មើស និងពីទោសដែលត្រូវអនុវត្តលើបទល្មើស និងលក្ខខណ្ឌនៃការទទួលខុសត្រូវរបស់ចារី

សាលដីការស្ថាពរហើយពុំអាចសើរើកែប្រែបានឡើយ។[10] លើកលែងតែទណ្ឌិតត្រូវបានដាក់ទោសដោយហេតុផលថាបានប្រព្រឹត្តអំពើណាមួយដែលច្បាប់ថ្មីពុំបានចាត់ទុកថាជាបទល្មើស។

➢ **ច្បាប់ព្រហ្មទណ្ឌទម្រង់ ឬ ច្បាប់នីតិវិធី**

ច្បាប់ព្រហ្មទណ្ឌទម្រង់ ឬ ច្បាប់នីតិវិធី ជាច្បាប់ដែលពាក់ពន្ធ័ទៅនឹងការរៀបចំប្រព័ន្ធតុលាការ សមត្ថកិច្ចតុលាការ នីតិវិធីព្រហ្មទណ្ឌ ផ្លូវនៃបណ្ដឹង ឬ ផ្លូវតវ៉ា ការអនុវត្តទោស អាជ្ញាយុកាលនៃបណ្ដឹងអាជ្ញា និង អាជ្ញាយុកាលនៃទោស។[11] ច្បាប់នេះត្រូវអនុវត្តភ្លាមៗចាប់ពីពេលដែលច្បាប់ចូលជាធរមានទោះជាត្រូវអនុវត្តទៅលើបទល្មើសដែលបានប្រព្រឹត្តមុនពេលច្បាប់ចូលក៏ដោយ។ **ឧទាហរណ៍៖** ច្បាប់ស្ដីពីការតែងតាំង និងសកម្មភាពរបស់សាលាជម្រះក្ដីនៃរដ្ឋកម្ពុជា ចុះថ្ងៃទី ៨ កុម្ភះ ឆ្នាំ ១៩៩៣ ត្រង់មាត្រា ២៤ ចែងថា៖ សំនុំរឿងទាំងអស់ទាំងរឿងព្រហ្មទណ្ឌ រឿងរដ្ឋប្បវេណី និងរឿងយោធាដែលតុលាការកំពូលកំពុងពិនិត្យ ទោះជាពិនិត្យលើកទី១ ឬលើកទី២ក្ដីត្រូវបញ្ជូនទៅសាលាឧទ្ធរណ៍ដើម្បីជម្រះក្ដី។

**គ.២ ការអនុវត្តច្បាប់ព្រហ្មទណ្ឌនៅក្នុងលំហ**

ការអនុវត្តច្បាប់ព្រហ្មទណ្ឌក្នុងលំហ នៅពេលកើតមានវិវាទមាន ជាតិបរទេស ចូលរួមដោយវិវាទនេះ។

➢ **បទល្មើសដែលបានប្រព្រឹត្តនៅកម្ពុជាលើដែនដីកម្ពុជា**

បទល្មើសដែលប្រព្រឹត្ត ឬ ចាត់ថាបានប្រព្រឹត្តនៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា៖

គោលការណ៍ដែនដីនៃច្បាប់ គឺក្នុងរឿងព្រហ្មទណ្ឌច្បាប់កម្ពុជាត្រូវអនុវត្តទៅលើបទល្មើសទាំងឡាយដែលបានប្រព្រឹត្តនៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា។ ដែនដីនៃព្រះរាជាណាចក្រកម្ពុជា រួមបញ្ចូលទាំងលំហអាកាស និងសមុទ្រ ដែលមានចំណងចងភ្ជាប់នឹងដែនដីនៃព្រះរាជាណាចក្រកម្ពុជា។[12] បទល្មើសត្រូវបានចាត់ថាប្រព្រឹត្តនៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជានៅពេលដែលអំពើណាមួយនៃបទល្មើសនោះ បានប្រព្រឹត្តនៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា។[13] គោលការណ៍ដែនដីនៃច្បាប់ព្រហ្មទណ្ឌ គឺរួមមានគោលការណ៍សំខាន់ៗដូចជា :

• **បទល្មើសដែលបានប្រព្រឹត្តនៅក្នុងនាវាកម្ពុជា** គឺច្បាប់កម្ពុជាត្រូវអនុវត្តទៅលើបទល្មើសដែលប្រព្រឹត្តនៅក្នុងនាវាដែលមានសញ្ជាតិខ្មែរ ទោះបីជានាវានោះស្ថិតនៅទីណាក៏ដោយ។[14] ច្បាប់កម្ពុជាត្រូវអនុវត្តទៅលើ

[10] មាត្រា១១ នៃក្រមព្រហ្មទណ្ឌ លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩

[11] **ច្បាប់ព្រហ្មទណ្ឌទម្រង់ ឬ ច្បាប់នីតិវិធី** ជាច្បាប់ដែលពាក់ពន្ធ័ទៅនឹងការរៀបចំប្រព័ន្ធតុលាការ សមត្ថកិច្ចតុលាការ នីតិវិធីព្រហ្មទណ្ឌ ផ្លូវនៃបណ្ដឹង ឬ ផ្លូវតវ៉ា ការអនុវត្តទោស អាជ្ញាយុកាលនៃបណ្ដឹងអាជ្ញា និង អាជ្ញាយុកាលនៃទោស

[12] មាត្រា១២ នៃក្រមព្រហ្មទណ្ឌ លេខ នស/រកម/១១០៩/០២២ ៣០ វិច្ឆិកា ២០០៩

[13] មាត្រា១៣ នៃក្រមព្រហ្មទណ្ឌ លេខ នស/រកម/១១០៩/០២២ ៣០ វិច្ឆិកា ២០០៩

[14] មាត្រា១៤ នៃក្រមព្រហ្មទណ្ឌ លេខ នស/រកម/១១០៩/០២២ ៣០ វិច្ឆិកា ២០០៩

បទល្មើសដែលប្រព្រឹត្តនៅក្នុងនាវាបរទេសដែលអាជ្ញាធរកម្ពុជាបានទទួលការអនុញ្ញាតឲ្យពិនិត្យមើល ឬឲ្យចាប់នាវាតាមអំណាចនៃកិច្ចព្រមព្រៀងអន្តរជាតិ។[15]

- **បទល្មើសដែលបានប្រព្រឹត្តនៅក្នុងអាកាសយានកម្ពុជា** គឺច្បាប់កម្ពុជាត្រូវអនុវត្តទៅលើបទល្មើសដែលប្រព្រឹត្តនៅក្នុងអាកាសយានដែលចុះបញ្ជីនៅព្រះរាជាណាចក្រកម្ពុជា ទោះបីជាអាកាសយាននោះស្ថិតនៅទីណាក៏ដោយ។[16] ច្បាប់កម្ពុជាត្រូវអនុវត្តទៅលើបុគ្គលគ្រប់រូបដែលជាអ្នកផ្តើមគំនិត ឬ អ្នកសមគំនិតនៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា ក្នុងបទឧក្រិដ្ឋ ឬ បទមជ្ឈិម ដែលប្រព្រឹត្តនៅឯបរទេស ប្រសិនបើលក្ខខណ្ឌទាំងពីរដូចខាងក្រោមនេះ ត្រូវបានបំពេញៈ បទល្មើសត្រូវផ្តន្ទាទោសតាមច្បាប់កម្ពុជា និងតាមច្បាប់បរទេសផង និង អត្ថិភាពនៃបទល្មើស ត្រូវបានបញ្ជាក់ដោយសេចក្តីសម្រេចជាស្ថាពររបស់តុលាការបរទេស។

- **សមត្ថកិច្ចដោយឡែកចំពោះបទឧក្រិដ្ឋដោយឡែក** គឺច្បាប់កម្ពុជាត្រូវអនុវត្តទៅលើបទល្មើស ដែលប្រព្រឹត្តនៅក្រៅដែនដីនៃព្រះរាជាណាចក្រកម្ពុជា ហើយបើបទល្មើសនោះជា[17]៖

  - បទល្មើសប្រឆាំងនឹងសុវត្ថិភាពនៃព្រះរាជាណាចក្រកម្ពុជា។
  - បទល្មើសក្លែងត្រាផ្លូវការនៃព្រះរាជាណាចក្រកម្ពុជា។
  - បទល្មើសក្លែងរូបិយវត្ថុ និងធនបត្រជាតិ ដែលមានតម្លៃស្របច្បាប់នៅព្រះរាជាណាចក្រកម្ពុជា។
  - បទល្មើសប្រឆាំងនឹងភ្នាក់ងារទូត ឬកុងស៊ុលនៃព្រះរាជាណាចក្រកម្ពុជា។
  - បទល្មើសប្រឆាំងនឹងទីតាំងទូត ឬកុងស៊ុលនៃព្រះរាជាណាចក្រកម្ពុជា។

ច្បាប់កម្ពុជាត្រូវអនុវត្តទៅលើគ្រប់បទឧក្រិដ្ឋដែលប្រព្រឹត្តដោយពលរដ្ឋខ្មែរនៅក្រៅដែនដីនៃព្រះរាជាណាចក្រកម្ពុជា។ ច្បាប់កម្ពុជាត្រូវអនុវត្តទៅលើបទមជ្ឈិមដែលប្រព្រឹត្តដោយពលរដ្ឋខ្មែរ នៅក្នុងប្រទេសក្រៅណាមួយ ប្រសិនបើអំពើនោះត្រូវបានផ្តន្ទាទោសតាមច្បាប់នៃប្រទេសនោះផងដែរ។ ទោះបីជាជនជាប់ចោទបានទទួលសញ្ជាតិខ្មែរក្រោយអំពើដែលចោទប្រកាន់នេះក៏ដោយ។[18]

ច្បាប់កម្ពុជាត្រូវបានអនុវត្តទៅលើគ្រប់បទឧក្រិដ្ឋដែលប្រព្រឹត្តនៅក្រៅដែនដីនៃព្រះរាជាណាចក្រកម្ពុជាដោយពលរដ្ឋខ្មែរ ឬ ដោយជនបរទេសទៅលើជនរងគ្រោះដែលមានសញ្ជាតិខ្មែរ នៅក្នុងពេលដែលបទល្មើសត្រូវបានប្រព្រឹត្ត។[19]

---

[15] មាត្រា១៥ នៃក្រមព្រហ្មទណ្ឌ លេខ នស/រកម/១១០៩/០២២ ៣០ វិច្ឆិកា ២០០៩

[16] មាត្រា១៦ នៃក្រមព្រហ្មទណ្ឌ លេខ នស/រកម/១១០៩/០២២ ៣០ វិច្ឆិកា ២០០៩

[17] មាត្រា២២ នៃក្រមព្រហ្មទណ្ឌ លេខ នស/រកម/១១០៩/០២២ ៣០ វិច្ឆិកា ២០០៩

[18] មាត្រា១៩ នៃក្រមព្រហ្មទណ្ឌ លេខ នស/រកម/១១០៩/០២២ ៣០ វិច្ឆិកា ២០០៩

[19] មាត្រា២០ នៃក្រមព្រហ្មទណ្ឌ លេខ នស/រកម/១១០៩/០២២ ៣០ វិច្ឆិកា ២០០៩

+ គោលការណ៍ដែនដីនៃការអនុវត្តច្បាប់ព្រហ្មទណ្ឌកម្ពុជា

បទល្មើសមួយដែលត្រូវបានចាត់ទុកបានប្រព្រឹត្តនៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា។ មាត្រា ១៤ នឹងមាត្រា១៦ នៃក្រមព្រហ្មទណ្ឌ កាលបើបានប្រព្រឹត្តៈ

•មាននៅក្នុងនាវាដែលមានសញ្ជាតិខ្មែរទោះជាវាស្ថិតនៅទីណាក៏ដោយ។

•នៅក្នុងអាកាសយានដែលបានចុះបញ្ជីនៃព្រះរាជាណាចក្រកម្ពុជា ទោះជាអាកាសយាននោះស្ថិតទីណាក៏ដោយ។ ដូច្នោះការប្រព្រឹត្តបទល្មើសនៅលើនាវា ឬអាកាសយានត្រូវស្ថិតនៅក្រោមការគ្រប់គ្រងរបស់ច្បាប់កម្ពុជា។

តាមមាត្រា១៥ នៃក្រមព្រហ្មទណ្ឌ បានប្រគល់សមត្ថកិច្ចឲ្យច្បាប់កម្ពុជាបន្ថែមទៀត ចំពោះបទល្មើសដែលបានប្រព្រឹត្តនឹងក្នុងនាវាបរទេសដែលអាជ្ញាធរកម្ពុជា ឲ្យចាប់តាមអំណាចនៃកិច្ចព្រមព្រៀងអន្តរជាតិ។

+ ការកម្រិតនៃការអនុវត្តគោលការណ៍ដែនដី

មាត្រា២៩ នៃអនុសញ្ញាទីក្រុងវីយែនស្តីពីទំនាក់ទំនងការទូតបានចែងថា បុគ្គលនៃភ្នាក់ងារការទូតមិនអាចរំលោភបំពានបានឡើយ។ បុគ្គលនេះមិនអាចត្រូវបានចាប់ខ្លួនឡើយ។ រដ្ឋដែលទទួលត្រូវគោរពភ្នាក់ងារទូត និងត្រូវចាត់វិធានការសមស្របទាំងឡាយ ដើម្បីរាំងនូវរាល់ការប៉ះពាល់ដល់ រាងកាយ សេរីភាព និងសេចក្តីថ្លៃថ្នូររបស់ជននោះ។

➢ បទល្មើសប្រព្រឹត្តប្រព្រឹត្តនៅក្រៅដែនដីព្រះរាជាណាចក្រកម្ពុជា

+ គោលការណ៍សញ្ជាតិនៃការអនុវត្តច្បាប់ព្រហ្មទណ្ឌកម្ពុជា

ច្បាប់កម្ពុជាត្រូវអនុវត្តទៅលើបទឧក្រិដ្ឋទាំងអស់ ដែលប្រព្រឹត្តដោយជននោះ។ ច្បាប់កម្ពុជាអនុវត្តលើបទមជ្ឈិមបាន លុះត្រាតែអំពើនោះត្រូវបានផ្តន្ទាទោសតាមច្បាប់នៃប្រទេសដែលបទល្មើសបានកើតឡើងផងដែរ។ដោយមាត្រា១៩នៃក្រមព្រហ្មទណ្ឌ បទឧក្រិដ្ឋ ឬ បទមជ្ឈិមប្រព្រឹត្តដោយពលរដ្ឋខ្មែរ ចែងថា ក្នុងរឿងព្រហ្មទណ្ឌ ច្បាប់កម្ពុជាត្រូវអនុវត្តទៅលើគ្រប់បទឧក្រិដ្ឋដែលប្រព្រឹត្តដោយពលរដ្ឋខ្មែរនៅក្រៅដែនដីនៃព្រះរាជាណាចក្រកម្ពុជា។

ច្បាប់កម្ពុជាត្រូវអនុវត្តទៅលើបទមជ្ឈិមដែលប្រព្រឹត្តដោយពលរដ្ឋខ្មែរ នៅក្នុងប្រទេសក្រៅណាមួយប្រសិនបើអំពើនោះត្រូវបានផ្តន្ទាទោសតាមច្បាប់នៃប្រទេសនោះផងដែរ។

បទប្បបញ្ញត្តិទាំងនេះ ត្រូវអនុវត្តផងដែរ ទោះបីជាជនជាប់ចោទបានទទួលសញ្ជាតិខ្មែរក្រោយអំពើដែលចោទប្រកាន់នេះក៏ដោយ។

ករណីដែលជនរងគ្រោះជាពលរដ្ឋខ្មែរ ច្បាប់កម្ពុជាត្រូវយកអនុវត្តលើគ្រប់បទឧក្រិដ្ឋដែលប្រព្រឹត្តនៅក្រៅដែនដីនៃព្រះរាជាណាចក្រកម្ពុជាទោះបីជននោះជាជនបរទេសឬជាពលរដ្ឋខ្មែរក៏ដោយ។ យោងតាម

មាត្រា២០ នៃក្រមព្រហ្មទណ្ឌ ជនរងគ្រោះជាជនជាតិខ្មែរ ចែងថា ក្នុងរឿងព្រហ្មទណ្ឌ ច្បាប់កម្ពុជាត្រូវបានអនុវត្តទៅលើគ្រប់បទឧក្រិដ្ឋដែលប្រព្រឹត្តនៅក្រៅដែនដីនៃព្រះរាជាណាចក្រកម្ពុជាដោយពលរដ្ឋខ្មែរ ឬដោយជនបរទេសទៅលើជនរងគ្រោះដែលមានសញ្ជាតិខ្មែរ នៅក្នុងពេលដែលបទល្មើសត្រូវបានប្រព្រឹត្ត។

**គ.៣ការអនុវត្តច្បាប់កម្ពុជាដោយសារការប៉ះពាល់ផលប្រយោជន៍កម្ពុជា**

ច្បាប់កម្ពុជាក៏មានសមត្ថកិច្ចអនុវត្តដែល ប្រសិនបើបទល្មើសប៉ះពាល់ដល់អធិបតេយ្យភាពរបស់កម្ពុជា ទោះបីបានប្រព្រឹត្តនៅបរទេសក៏ដោយ៖

- បទល្មើសក្លែងត្រាផ្លូវការនៃព្រះរាជាណាចក្រកម្ពុជា។
- បទល្មើសប្រឆាំងនឹងភ្នាក់ងារទូត។
- បទល្មើសក្លែងរូបិយវត្ថុ។
- បទល្មើសប្រឆាំងនឹងសុវត្ថិភាពនៃព្រះរាជាណាចក្រកម្ពុជា។

**១.៣.២ ធាតុផ្សំសត្យានុម័ត ឬ សម្ភារៈនៃបទល្មើស**

ធាតុផ្សំសត្យានុម័ត គឺជាអង្គហេតុ ឬជាហេតុការទាំងឡាយណាដែលបង្កឲ្យ កើតមាននូវអាកាប្បកិរិយាណាមួយ។ អង្គហេតុទាំងនេះច្រើនសន្ធឹកសន្ធាប់ណាស់ អាចជាអំពើវិជ្ជមាន (សកម្ម) ជាអំពើអវិជ្ជមាន (អកម្ម) អំពើកើតឡើងភ្លាមៗ ឬ អូសបន្លាយក្នុងពេលវេលា អំពើកើតឡើងម្តងម្កាល ឬ ជាទម្លាប់ អំពើធម្មតា ស្មុគស្មាញ ។ល។

បទល្មើសកើតឡើងតែក្នុងករណីដែលមានអាកប្បកិរិយាជាសម្ភារៈសម្តែងចេញ ខាងក្រៅតែប៉ុណ្ណោះ អាកប្បកិរិយានេះទៀតសោតត្រូវបានហាមឃាត់ដោយច្បាប់ ពោលគឺច្បាប់បានបញ្ញត្តទុក។អំពើដែលស្តែងឲ្យឃើញយ៉ាងពិតប្រាកដ ពីបំណងក្នុងការប្រព្រឹត្តបទល្មើសមានដូចជា៖ តាមរយៈ កាយវិការ សំដីសំណេរ ឬអាកប្បកិរិយាសាមញ្ញណាមួយផ្សេងទៀត។

ធាតុផ្សំសត្យានុម័តរបស់បទល្មើសនីមួយៗ ត្រូវបានកំណត់នៅក្នុងអត្ថបទច្បាប់ដែលបញ្ជាក់បទល្មើស។ ធាតុផ្សំសត្យានុម័តអាចហៅម៉្យាងទៀតថា៖ ធាតុផ្សំសម្ភារៈ គឺជាអង្គហេតុ ឬ ជាហេតុការណ៍ទាំងឡាយណាដែលបង្កឲ្យកើតមាននូវអាកប្បកិរិយាណាមួយ។ អំពើជាំសម្ភារៈអាចជាអំពើធម្មតា ដូចជាលូកដៃយកវត្ថុអ្វីមួយរហូតដល់អំពើដែលមានលក្ខណៈស្មុគស្មាញតាមរយៈការរៀបចំឲ្យមាននូវឧបាយកលផ្សេងៗ ជាដើម។ ហើយអំពើនៃបទល្មើសអាចជាការបាញ់កាំភ្លើង ការចាក់ដោយកាំបិតការយកវត្ថុរបស់អ្នកដទៃការបើកបរឆ្លងកាត់ភ្លើងស្តុបពណ៌ក្រហម។

**ក. ធាតុផ្សំសម្ភារៈក្នុងបទល្មើសបានសម្រេច**

បទល្មើសដែលជនល្មើសបានប្រព្រឹត្តបទល្មើសបានសម្រេចដូចបំណងរបស់ខ្លួន។ ជាក់ស្តែង ជនដែលបានប្រព្រឹត្តបទល្មើសនឹងត្រូវជាប់ពន្ធនាគារ ហើយជនរងគ្រោះ គឺអាចនឹងប៉ះពាល់ដល់ជីវិត

បូរណភាពរូបកាយ និងប៉ះពាល់ដល់ទ្រព្យសម្បត្តិ រួមទាំងកម្មវត្ថុនៃបទល្មើសអាចប៉ះពាល់ដល់ជាតិថែម ទៀតផងដែរ។

**ក.១ដំណាក់កាលប្រព្រឹត្តបទល្មើស**

គោលការណ៍ដំណាក់កាលនៃការប្រព្រឹត្តបទល្មើសបានបែងចែងជា៤ គឺ ដំណាក់កាលនៃការគិត នឹងការសម្រេចចិត្តប្រព្រឹត្តបទល្មើស ដំណាក់កាលនៃការត្រៀមរៀបចំប្រព្រឹត្តបទល្មើស ដំណាក់កាលនៃការចាប់ផ្តើមប្រព្រឹត្តបទល្មើស នឹងដំណាក់កាលនៃការសម្រេចបទល្មើស ឬបទល្មើសប៉ុនប៉ង។

- **ដំណាក់កាលនៃការគិត នឹងការសម្រេចចិត្តប្រព្រឹត្តបទល្មើស**

ដំណាក់កាលនៃការគិត នឹងការសម្រេចចិត្តប្រព្រឹត្តបទល្មើស គឺជាដំណាក់កាលដំបូងដែលជនល្មើសគ្រាន់តែគិតនៅក្នុងចិត្ត ប៉ុន្តែពុំទាន់ធ្វើសកម្មភាពទេ។ អ្វីដែលចង់បញ្ជាក់ក្នុងដំណាក់កាលនេះ គឺច្បាប់មិនទាន់បានចែងអោយផ្តន្ទាទោស ចំពោះអ្នកដែលគិតនឹងសម្រេចប្រព្រឹត្តបទល្មើសណាមួយដោយហេតុថា បទល្មើសនោះមិនទាន់លិចជារូបរាងមកក្រៅហើយមិនរងជាព្យសនកម្មដល់សង្គម។

- **ដំណាក់កាលនៃការត្រៀមរៀបចំប្រព្រឹត្តបទល្មើស**

ដំណាក់កាលនៃការត្រៀមរៀបចំប្រព្រឹត្តបទល្មើស គឺជាដំណាក់កាល ជនដែលបម្រុងនិងប្រព្រឹត្តបទល្មើសដែលពួកគេបានត្រៀមជាឧបករណ៍ ដែលសម្រួលអោយការប្រព្រឹត្តបទល្មើសមានប្រសិទ្ធភាព។ ទោះបីជាជននោះបានធ្វើការសម្រេចចិត្តនិងរៀបចំជាឧបករណ៍ដែលសម្រួលអោយ បទល្មើសនោះ មានប្រសិទ្ធភាពក៏ដោយ ក៏ការគិតនិងការរៀបចំឧបករណ៍នោះគឺពុំបង្កអោយមានព្យសនកម្មដល់សង្គមរឺជនណាមួយឡើយ។

- **ដំណាក់កាលនៃការចាប់ផ្តើមប្រព្រឹត្តបទល្មើស**

ដំណាក់កាលនៃការចាប់ផ្តើមប្រព្រឹត្តបទល្មើស គឺជាដំណាក់កាលដែលជននោះបានចាប់ផ្តើមប្រព្រឹត្តបទល្មើសតាមការគិត និងការសម្រេចចិត្ត ហើយនឹងត្រៀមរៀបចំប្រព្រឹត្តបទល្មើសនោះ។

- **ដំណាក់កាលនៃការសម្រេចបទល្មើស ឬ បទល្មើសប៉ុនប៉ង**

ដំណាក់កាលនៃការសម្រេចបទល្មើស ឬ បទល្មើសប៉ុនប៉ង គឺជាដំណាក់កាលចុងក្រោយបំផុតនៃការប្រព្រឹត្តបទល្មើស។ ក្នុងដំណាក់កាលនេះ គឺជាជនល្មើសអាចទទួលបាននូវលទ្ធផលពីរយ៉ាងគឺ:

- ទី១ ប្រសិនបើលទ្ធផលនៃការប្រព្រឹត្តបទល្មើស បានបំពេញតាមបំណងរបស់ជនល្មើសនោះ គឺមានន័យថាបទល្មើសនោះ គឺជាបទល្មើសបានសម្រេច។

- ទី២ ផ្ទុយទៅវិញប្រសិនបើលទ្ធផលនៃការប្រព្រឹត្តបទល្មើសនោះ មិនស្របតាមបំណងឬឆន្ទះរបស់ជនល្មើសនោះ មិនស្របតាមបំណងឬឆន្ទះរបស់ជនល្មើសនោះ ដោយគ្រាន់តែផ្តល់នូវព្យសនកម្មធ្ងន់ធ្ងរ ឬស្រាលដល់ជនរងគ្រោះនោះ គឺហៅថាបទល្មើសប៉ុនប៉ង។

**ក.២ការប្រព្រឹត្តបទល្មើស( សកម្មភាព)**

សកម្មភាព គឺជាអំពើរបស់ជនល្មើស ក្នុងការប្រព្រឹត្តបទល្មើសក្រោមរូបភាពសកម្ម ឬ អកម្មបានសម្រេច ឬ មិនបានសម្រេច។

- **បទល្មើសសកម្ម**

បទល្មើសសកម្ម ជាសកម្មភាពយ៉ាងខិតខំរបស់មនុស្សម្នាក់បំពានទៅលើទំនាក់ទំនងសង្គមដែលនីតិព្រហ្មទណ្ឌបានការពារ។ បទល្មើសនេះ មានច្រើនជាងគេនៅក្នុងចំណោមបទល្មើសព្រហ្មទណ្ឌដូចជា បទល្មើសប្រឆាំងនឹងបុគ្គល បទល្មើសប្រឆាំងនិងទ្រព្យសម្បត្តិ បទល្មើសប្រឆាំងនឹងជាតិជាដើម។ ការធ្វើអោយសម្រេចបទល្មើសទាំងនេះ មានដូចជា :

- អំពើលួច គ្រាន់តែប្រើកាយវិការទៅយកទ្រព្យសម្បត្តិរបស់គេ មកធ្វើជារបស់ខ្លួន។

- អំពើមនុស្សឃាតដោយចេតនា ដោយប្រើកាំភ្លើង គ្រាន់តែយកចង្អុលដៃសង្កត់ទៅលើកាំភ្លើង តម្រង់ទៅជនរងគ្រោះ កាយវិការប៉ុណ្ណោះ អាចបង្កើតបានជាបទល្មើសជាស្រេច។ បន្ទាប់ពីកាយវិការ ប្រព្រឹត្តបទល្មើស ជនល្មើសបានបង្កើតកម្មវិបាកមួយ គឺ ការខូចខាតផ្សេងៗធ្លាក់ទៅលើជនរងគ្រោះ។

❖ **បទល្មើសសម្ភារៈ**

បទល្មើសសម្ភារៈ គឺជាបទល្មើសទាំងឡាយណាដែលជនល្មើសបានប្រព្រឹត្តដោយបានប្រើប្រាស់នូវសម្ភារៈក្នុងការប្រព្រឹត្តបទល្មើស ដែលមានចរិតគ្រោះថ្នាក់ដល់សង្គម ដែលលទ្ធផលនៃបទល្មើសនោះបានបង្ហាញនូវជាតុផ្សំសត្យានុម័ត។

ឧទាហរណ៍:

– ជនល្មើសបានលើដំបងវាយសំពងទៅលើជនរងគ្រោះ។

– ជនល្មើសបានលើកកាំភ្លើងបាញ់ជនរងគ្រោះ។

❖ **បទល្មើសរូបភាព**

បទល្មើសរូបភាពមានលក្ខណៈផ្ទុយពីបទល្មើសសម្ភារៈ។ បទល្មើសរូបភាព គឺជាបទល្មើសដែលគេមិនសំដៅទៅលើលទ្ធផងទៅជាយ៉ាងណានោះទេគឺអោយតែសកម្មភាពបានប្រព្រឹត្តគេចាប់ទុកថាជាបទល្មើសបនាសម្រេចហើយ។បទល្មើសរូបភាពស្ថិតនៅលើការចោទប្រកាន់ទៅលើសកម្មភាពប្រព្រឹត្តតែម្តង។

ឧទាហរណ៍:

–ការចូលរួមក្នុងក្រុមណាមួយដែលបង្កើតឡើង ឬចូលរួមក្នុងការសន្និដ្ឋិភាពដែលធ្វើឡើងដើម្បីរៀបចំអំពើឧក្រិដ្ឋប្រល័យពូជសាសន៍។[20]

–ឡើងដើម្បីរៀបចំអំពើឧក្រិដ្ឋប្រល័យពូជសាសន៍។[21]

- **បទល្មើសអកម្ម**

បទល្មើសអកម្មគឺ ជាបទល្មើសដែលសំដៅទៅលើការបំពានកាតព្វកិច្ចដែលច្បាប់តម្រូវអោយធ្វើ ហើយយើងមានលទ្ធភាពគ្រប់គ្រាន់និងធ្វើ តែមិនធ្វើតាមការកំណត់របស់ច្បាប់។ ដើម្បីកំណត់ថា ជនណាម្នាក់ប្រព្រឹត្តបទល្មើសអកម្មបាន ត្រូវផ្អែកលើមូលដ្ឋានពីរគឺ៖

- ជនប្រព្រឹត្តបទល្មើសអកម្ម គឺជាជនដែលមានកាតព្វកិច្ចត្រូវបំពេញ ហើយកិច្ចការនោះអាស្រ័យដោយ:
  - ច្បាប់បានកំណត់
  - បទបញ្ជារបស់ស្ថាប័នមានសមត្ថកិច្ច ឬ សេចក្តីសម្រេចរបស់តុលាការ
  - ចេញពីករណីកិច្ចរបស់ការងារ ឬ ចេញពីមុខងារដោយមានកិច្ចសន្យា
  - ការគេចចេញពីការទទួលខុសត្រូវដោយសារកំហុសរបស់ខ្លួន។
- ជនប្រព្រឹត្តបទល្មើសអកម្ម គឺជាជនដែលមានលក្ខណះសម្បត្តិគ្រប់គ្រាន់ ដើម្បីអនុវត្តកាតព្វកិច្ចរបស់ខ្លួន ផ្ទុយទៅវិញបើសិនជាគ្មានលក្ខណះសម្បត្តិគ្រប់គ្រាន់ទេ មិនអាចទទួលខុសត្រូវព្រហ្មទណ្ឌទេ។

**ខ. ធាតុផ្សំនៃបទល្មើសមិនបានសម្រេច**

បទល្មើសមិនបានសម្រេច គឺជាអំពើប្រព្រឹត្តដោយចេតនា ប៉ុន្តែអំពើប្រព្រឹត្តនោះមិនទាន់ចប់នៅឡើយដោយសារមូលហេតុផ្សេងៗមកបង្អាក់សកម្មភាពនោះ។

**ខ.១ លក្ខខណ្ឌនៃការប៉ុនប៉ងមានទោស**

ការប៉ុនប៉ងក្នុងបទឧក្រិដ្ឋ ឬ ក្នុងករណីដែលច្បាប់បានចែងទុកក្នុងបទមជ្ឈិម អាចត្រូវផ្តន្ទាទោសបាន កាលណាលក្ខខណ្ឌខាងក្រោមនេះត្រូវបានបំពេញ:

- ចារី បានចាប់ផ្តើមអនុវត្តបទល្មើស មានន័យថា ចារីបានប្រព្រឹត្តអំពើដែលមានគោលបំណងដោយផ្ទាល់ដើម្បីប្រព្រឹត្តបទល្មើស និង
- ចារីមិនបានបញ្ឈប់អំពើរបស់ខ្លួនទៅវិញដោយស្ម័គ្រចិត្ត តែត្រូវបានរាំងស្ទះ ឬ អាក់ខាន ដោយ

[20] មាត្រា១៨៥ នៃក្រមព្រហ្មទណ្ឌ លេខ នសរកម១១០៩០២២ ៣០ វិច្ឆិកា ២០០៩

[21] មាត្រា១៨៥ នៃក្រមព្រហ្មទណ្ឌ លេខ នសរកម១១០៩០២២ ៣០ វិច្ឆិកា ២០០៩

ឥទ្ធិពលនៃកាលៈទេសៈក្រៅឆន្ទរបស់ខ្លួន។[22]

ជាទូទៅការប្រព្រឹត្តបទល្មើស ត្រូវបានចែងចែកជា៣ដំណាក់កាលគឺៈ

-មុនគេបង្អស់គឺការគិត (ការសម្រេចចិត្តប្រព្រឹត្ត) ដំណាក់កាលនេះនីតិព្រហ្មទណ្ឌពុំផ្តន្ទាទោសចំពោះជនណាដែលគ្រាន់តែមានគំនិត ឬ សម្រេចថាប្រព្រឹត្តបទល្មើសឡើយ ពីព្រោះមិនទាន់បណ្តាលអោយមានគ្រោះថ្នាក់ដល់សង្គម។

- ដំណាក់កាលទី២( ជាដំណាក់កាលត្រៀមប្រព្រឹត្តបទល្មើស): នៅក្នុងដំណាក់កាល កាលនេះ ក៏នីតិព្រហ្មទណ្ឌនៅតែពុំផ្តន្ទាទោសដែរ។

- ទីបញ្ចប់ (ដំណាក់កាលប្រតិបត្តិ) ជនល្មើសអនុវត្តគម្រោងផែនការ ដែលគេគិតទុកជាស្រេច។ ដំណាក់កាលនេះ នីតិព្រហ្មទណ្ឌត្រូវតែផ្តន្ទាទោសដើម្បីទប់ស្កាត់កុំអោយអំពើគ្រោះថ្នាក់សង្គមកើតឡើង។ ការទប់ស្កាត់នេះធ្វើអោយអំពើប្រព្រឹត្តរបស់ជនល្មើសមិនបានស្រេចដែលនាំអោយនូវការប៉ុនប៉ង។

អវត្តមាននៃការបញ្ឈប់ដោយស្ម័គ្រចិត្តបើក្រោយពីការចាប់ផ្តើម ចារីបោះបង់ចោលការប្រព្រឹត្តបទល្មើស គឺ គេមិនត្រូវបាននីតិព្រហ្មទណ្ឌផ្តន្ទាទោសឡើយ។ ការធ្វើដូចនេះមកពីនីតិព្រហ្មទណ្ឌមានបំណងលើកទឹកចិត្តជនល្មើស ដើម្បីអោយគេបោះបង់នូវគ្រោងផែនការខុសច្បាប់របស់គេ។ ការបោះបង់នេះគឺជនល្មើសសំដែងនូវកសរសោកស្តាយពិតប្រាកដ ដើម្បីរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌត្រូវមានលក្ខណៈដូចខាងក្រោម :

- ការបញ្ឈប់ត្រូវតែដោយស្ម័គ្រចិត្ត
- ការបញ្ឈប់ ត្រូវកើតឡើងមុនអំពើគ្រោះថ្នាក់ដល់សង្គមកើតឡើង គឺមុនពេលបទល្មើសបានសម្រេច។

កត្តាដែលនាំអោយមានការបញ្ឈប់ដោយស្ម័គ្រចិត្ត:

- ការអាណិតអាសូរដល់ជនរងគ្រោះ
- ការទូន្មានក្រើនរំលឹករបស់តតិយជន
- ខ្លាចទទួលរងនូវទណ្ឌកម្ម
- យល់ច្បាស់នូវចរិកគ្រោះថ្នាក់ដល់សង្គមនៃអំពើរបស់ខ្លួន។

ប៉ុន្តែគេមិនអាចចាត់ទុកជាការបញ្ឈប់ដោយស្ម័គ្រចិត្តបាន នៅពេលដែល:

- បទល្មើសបានសម្រេច
- សកម្មភាពបានស្តារឡើងវិញ នូវស្ថានភាពដើមដែលជនល្មើសបានប្រព្រឹត្តរួចហើយ។

**ឧទាហរណ៍៖** ស្ម័គ្រចិត្តសងទ្រព្យសម្បត្តិដែលខ្លួនបានលួច ទៅអោយម្ចាស់ទ្រព្យគេវិញ ក្រោយពីបាន

[22] មាត្រា២៧ នៃក្រមព្រហ្មទណ្ឌ លេខ នស/រកម/១១០៩/០២២ ៣០ វិច្ឆិកា ២០០៩

លួច។ ករណីនេះគ្រាន់តែជាការសោកស្តាយ ហើយតុលាការអាចយកមកធ្វើជាស្ថានសម្រាលនៅពេលកំណត់ទោសតែប៉ុណ្ណោះ។

### ១.២ ការផ្តន្ទាទោសចំពោះការប៉ុនប៉ងប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ

នៅក្នុងក្រមព្រហ្មទណ្ឌបានកំណត់នូវបញ្ញត្តិមួយចំនួនដែល តម្រូវអោយជនល្មើសទទួលខុសត្រូវចំពោះសកម្មភាពរបស់ខ្លួនទៅ តាមបទល្មើសដែលខ្លួនបានប្រព្រឹត្ត។ ប៉ុន្តែក៏មានបទល្មើសខ្លះក្រមព្រហ្មទណ្ឌមិនបានដាក់ទណ្ឌកម្ម ចំពោះការប៉ុនប៉ងប្រព្រឹត្តបទល្មើសនោះទេ។ ជាទូទៅចៅក្រមក៏មិនដាក់ទោសទៅលើចារី អោយធ្ងន់ធ្ងរដូចជាចារីប្រព្រឹត្តបទល្មើសបានសម្រេចនោះឡើយ។

- **ការប៉ុនប៉ងប្រព្រឹត្តបទឧក្រិដ្ឋ**

ចំពោះការប៉ុនប៉ងលើបទឧក្រិដ្ឋគ្រប់ប្រភេទ គឺត្រូវតែមានទោស ឬត្រូវតែផ្តន្ទាទោស។[23] គ្មានការប្រព្រឹត្តបទល្មើសឧក្រិដ្ឋណាមួយដែលមិនកើតចេញពីការប៉ុនប៉ងនោះទេ។

- **ការប៉ុនប៉ងប្រព្រឹត្តបទមជ្ឈិម**

ការប៉ុនប៉ងក្នុងបទមជ្ឈិមអាចផ្តន្ទាទោសបាន លុះត្រាតែមានច្បាប់ចែងដាក់លាក់។[24] ដើម្បីអាចផ្តន្ទាទោសលើការប៉ុនប៉ងបទល្មើសមជ្ឈិមណាមួយបាន លុះត្រាតែមានច្បាប់ចែងយ៉ាងច្បាស់លាស់ថា ការប៉ុនប៉ងក្នុងបទមជ្ឈឹមណាមួយត្រូវមានទោស ឬត្រូវផ្តន្ទាទោសតាមទម្ងន់នៃបទល្មើសនោះ។

- **ការប៉ុនប៉ងប្រព្រឹត្តបទលហុ**

ការប៉ុនប៉ងនៅក្នុងបទលហុ គឺពុំត្រូវទទួលការផ្តន្ទាទោសទេ។[25] បើសិនជាបុគ្គលណាមួយបានប្រព្រឹត្តបទលហុ បុគ្គលនោះពុំត្រូវផ្តន្ទាទោស ឬ ទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌទៅការប៉ុនប៉ងទេដោយសារច្បាប់ មិនបានចែងអោយមានការផ្តន្ទាទោសលើការប៉ុនប៉ងក្នុងបទលហុឡើយ។

### ១.៣.៣ ធាតុផ្សំអត្តនោម័ត

ធាតុផ្សំអត្តនោម័ត គឺជាចិត្តគំនិតខាងក្នុងរបស់ជនល្មើស ដែលវាស្តែងមកខាងក្រៅតាមរយៈធាតុសត្យានុម័តដូចជា កាយវិការ ឬ អំពើប្រព្រឹត្តរបស់ជនល្មើសបាន ។

ធាតុអត្តនោម័តគឺ សំដៅលើចេតនាឬស្ថានភាពផ្លូវចិត្តរបស់ជនប្រព្រឹត្តបទល្មើសព្រហ្មតណ្ឌជាមួយ។ នៅក្នុងមាត្រា៤ កថាខណ្ឌ១ ក្នុងក្រមព្រហមទណ្ឌ បានចែងថាផងដែរថា ពុំមានបទល្មើសទេប្រសិនបើគ្មានចេតនាប្រព្រឹត្ត។ ប្រសិនបើជនណាម្នាក់នឹងអាចត្រូវផ្តន្ទាទោសព្រហ្មទណ្ឌបាន លុះត្រាតែមានធាតុផ្សំមួយនេះដែរ ពោលគឺជននោះមិនទទួលខុសត្រូវព្រហ្មទណ្ឌឡើយ។

---

[23] មាត្រា២៧ នៃក្រមព្រហ្មទណ្ឌ នស/រកម/១១០៩/០២២ ៣០ វិច្ឆិកា ២០០៩

[24] មាត្រា២៧ នៃក្រមព្រហ្មទណ្ឌ នស/រកម/១១០៩/០២២ ៣០ វិច្ឆិកា ២០០៩

[25] មាត្រា២៧ នៃក្រមព្រហ្មទណ្ឌ នស/រកម/១១០៩/០២២ ៣០ វិច្ឆិកា ២០០៩

**ក. កំហុសចេតនា និងកំហុសអចេតនា**

អំពើល្មើសនឹងច្បាប់ព្រហ្មទណ្ឌទាំងឡាយសុទ្ធតែបណ្តាលមកពីកំហុស។ ជាគោលការណ៍កំហុសត្រូវ ចេញពីចេតនារបស់ជនល្មើស ប៉ុន្តែអាចចេញមកពីការភ្លេចភ្លាំង ឬការបំភ្លេច ឬ មកពីការធ្វេសប្រហែសផងដែរ។

**ក.១កំហុសចេតនា**

មាត្រា ៤ កថាខណ្ឌ ទី១ នៃក្រមព្រហ្មទណ្ឌ ចែងថា ពុំមានបទល្មើសទេ ប្រសិនបើគ្មានចេតនាប្រព្រឹត្ត។ ចេតនា គឺជាធាតុផ្សំអត្តនោម័តនៃបទល្មើសដោយចេតនា។

មានចេតនាប្រព្រឹត្តបទល្មើសកាលបើ :

-ចារីស្វែងរកលទ្ធផលខុសច្បាប់ពីអំពើរបស់ខ្លួន។

-ចារីដឹងថាអំពើរបស់ខ្លួននឹងផ្តល់នូវលទ្ធផលខុសច្បាប់។

ចេតនាប្រព្រឹត្តបទល្មើសរួមមាន :

- **ចេតនាសម្រេចបទល្មើស** គឺជាចេតនារបស់បុគ្គលម្នាក់ដែលមានសេរីភាព និង មនសិការគ្រប់គ្រាន់ក្នុងការរកលទ្ធផល ដែលច្បាប់ព្រហ្មទណ្ឌហាមឃាត់។
- **ចេតនាប្រព្រឹត្តអំពើ** ចារីបានប្រព្រឹត្តអំពើរបស់ខ្លួន។
- **ចេតនាទុច្ចរិត** អ្នកនីតិបញ្ញត្តិបានកំណត់យកមូលហេតុនៃការប្រព្រឹត្តបទល្មើសមកធ្វើជាមូលហេតុនៃការកំណត់ទណ្ឌកម្មអោយកាន់តែធ្ងន់ ដោយសារតែចារីមានចេតនាបង្កនូវគ្រោះថ្នាក់យ៉ាងខ្លាំង និងយ៉ាងធ្ងន់ធ្ងរដល់សង្គម។
- **ចេតនាទុច្ចរិតទូទៅ** គឺជាចេតនារបស់ចារីក្នុងការប្រព្រឹត្តអំពើដែលខ្លួនបានដឹងច្បាស់ថាច្បាប់ព្រហ្មទណ្ឌបានមហាឃាត់។ ចេតនាទុច្ចរិតទូទៅគឺសំដៅទៅលើចេតនាព្យាបាទណាមួយទេ គឺសំដៅទៅលើចេតនាបំពានច្បាប់ព្រហ្មទណ្ឌ ឬបំពានលើការមហាឃាត់ច្បាប់។
- **ចេតនាទុច្ចរិតពិសេស** គឺជាចេតនាដែលចារីចង់បានលទ្ធផលពិសេសណាមួយសម្រាប់បទល្មើសដែលខ្លួនប្រព្រឹត្ត។

**ក.២កំហុសអចេតនា**

អចេតនាប្រព្រឹត្តបទល្មើស ជាការប្រព្រឹត្តបទល្មើសដែលបានដឹងជាមុនថា អំពើរបស់ខ្លួនអាចបង្កអោយមានគ្រោះថ្នាក់ដល់សង្គមដែលកើតដោយសារការ ធ្វេសប្រហែស ឬការខ្ជីខ្ជារ។ ចារីមានបំណងធ្វើសកម្មភាពរបស់ខ្លួនប៉ុន្តែមិនមានឆន្ទៈ រឺ ពុំបានដឹងពីផលវិបាកដែលកើតចេញពីអំពើរបស់ខ្លួនឡើយ។

កំហុសអចេតនា គឺសំដៅទៅលើៈ

❖ **ការមិនប្រុងប្រយ័ត្ន**

គឺសំដៅទៅលើអំពើទាំងឡាយណាដែលបណ្តាលមកពីការមិនប្រុងប្រៀបស្មារតីដោយការរាយមាយជាដើម។ ឧទាហរណ៍ៈ ការបើកម៉ូតូដោយមិនគិតពីបញ្ហាផ្សេងៗដែលកើតនៅកន្លែងធ្វើការនឹងបញ្ហាគ្រួសារដោយមិនបានតាំងស្មារតីលើការបក់បរដោយធ្វើឲ្យប៉ះពាល់ដល់អ្នកដទៃ ដោយគេមិនបានដឹងនោះ គឺជាការបើកបរដោយខ្វះការប្រុងប្រយ័ត្ន។

❖ **ការខ្ជីខ្ជា**

គឺសំដៅលើការធ្វើការ ឬ និយាយអ្វីដោយមិនបានគិតឲ្យម៉ត់ចត់ជាមុនសិន។ ឧទាហរណ៍៖ បុរសម្នាក់បានកាន់កាំបិតទៅខាងលើដៅបូលផ្ទះជួលដោយមិនបានប្រយ័ត្ន គាត់បានធ្វើឲ្យធ្លាក់កាំបិតទៅក្មេងម្នាក់នៅខាងក្រោមផ្ទះ បណ្តាលឲ្យមានរបួស។

❖ **ការធ្វេសប្រហែស**

គឺជាការភ្លេចភ្លាំង ការបណ្តែតបណ្តោយ ការមាក់ងាយដោយជនល្មើស។ ឧទាហរណ៍៖ នារីម្នាក់បានបោះកែងថ្មពីលើផ្ទះមកខាងក្រោមដោយមិនបានដឹងថាមានមនុស្សនៅពីខាងក្រោម ទើបបណ្តាលឲ្យមានរបួសបែកក្បាលលើបុរសម្នាក់នោះទៅ។

**ខ. ការវាយតម្លៃអំពីកំហុសចេតនា និង កំហុសអចេតនា**

សម្រាប់បទលហុជាច្រើន ចារីត្រូវបានសន្មតថាមានកំហុស នៅពេលដែលធាតុផ្សំសត្យានុម័តនៃបទល្មើសមានគ្រប់គ្រាន់។ ប្រសិនបើរកឃើញថា ចារីបានបើកបរដោយមិនបានពាក់ខ្សែក្រវាត់ការពារ ឬមួកការពារសុវត្ថិភាព គឺមានន័យថាពិតជាបានប្រព្រឹត្តកំហុសពិតហើយ។

# ជំពូលទី២
# ចំណាត់ថ្នាក់នៃបទល្មើស

# ជំពូលទី
# ចំណាត់ថ្នាក់នៃបទល្មើស

ដើម្បីស្គាល់ឲ្យបានច្បាស់នូវប្រភេទនៃបទល្មើសនីមួយៗ គឺជាការចាំបាច់ណាស់ដែលត្រូវតែធ្វើចំណាត់ថ្នាក់នៃបទល្មើសទាំងអស់ ក្នុងគោលដៅសម្រួលដល់ការកំណត់ និងស្គាល់នូវរបបគតិយុត្ត ក្នុងការអនុវត្តចំពោះបទល្មើសណាមួយ។ ការបែងចែកបទល្មើសដែលសំខាន់ជាងគេបំផុតគឺការបែងចែករវាង បទឧក្រិដ្ឋ បទមជ្ឈិម និងបទលហុ។

## ២.១ ការបែងចែករវាងបទលហុ បទមជ្ឈិម និងបទឧក្រិដ្ឋ

មាត្រា២ វាក្យខណ្ឌទី២ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩ បានបញ្ញត្តិថា បទល្មើស ត្រូវបានចាត់ថ្នាក់ជា បទឧក្រិដ្ឋ បទមជ្ឈិម និងបទលហុ ទៅតាមទម្ងន់នៃបទល្មើសនោះ។

ចំពោះការបែងចែកបទល្មើស គឺត្រូវបានបែងចែកជា៣ប្រភេទ ទៅតាមលក្ខណៈធ្ងន់ធ្ងរនៃបទល្មើស គឺពិតជាមានសារៈសំខាន់ណាស់នៅក្នុងនីតិព្រហ្មទណ្ឌ ពីព្រោះថាការបែងចែកបទល្មើសនាំមកនូវផលប្រយោជន៍ទាក់ទងនឹងរបបគតិយុត្ត ដែលច្បាប់រមែងតែងតែភ្ជាប់ទៅនឹងប្រភេទនីមួយៗនៃបទល្មើស។

### ២.១.១ លក្ខណៈវិនិច្ឆ័យនៃការបែងចែក

ដើម្បីអាចដឹងពីប្រភេទនៃបទល្មើស គឺគេត្រូវពិនិត្យមើលទៅលើអតិបរមានៃទោសដែលច្បាប់បានចែងទុកសម្រាប់បទល្មើសនីមួយៗ។

**ក. បទឧក្រិដ្ឋ**

បទល្មើសជាបទឧក្រិដ្ឋ នៅក្នុងករណីដែលអតិបរមានៃទោសដាក់ពន្ធនាគារត្រូវរងនូវការផ្តន្ទាទោសដូចខាងក្រោមគឺៈ

- ទោសដាក់ពន្ធនាគារអស់មួយជីវិត។
- ទោសដាក់ពន្ធនាគារមានរយៈពេលលើសពី ៥ឆ្នាំ និងក្រោម ឬស្មើ៣០ឆ្នាំ។

ទោសដាក់ពន្ធនាគារ អាចត្រូវបន្ថែមនូវទោសពិន័យជាប្រាក់ផងដែរ។

ឧទាហរណ៍ :

-បទរំលោភសេពសន្ថវៈ (មាត្រា២៣៩ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ (២០០៩)។

-បទឃាតកម្ម (មាត្រា១៩៩ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ (២០០៩)។

**ខ. មជ្ឈិម**

បទល្មើសជាបទមជ្ឈិម នៅក្នុងករណីដែលអតិបរមានៃទោសដាក់ពន្ធនាគារដែលត្រូវរងនោះ មានរយៈពេលលើសពី ៦ថ្ងៃ និងក្រោម ឬស្មើនឹង៥ឆ្នាំ។

ទោសដាក់ពន្ធនាគារ អាចត្រូវបន្ថែមនូវទោសពិន័យជាប្រាក់ផងដែរ។

ឧទាហរណ៍ៈ

- បទហិង្សាដោយចេតនា (មាត្រា២១៧ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ(២០០៩)។
- បទធ្វើឲ្យខូចខាតដោយចេតនា (មាត្រា៤១០ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ(២០០៩)។

- បទលួច (មាត្រា៣៥៦ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩)។

**គ. បទលហុ**

បទល្មើសជាបទលហុ នៅក្នុងករណីដែល៖

- អតិបរមានៃទោសដាក់ពន្ធនាគារមានរយៈពេលក្រោម ឬស្មើនឹង៦ថ្ងៃ ឬក៏ជាបទល្មើសដែលតម្រូវឲ្យផ្តន្ទាទោសត្រឹមតែពិន័យជាប្រាក់ប៉ុណ្ណោះ។
- បទល្មើសត្រូវផ្តន្ទាទោសត្រឹមតែពិន័យជាប្រាក់។

**ឧទាហរណ៍ ៖**

- បទបរិហាកេរ្តិ៍ជាសាធារណៈ (មាត្រា៣០៥ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩)។
- បទជេរប្រមាថជាសាធារណៈ (មាត្រា៣០៧ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩)។

**២.១.២ ផលប្រយោជន៍នៃការបែងចែក**

**ក. ផលប្រយោជន៍ទាក់ទងនិងអាជ្ញាយុកាល**

អាជ្ញាយុកាល គឺជារយៈពេលមួយដែលបានកំណត់ដោយច្បាប់ដែលផុតរយៈពេលនេះ បុគ្គលម្នាក់អាចនឹងបាត់បង់សិទ្ធិណាមួយរបស់ខ្លួន ឬអាចទាមទារសិទ្ធជាប្រយោជន៍របស់ខ្លួន។ ក្នុងច្បាប់ព្រហ្មទណ្ឌអាជ្ញាយុកាលត្រូវបានចែកចេញជាពីរប្រភេទគឺ ១.អាជ្ញាយុកាលនៃបទល្មើស (ឬថា ព្រះអាជ្ញាយុកាលនៃបណ្តឹងអាជ្ញា) និង ២.អាជ្ញាយុកាលនៃទោស។

**១. អាជ្ញាយុកាលនៃបទល្មើស** គឺជារយៈពេលមួយកំណត់ដោយច្បាប់ដែលផុតរយៈពេលនេះ ព្រះរាជអាជ្ញាពុំអាចធ្វើការចោទប្រកាន់បានទេ ឬ និយាយម្យ៉ាងទៀតថា ព្រះរាជអាជ្ញាពុំអាចធ្វើបណ្តឹងអាជ្ញាបានឡើយ។ អាជ្ញាយុកាលអាចប្រែប្រួលទៅតាមប្រភេទនីមួយៗនៃបទល្មើស។ចិរវេលានៃអាជ្ញាយុកាលនៃបណ្តឹងអាជ្ញា[26] មានដូចខាងក្រោម៖

- ១៥ឆ្នាំ ចំពោះបទឧក្រិដ្ឋ
- ៥ឆ្នាំ ចំពោះបទមជ្ឈិម
- ១ឆ្នាំ ចំពោះបទលហុ

ជាគោលការណ៍ អាជ្ញាយុកាលនៃបទល្មើសចាប់ផ្តើមរាប់ពីពេលប្រព្រឹត្តបទល្មើសតទៅ។

**២. អាជ្ញាយុកាលនៃទោស** ជារយពេលមួយកំណត់ដោយច្បាប់ដែលផុតរយៈពេលនេះទោសមិនអាចយកទៅអនុវត្តបានទៀតឡើយ។ រយៈពេលអាជ្ញាយុកាលនៃទោស[27] រួមមានដូចខាងក្រោម៖

[26] មាត្រា១០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ លេខ នស/រកម/០៨០៧/០២៤ ១០ សីហា ២០០៧

[27] មាត្រា១៤៤ នៃក្រមព្រហ្មទណ្ឌ លេខ នស/រកម/១១០៩/០២២ ៣០ វិច្ឆិកា ២០០៩

- ទោសដែលប្រកាសពីបទឧក្រិដ្ឋមានអាជ្ញាយុកាល២០ឆ្នាំ។
- ទោសដែលប្រកាសពីបទមជ្ឈិមមានអាជ្ញាយុកាល៥ឆ្នាំ។
- ទោសដែលប្រកាសពីបទលហុមានអាជ្ញាយុកាល១ឆ្នាំ។

**ខ. ផលប្រយោជន៍ទាក់ទងនឹងការអនុវត្តនីតិវិធី**

នៅក្នុងការអនុវត្តនីតិវិធីព្រហ្មទណ្ឌ អ្នកនីតិបញ្ញត្តិខ្មែរបានកំណត់យ៉ាងច្បាស់លាស់នូវគោលការណ៍មួយចំនួន ដោយផ្អែកទៅលើប្រភេទនៃបទល្មើសជាបទឧក្រិដ្ឋ បទមជ្ឈិម ឬបទលហុ។ **ឧទាហរណ៍៖** ក្នុងករណីដែលអំពើមួយជាបទឧក្រិដ្ឋត្រូវបានបង្កឡើង ព្រះរាជអាជ្ញាត្រូវតែបើកការស៊ើបសួរដោយធ្វើដីការសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ។[28] បទមជ្ឈិមព្រះរាជអាជ្ញាមាន សិទ្ធិជ្រើសរើសក្នុងការបើកការស៊ើបសួរ ឬបញ្ជូនទៅជំនុំជម្រះផ្ទាល់ ឬក៏ប្រើប្រាស់នីតិវិធីនៃការបង្ហាញខ្លួនភ្លាម។ ប្រសិនបើជាបទលហុវិញនោះ ព្រះរាជអាជ្ញាត្រូវកោះហៅជនជាប់ចោទឱ្យចូលខ្លួនទៅចំពោះមុខតុលាការជំនុំជម្រះដោយផ្ទាល់។[29]

**គ. ផលប្រយោជន៍ទាក់ទងនឹងការកំណត់បទល្មើសប៉ុនប៉ង**

មាត្រា២៧ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩ បានចែងថា ការប៉ុនប៉ងក្នុងបទឧក្រិដ្ឋ ឬក្នុងករណីដែលច្បាប់បានចែងទុកក្នុងបទមជ្ឈិម អាចត្រូវផ្តន្ទាទោសបាន កាលណាលក្ខខណ្ឌខាងក្រោមនេះត្រូវបានបំពេញ៖

- ចារីបានចាប់ផ្តើមអនុវត្តបទល្មើស មានន័យថា ចារីបានប្រព្រឹត្តអំពើដែលមានគោលបំណងដោយផ្ទាល់ដើម្បីប្រព្រឹត្តបទល្មើស និង
- ចារីមិនបានបញ្ឈប់អំពើរបស់ខ្លួនទៅវិញដោយស្ម័គ្រចិត្ត តែត្រូវបានរាំងស្ទះ ឬអាក់ខាន ដោយឥទ្ធិពលនៃកាលទេសក្រៅឆន្ទៈរបស់ខ្លួន។ អំពើត្រៀមបម្រុងដែលពុំមានគោលបំណងដោយផ្ទាល់ ដើម្បីប្រព្រឹត្តបទល្មើសមិនមែនជាការចាប់ផ្តើមអនុវត្តទេ។

ការប៉ុនប៉ងក្នុងបទលហុ ពុំទទួលការផ្តន្ទាទោសទេ។[30]

**ឃ. ផលប្រយោជន៍ទាក់ទងនឹងការកំណត់ការផ្តើមគំនិត និងការសមគំនិត**

មាត្រា២៨ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩ ត្រូវចាត់ទុកជាអ្នកផ្តើមគំនិតក្នុងបទឧក្រិដ្ឋ ឬ បទមជ្ឈិម ចំពោះបុគ្គលណាដែល៖

- ជំរុញឲ្យប្រព្រឹត្តបទឧក្រិដ្ឋ ឬ បទមជ្ឈិមនោះតាមការណែនាំ ឬ ការបញ្ជា។

---

[28] មាត្រា៨៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ លេខ នស/រកម/០៨០៧/០២៤ ១០ សីហា ២០០៧

[29] មាត្រា៨៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ លេខ នស/រកម/០៨០៧/០២៤ ១០ សីហា ២០០៧

[30] មាត្រា២៧ នៃក្រមព្រហ្មទណ្ឌ លេខ នស/រកម/១១០៩/០២២ ៣០ វិច្ឆិកា ២០០៩

• បង្កឲ្យមានបទឧក្រិដ្ឋ ឬ បទមជ្ឈិមនោះ ដោយផ្តល់អំណោយ ដោយការសន្យា ឬ ការគំរាមកំហែង ការញុះញុង ការលួងលោម ឬ ក៏ដោយការរំលោភអាជ្ញា ឬ អំណាចរបស់ខ្លួន។ អ្នកផ្តើមគំនិតនឹងអាចត្រូវផ្តន្ទាទោសបានលុះត្រាតែបទឧក្រិដ្ឋ ឬបទមជ្ឈិមត្រូវបានសម្រេច ឬបានប៉ុនប៉ង។ អ្នកផ្តើមគំនិតនៃបទឧក្រិដ្ឋ ឬបទមជ្ឈិមត្រូវផ្តន្ទាទោសដូចគ្នានឹងចារីដែរ។[31] ហើយមួយវិញទៀតត្រូវចាត់ទុកជាអ្នកសមគំនិតក្នុងបទឧក្រិដ្ឋ ឬ បទមមជ្ឈិម ចំពោះបុគ្គលណាដែលជួយសម្រួលដោយចេតនា ដល់ការប៉ុនប៉ង ឬ ការសម្រេចបទឧក្រិដ្ឋ ឬបទមជ្ឈិមនោះ ដោយផ្តល់ជំនួយ ឬការឧបត្ថម្ភរបស់ខ្លួន។

អ្នកសមគំនិតនឹងអាចត្រូវផ្តន្ទាទោសបានលុះត្រាតែបទឧក្រិដ្ឋ ឬបទមជ្ឈិមត្រូវបានសម្រេច ឬបានប៉ុនប៉ង។ អ្នកសមគំនិតនៃបទឧក្រិដ្ឋ ឬបទមជ្ឈិម ត្រូវផ្តន្ទាទោសដូចគ្នានឹងចារីដែរ។[32]

## ២.២ ចំណាត់ថ្នាក់បទល្មើសផ្អែកលើធាតុសត្យានុម័ត

### ២.២.១ ចំណាត់ថ្នាក់នៅតាមប្រភេទនៃអំពើសម្ភារៈ

ប្រភេទនៃអំពើជាសម្ភារៈនៃបទល្មើសមួយអាចជាការប្រព្រឹត្តសកម្មភាពណាមួយឬ ការមិនប្រព្រឹត្តសកម្មភាពណាមួយ។ ប្រសិនបើអំពើជាសម្ភារៈការប្រព្រឹត្តសកម្មភាពបទល្មើសនោះ គឺមានឈ្មោះថាជាបទល្មើសសកម្ម ។

ផ្ទុយទៅវិញប្រសិនបើអំពើជាសម្ភារៈជាការមិនប្រព្រឹត្តសកម្មភាព ឬអនុប្បវាទបទល្មើសនោះ គឺមានឈ្មោះថា បទល្មើសអកម្ម។

**ក. សកម្មភាពក្នុងការប្រព្រឹត្តបទល្មើសសកម្ម**

បទល្មើសសកម្ម គឺជាអំពើសម្ភារៈ ឬ ជាសត្យានុម័តរបស់បទល្មើសអាចជាសកម្មភាពពោលគឺជាអំពើវិជ្ជមានមានន័យថាចារីនៃបទល្មើសបានប្រព្រឹត្តទង្វើណាមួយដែលច្បាប់បានហាមឃាត់។

ឧទាហរណ៍៖

•អំពើជាសត្យានុម័តនៃអំពើលួច គឺជាអំពើដកហូតយកនូវទ្រព្យសម្បត្តិរបស់អ្នកដទៃ។

•អំពើជាសត្យានុម័តនៃបទប្រទូសកេរ្តិ៍ខ្មាស គឺជាអំពើប៉ះពាល់ស្វាបអង្អែលកេរ្តិ៍ភេទ ឬ ផ្នែកភេទផ្សេងទៀតរបស់អ្នកដទៃ។

**ខ. សកម្មភាពក្នុងការប្រព្រឹត្តបទល្មើសអកម្ម**

បទល្មើសអកម្ម គឺជាបទលល្មើសដែលកើតចេញ ពីការបំពានកាតព្វកិច្ចដែលច្បាប់តម្រូវដូចជាការបំពេញកិច្ចជាវិជ្ជមានមួយដូចជាៈ កាតព្វកិច្ចផ្តល់ព័ត៌មានអំពើបទល្មើស នឹងការដោះបន្ទុក និងបង្ហាញភស្តុតាង

[31] មាត្រា២៨ នៃក្រមព្រហ្មទណ្ឌ លេខ នស/រកម/១១០៩/០២២ ៣០ វិច្ឆិកា ២០០៩

[32] មាត្រា២៩ នៃក្រមព្រហ្មទណ្ឌ លេខ នស/រកម/១១០៩/០២២ ៣០ វិច្ឆិកា ២០០៩

ពីភាពស្លូតត្រង់របស់ជនដែលស្ថិតនៅក្នុងដំណាក់កាលនីតិវិធីតុលាការ។ មូលហេតុនៃការបង្កើតបទល្មើសអកម្មមានពីរយ៉ាងគឺ៖

•បង្កើតការសហការជាមួយអាជ្ញាធរមានសមត្ថកិច្ចនានាដើម្បីស្វែងរក និងបង្ក្រាបបទល្មើស។

•បង្កើតសាមគ្គីភាពក្នុងសង្គមក្នុងគោលដៅរួមចំណែករក្សាសន្តិភាពស្ងប់ស្ងាត់។

**ឧទាហរណ៍៖**

• មាត្រា៣២៦ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩ ចាត់ទុកជាបទល្មើសមិនព្រមប្រគល់អនីតិជនចំពោះអំពើប្រព្រឹត្តដោយគំនិតទុច្ចរិត ដែលមិនព្រមប្រគល់អនីតិជនឲ្យទៅបុគ្គលដែលមានសិទ្ធិទាមទារនោះ ហើយត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១ខែ ទៅ១ឆ្នាំ និងពិន័យជាប្រាក់ពី១សែនរៀលទៅ ២លានរៀល។

• មាត្រា៥២៩ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩ ចាត់ទុកបទល្មើសចំពោះការមិនប្តឹងបរិហាបទឧក្រិដ្ឋដោយចែងថាៈ រាល់បុគ្គលណាដែលបានដឹងពីបទឧក្រិដ្ឋដែលអាចនឹងបង្ការ ឬ បន្ថយអានុភាពរបស់បទល្មើសបាន ហើយមមិនប្តឹងបរិហាដល់អាជ្ញាធរតុលាការ ឬអាជ្ញាធរមានសមត្ថកិច្ចផ្សេងទៀត ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ខែ ទៅ១ឆ្នាំ និងពិន័យជាប្រាក់ពី១សែនរៀល ទៅ២លានរៀល។

## ២.៣ ចំណាត់ថ្នាក់ទៅតាមរយៈពេលប្រព្រឹត្តបទល្មើស

យោងតាមរយៈពេលដែលប្រើប្រាស់ដើម្បីប្រព្រឹត្តបទល្មើស យើងឃើញមានរូបភាពនៃបទល្មើស៣យ៉ាងគឺ៖ (១)បទល្មើសភ្លាមៗ (២)បទល្មើសបន្តរៀងហូរហែ នឹង(៣)បទល្មើសអូសបន្លាយ។

### ក.បទល្មើសភ្លាមៗ

បទល្មើសភ្លាមៗ គឺនៅពេលដែលបទល្មើសអាចសម្រេចបាន ក្នុងពេលតែមួយភ្លែតបាន មានន័យថាបទល្មើសដែលកើតឡើងក្នុងពេលតែមួយជាមួយនឹងអំពើប្រព្រឹត្ត គឺបទល្មើសនោះត្រូវចាត់ទុកថាជាបទល្មើសភ្លាមៗ។ ម៉្យាងទៀតថាការសម្រេច ការប្រមូលផ្តុំនូវធាតុផ្សំទាំងអស់នៃបទល្មើសបានកើតឡើង
ភ្លាមៗ ហើយក៏បញ្ចប់ទៅវិញភ្លាមៗដែរ។

**ឧទាហរណ៍ ៖** បទដេញថ្លៃមិនត្រឹមត្រូវ បទឃាតកម្ម បទលួច បទហិង្សាដោយចេតនា។

### ខ.បទល្មើសបន្តរៀងហូរហែ

បទល្មើសបន្តរៀងហូរហែ គឺជាបទល្មើសដែលអំពើជាសម្ភារៈប្រព្រឹត្តឡើងបន្តគ្នាជាហូរហែ និងដោយស៊ីសង្វាក់គ្នានៅក្នុងពេលវេលា។

ដើម្បីចាត់ទុកថាបទល្មើសណាមួយជាបទល្មើសបន្តហូរហែ គេចាំបាច់ត្រូវពិនិត្យទៅលើសកម្មភាពដែលអ្នកនីតិបញ្ញត្តិចាត់ទុកជាបទល្មើស ពោលគឺត្រូវពិនិត្យមើលថា តើសកម្មភាពនោះកើតឡើងដោយទាមទារឲ្យ

មានរយៈពេលណាមួយ ឬក៏កើតឡើងភ្លាមៗ ។ ប្រសិនបើសកម្មភាពនោះ កើតឡើងដោយទាមទារឲ្យមានរយៈពេលណាមួយនោះគឺជាបទល្មើសបន្តរៀងហូរហែ។

ឧទាហរណ៍៖

•បទទទួលផលចោរកម្មត្រូវបានបង្កើតឡើងចាប់ពីពេលដែលបុគ្គលម្នាក់ទទួលទិញវត្ថុណាមួយដោយដឹងជាក់ច្បាស់ថាវត្ថុនោះបានមកដោយសារតែការ ប្រព្រឹត្តបទល្មើស(ដូចជាអំពើលួចជាដើម)។ ដរាបណាជនទទួលផលចោរកម្មបន្តកាន់កាប់វត្ថុទិញនោះទៀត បទល្មើសត្រូវចាត់ទុកថានៅតែបន្តប្រព្រឹត្តទៅទៀតពុំទាន់បានចប់សព្វគ្រប់នៅឡើយ។

•បទចតពាក្យសំដីឯកជនគឺជាបទល្មើសបន្តរៀងហូរហែ ពីព្រោះថាការចតពាក្យសំដីរបស់អ្នកដទៃតែងតែធ្វើឡើងនៅក្នុង រយៈពេលណាមួយជាកំណត់ហើយរយៈពេលនេះអាចខ្លីឬ ក៏វែងទៅតាមករណីនីមួយៗ(អាចជារយៈពេល១នាទី ឬ១ម៉ោង ឬ១ខែជាដើម)។

**គ.បទល្មើសអូសបន្លាយ**

បទល្មើសអូសបន្លាយ គឺជាបទល្មើសដែលអំពើបង្កគ្រោះថ្នាក់ដល់សង្គមស្តែងឡើងជាប់ជាហូរហែគ្មានអាក់ខានក្នុងរយៈពេលណាមួយឡើយ។ ម្យ៉ាងទៀត បទល្មើសអូសបន្លាយ សំដៅលើបទល្មើសដែលបង្កើតឡើងដោយបណ្តាអំពើជាច្រើនប្រហាក់ប្រហែលគ្នា ដោយអំពើនីមួយៗក៏ត្រូវចាត់ទុកថាជាបទល្មើសព្រហ្មទណ្ឌដែរក៏ប៉ុន្តែដោយសារតែឯកភាពនៃសេចក្តីសម្រេចចិត្ត(គោលដៅរបស់ជនល្មើស) និងភាពដូចគ្នានៃច្បាប់ដែលជនល្មើសបានបំពានអំពើច្រើនប្រហាក់ប្រហែលគ្នានោះគួរតែចាត់ទុកថាជាបទល្មើសតែមួយប៉ុណ្ណោះ។

**ឧទាហរណ៍:** បទរំលោភលើភាពល្ងង់ខ្លៅ ឬភាពទន់ខ្សោយ ការកាន់កាប់អាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទដោយគ្មានការអនុញ្ញាត។

## ៣.៤ចំណាត់ថ្នាក់ផ្អែកទៅលើមេបបទជាអត្តនោម័តនៃការប្រព្រឹត្តបទល្មើស

ជាគោលការណ៍ពុំមានបទល្មើសទេ ប្រសិនបើគ្មានចេតនាប្រព្រឹត្ត។ ប៉ុន្តែក្នុងករណីដែលច្បាប់បានចែងទុកជាមុន បទល្មើសមួយអាចកើតចេញពីការមិនប្រុងប្រយ័ត្ន ការខ្ជីខ្ជា ការធ្វេសប្រហែស ឬ ការមិនគោរពកាតព្វកិច្ចដោយឡែកណាមួយ។

**ក. ចេតនាក្នុងការប្រព្រឹត្តបទល្មើស(ការមិនរាងចាល)**

ការមិនរាងចាលត្រូវបាន កំណត់ក្នុងក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ដោយក្នុងនោះសញ្ញាណជារួមនៃការមិនរាងចាល សំដៅទៅលើស្ថានភាពដែលបុគ្គលម្នាក់បានប្រព្រឹត្តបទឧក្រិដ្ឋ ឬមជ្ឈិម និងត្រូវបានផ្តន្ទាទោសជាស្ថាពរ ហើយគាត់បានប្រព្រឹត្តបទឧក្រិដ្ឋ ឬមជ្ឈិមទៀត នៅក្នុងរយៈពេលមួយដែលក្រមព្រហ្មទណ្ឌបានកំណត់។

ពាក្យថាផ្តន្ទាទោសស្ថាពរត្រង់ចំណុចនេះ គឺទាល់តែសេចក្តីសម្រេចផ្តន្ទាទោសនោះ មិនអាចមានផ្លូវតវ៉ាទៀត។

**ក.១ អានុភាពនៃការមិនរាងចាល**

ការមិនរាងចាលមានអានុភាព នាំឱ្យមានការបន្ថែមទម្ងន់អតិបរមា នៃ ទោសដាក់ពន្ធនាគារចំពោះបទល្មើសឧក្រិដ្ឋ ឬមជ្ឈិម នៅក្នុង លក្ខខណ្ឌដែលមានចែងដោយកថាភាគនេះ ។[33]

**ក.២ លក្ខខណ្ឌនៃការមិនរាងចាល**

ការមិនរាងចាលត្រូវបានកើតក្នុងករណីណាមួយដូចតទៅ ៖

•កាលបើបុគ្គលណាម្នាក់ ដែលត្រូវបានផ្តន្ទាទោសជាស្ថាពររួច ហើយពីបទឧក្រិដ្ឋ បុគ្គលនោះបានប្រព្រឹត្តបទឧក្រិដ្ឋថ្មីទៀតនៅក្នុង រយៈពេល ១០ (ដប់) ឆ្នាំ ។ ប្រសិនបើអតិបរមានៃទោសពន្ធនាគារនៃបទឧក្រិដ្ឋថ្មីមិនលើសពី ២០ (ម្ភៃ) ឆ្នាំទេ អតិបរមានេះត្រូវឡើងទ្វេរដង តែបើមានរយៈពេល៣០ (សាមសិប) ឆ្នាំ អតិបរមានៃទោសគឺ ដាក់ពន្ធនាគារអស់មួយជីវិត។

•កាលបើបុគ្គលណាម្នាក់ ដែលត្រូវបានផ្តន្ទាទោសជាស្ថាពររួច ហើយពីបទឧក្រិដ្ឋ បុគ្គលនោះបានប្រព្រឹត្តបទមជ្ឈិមក្នុងរយៈពេល ៥ (ប្រាំ) ឆ្នាំ ។ ចំពោះករណីនេះអតិបរមានៃទោសពន្ធនាគារ ចំពោះបទមជ្ឈិមត្រូវកើនឡើងទ្វេដង។

•កាលបើបុគ្គលណាម្នាក់ ដែលត្រូវបានផ្តន្ទាទោសជាស្ថាពររួច ហើយពីបទមជ្ឈិម ដោយត្រូវជាប់ពន្ធនាគារស្មើ ឬលើសពី ៣ (បី) ឆ្នាំ បុគ្គលនោះបានប្រព្រឹត្តបទឧក្រិដ្ឋក្នុងរយៈពេល ៥ (ប្រាំ) ឆ្នាំ ។ ប្រសិនបើអតិបរមានៃទោសពន្ធនាគារនៃបទឧក្រិដ្ឋថ្មីមិនលើសពី ២០ (ម្ភៃ) ឆ្នាំទេ អតិបរមានេះត្រូវឡើងទ្វេដង តែបើមានរយៈពេល ៣០ (សាមសិប) ឆ្នាំ អតិបរមានៃទោសគឺ ដាក់ពន្ធនាគារអស់មួយជីវិត។

•កាលបើបុគ្គលណាម្នាក់ ដែលត្រូវបានផ្តន្ទាទោសជាស្ថាពររួច ហើយពីបទមជ្ឈិម បុគ្គលនោះបានប្រព្រឹត្តបទមជ្ឈិមដដែលនៅក្នុង រយៈពេល ៥ (ប្រាំ) ឆ្នាំ ។ ចំពោះករណីនេះ អតិបរមានៃទោសពន្ធនាគារចំពោះបទមជ្ឈិមត្រូវកើនឡើងទ្វេដង។

រយៈពេល ១០ (ដប់) ឆ្នាំ និង ៥ (ប្រាំ) ឆ្នាំចាប់ផ្តើមគិតពីថ្ងៃដែល សេចក្តីសម្រេចផ្តន្ទាទោសចំពោះបទល្មើសទី ១ ចូលជាស្ថាពរ ។[34]

ក្នុងការកំណត់ឲ្យបានថាជាអំពើមិនរាងចាល គេបានបង្កើតឲ្យមានបញ្ជីថ្កោលទោស ដែលជាប្រភពព័ត៌មានដ៏សំខាន់ក្នុងការបង្ហាញអំពីសញ្ញាណអំពីបទល្មើសដែលត្រូវផ្តន្ទាទោស ក៏ដូចជារយៈពេលផ្តន្ទាទោស

[33] មាត្រា៨៣ នៃក្រមព្រហ្មទណ្ឌ លេខ នស/រកម/១១០៩/០២២ ៣០ វិច្ឆិកា ២០០៩

[34] មាត្រា៨៤ នៃក្រមព្រហ្មទណ្ឌ លេខ នស/រកម/១១០៩/០២២ ៣០ វិច្ឆិកា ២០០៩

ជាដើម។ ការណ៍នេះធ្វើឲ្យតុលាការមានភាពងាយស្រួលក្នុងការកំណត់អំពីសញ្ញាណនៃបទល្មើសនីមួយៗ ថាតើជាលក្ខខណ្ឌនៃការមិនរាងចាល ឬក៏អត់។

ការមិនរាងចាលជាវិធានព្រហ្មទណ្ឌមួយដ៏សំខាន់ សម្រាប់ទប់ស្កាត់កុំឲ្យបទល្មើសព្រហ្មទណ្ឌកើតមានជាថ្មី តាមរយៈការបន្ថែមទម្ងន់ទោសទៅលើបទល្មើសថ្មី ប្រសិនបើការប្រព្រឹត្តនោះចូលក្នុងលក្ខខណ្ឌនៃការមិនរាងចាល។ ចំណុចនេះគឺជាការគោលការណ៍ដ៏សំខាន់ដើម្បីកាត់បន្ថយបទល្មើស ក៏ដូចជាក្រើនរំលឹកដល់បុគ្គលគ្រប់រូបឲ្យមានការប្រុងប្រយ័ត្នចំពោះអំពើដែលខ្លួនបានប្រព្រឹត្ត។ ម្យ៉ាងវិញទៀតចំពោះបុគ្គលដែលបានផ្តន្ទាទោសពីតុលាការរួចមកហើយ ជឿជាក់ថាលក្ខខណ្ឌនៃការមិនរាងចាលអាចធ្វើឲ្យបុគ្គលនោះ ហាក់មានការខ្លាចរអា ក៏ដូចជាមានការប្រយ័ត្ន មិនឲ្យមានបទល្មើសថ្មីកើតឡើងទៀតឡើយ។

### ក.៣ ការប្រដូចបទល្មើស ដើម្បីបង្កើតឲ្យមានការមិនរាងចាល

ដើម្បីអនុវត្តបទប្បញ្ញត្តិស្តីពីការមិនរាងចាល បទលួច បទរំលោភ លើទំនុកចិត្ត និងបទឆបោក ត្រូវចាត់ទុកថាជាបទល្មើសដូចគ្នា ដដែល ។ បទល្មើសទទួលផលចោរកម្ម ត្រូវប្រដូចជាបទល្មើសដែលជា ប្រភពនៃទ្រព្យ សម្បត្តិដែលទទួលលាក់បំបាំង ។ បទល្មើសសំអាតប្រាក់ ត្រូវប្រដូចជាបទល្មើសដែលការសំអាត ប្រាក់នេះបានសម្រេច ។[35]

ការមិនរាងចាល និងកិច្ចនៃការចោទប្រកាន់ គឺជាការមិនរាងចាលអាចត្រូវតុលាការជំនុំជម្រះកត់ត្រាទុក និងអាចជា មូលហេតុ នៃការបន្ថែមទម្ងន់ទោសដាក់ពន្ធនាគារបាន ប្រសិន បើមានចែងយ៉ាងជាក់លាក់ នៅក្នុងលិខិតចោទប្រកាន់ ។[36]

ការមិនរាងចាល និងសេចក្តីសម្រេចស្ថាពរ គឺជាសេចក្តីសម្រេចត្រូវបានចាត់ទុកថាជាស្ថាពរ កាលណាសេចក្តីសម្រេចនេះ មិនអាចមានផ្លូវតវ៉ាបានទៀតឡើយ ។

ដើម្បីអនុវត្តបទប្បញ្ញត្តិស្តីពីការមិនរាងចាល ត្រូវគិតគូរតែលើការ ផ្តន្ទាទោសស្ថាពរខាងបណ្តឹងអាជ្ញាប៉ុណ្ណោះ ។[37]

ការមិនរាងចាលអាចត្រូវកត់ត្រាទុក ទោះបីទោសដែលកើតចេញ ពីការផ្តន្ទាទោសនោះត្រូវផុតអាជ្ញាយុកាលក៏ដោយ ។

[35] មាត្រា៨៩ នៃក្រមព្រហ្មទណ្ឌ លេខ នស/រកម/១១០៩/០២២ ៣០ វិច្ឆិកា ២០០៩

[36] មាត្រា៩០ នៃក្រមព្រហ្មទណ្ឌ លេខ នស/រកម/១១០៩/០២២ ៣០ វិច្ឆិកា ២០០៩

[37] មាត្រា៩១ នៃក្រមព្រហ្មទណ្ឌ លេខ នស/រកម/១១០៩/០២២ ៣០ វិច្ឆិកា ២០០៩

ការមិនរាងចាល មិនអាចត្រូវកត់ត្រាទុកទេ បើទោសដែលកើតចេញ ពីការផ្តន្ទាទោសស្ថាពរនោះ ត្រូវបានលើកលែងដោយអនុលោម តាមមាត្រា៩០ថ្មី(ពីរ) វាក្យខណ្ឌទី ៤ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ។[38]

**ខ. អចេតនាក្នុងការប្រព្រឹត្តបទល្មើស**

គឺជាបទល្មើសដែលបានកើតឡើងទោះបីជាចារីពុំមានបំណងប្រព្រឹត្តក៏ដោយ។ ម្យ៉ាងវិញទៀត ចំពោះបទល្មើសដោយអចេតនា ភាពសុចរិតរបស់ចារីពុំមែនជាធាតុផ្សំបទល្មើសទេ បានសេចក្តីថា ទោះបីជាចារីពុំមានបំណងទុច្ចរិតក៏ដោយ ក៏នៅតែមានបទល្មើសបានកើតឡើងដដែល។

**ឧទាហរណ៍៖** បទមនុស្សឃាតដោយអចេតនា ការបើកបរដោយបង្កឱ្យស្លាប់ដល់អ្នកដទៃដោយអចេតនា ការបើកបរបង្កឱ្យមានរបួសដល់អ្នកដទៃដោយអចេតនា ។ មួយវិញទៀត ក្រមព្រហ្មទណ្ឌមិនត្រឹមតែ ដាក់ទោសលើការប្រព្រឹត្តបទល្មើសបានសម្រេចផលនោះទេ គឺថែមទាំងបានដាក់ទោសលើការប៉ុនប៉ងប្រព្រឹត្តបទល្មើសផងដែរ កាលបើលក្ខខណ្ឌនៃការប៉ុងប៉ងមានទោសត្រូវបានបំពេញយ៉ាងគ្រប់គ្រាន់។

[38] មាត្រា៩២ នៃក្រមព្រហ្មទណ្ឌ លេខ នស/រកម/១១០៩/០២២ ៣០ វិច្ឆិកា ២០០៩

# ជំពូកទី៤
# ប្រភេទនៃបទល្មើសព្រហ្មទណ្ឌ

# ជំពូកទី៣
# ប្រភេទនៃបទល្មើសព្រហ្មទណ្ឌ
## ៣.១បទល្មើសសំខាន់ៗដែលមានចែងក្នុងក្រមព្រហ្មទណ្ឌ
### ៣.១.១ការប៉ះពាល់ដល់ជីវិតមនុស្ស
#### ក. បទឃាតកម្ម

ឃាតកម្មគឺ បទល្មើសដែលប៉ះពាល់ដល់ជីវិតមនុស្ស ។ គឺជាអំពើសម្លាប់មនុស្សដោយចេតនា ដោយប្រើអាវុធ ឬមិនប្រើអាវុធដោយគ្មានស្ថានទម្ងន់ណាមួយដូចបានកំណត់ក្នុងក្រមព្រហ្មទណ្ឌ។ បទឃាតកម្មគឺជាបទឧក្រិដ្ឋត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១០ឆ្នាំ ទៅ១៥ឆ្នាំ។[39]

- ចេតនា

ជនល្មើសមានចេតនាចង់ឲ្យមនុស្សម្នាក់ ឬច្រើននាក់ស្លាប់តាមបំណងរបស់ខ្លួនដោយប្រើប្រាស់គ្រប់មធ្យោបាយគ្រប់ប្រភេទ។ ជនល្មើសប្រព្រឹត្តអំពើនេះដោយ ប្រើប្រាស់អាវុធ ឬមិនប្រើអាវុធ ប្រើថ្នាំបំពុល ឬពួនស្ទាក់ ។

**ឧទាហរណ៍៖** បទឃាតកម្មគិតទុកជាមុន អំពើសម្លាប់មនុស្សដោយគិតទុកជាមុន ឬដោយការពួនស្ទាក់។ ការគិតទុកជាមុន គឺជាគម្រោងដែលបង្កើតឡើងមិនអំពើបៀតបៀនទៅលើរូបបុគ្គលនៃជនរងគ្រោះ។ ការពួនស្ទាក់ គឺជាអំពើឃ្លាំចាំបុគ្គលណាម្នាក់ក្នុងរយៈពេលមួយរយៈដើម្បីប្រព្រឹត្តអំពើ បៀតបៀនទៅលើរូបបុគ្គលនៃជនរងគ្រោះ។ ឃាតកម្មគិតទុកជាមុនត្រូវផ្តន្ទាទោសដាក់ពន្ធនាគារអស់មួយជីវិត(មាត្រា២០០ នៃក្រមព្រហ្មទណ្ឌ)។

#### ខ.បទមនុស្សឃាតដោយអចេតនា

បទមនុស្សឃាតដោយអចេតនា គឺជាអំពើបណ្តាលឲ្យស្លាប់អ្នកដទៃដោយ៖

- ការធ្វេសប្រហែស ការមិនប្រុងប្រយ័ត្ន ឬការខ្ជីខ្ជា។
- ការបំពាន់លើលកាតព្វកិច្ចសន្តិសុខ ឬកាតព្វកិច្ចប្រុងប្រយ័ត្នដែលច្បាប់តម្រូវ។

បទល្មើសនេះត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ឆ្នាំទៅ៣ឆ្នាំ និងពិន័យជាប្រាក់ពី២លានទៅ៦លានរៀល។[40]

ជនល្មើសមានចេតនាបានធ្វើឲ្យមានមនុស្សម្នាក់ ឬច្រើននាក់ស្លាប់ដោយចេតនាដោយសារ តែមានការធ្វេសប្រហែស ការមិនប្រុងប្រយ័ត្ន ឬការខ្ជីខ្ជារ នឹងអាចបណ្តាលឲ្យមានមនុស្សស្លាប់។ ហើយមានការបំពានលើ

[39] មាត្រា១៩៩ នៃក្រមព្រហ្មទណ្ឌ លេខ នស/រកម/១១០៩/០២២ ៣០ វិច្ឆិកា ២០០៩

[40] មាត្រា២០៧ នៃក្រមព្រហ្មទណ្ឌ លេខ នស/រកម/១១០៩/០២២ ៣០ វិច្ឆិកា ២០០៩

កាតព្វកិច្ចសន្តិសុខ ឬកាតព្វកិច្ចមិនប្រុងប្រយ័ត្ន ដែលបណ្តាលឲ្យច្បាប់កំណត់ឲ្យខ្លួនបំពេញតាម ដើម្បីធានានូវសន្តិសុខ សុវត្ថិភាពដល់សង្គម។

**ឧទាហរណ៍:** យោធិនម្នាក់បានធ្វើឲ្យកាំភ្លើងរបស់ខ្លួនធ្លាក់ហើយបណ្តាលឲ្យផ្ទុះគ្រាប់ទៅត្រូវលើជននម្នាក់ទៀតស្លាប់បាត់បង់ជីវិតទៅ។

ប្រសិនបើការបង្កឲ្យស្លាប់អ្នកដទៃដោយចេតនា កើតឡើងដោយសារការបើកបរយានយន្តតាមដងផ្លូវសាធារណៈអំពើនេះក៏ចាត់ទុកជាបទល្មើសដែរដោយយោងតាមមាត្រា ៨២ នៃ ច្បាប់ស្តីពីចរាចរណ៍ផ្លូវគោលកំណត់ទណ្ឌកម្មដូចគ្នានឹងមាត្រា២០៧ នៃក្រមព្រហ្មទណ្ឌដែរ។

### ៣.១.២ ការប៉ះពាល់ដល់បូរណភាពនៃបុគ្គល

#### ក. បទទារុណកម្ម នឹងអំពើឃោរឃៅ

បទទារុណកម្ម នឹងអំពើឃោរឃៅ គឺគ្រប់អំពើធ្វើបាប ឬទារុណកម្មទៅលើរាងកាយរបស់អ្នកដទៃយ៉ាងកាចសាហាដោយគ្មានមនុស្សធម៌ តាមគ្រប់មធ្យោបាយ នឹងគ្រប់រូបភាព។ ការធ្វើទារុណកម្មក្នុងមាត្រានេះ មិនសំដៅទៅលើការធ្វើទារុណកម្មផ្នែកស្មារតីទេ គឺសំដៅទៅលើរាងកាយ។ យោងតាមមាត្រា២១០ នៃក្រមព្រហ្មទណ្ឌចាត់ទុកអំពើទារុណកម្ម និងអំពើឃោរឃៅជាបទល្មើសដោយឡែក ហើយត្រូវផ្តន្ទាទោសពី ៧ឆ្នាំទៅ១៥ឆ្នាំ ។ ក្រៅពីនេះប្រសិនបើការធ្វើទារុណកម្ម និងអំពើឃោរឃៅធ្វើឡើងដោយមានស្ថានទម្ងន់ទោសដូចមានចែងនៅមាត្រា២១២ ដល់មាត្រា២១៤ នៃក្រមព្រហ្មទណ្ឌការផ្តន្ទាទោសដាក់ពន្ធនាគារពី ១០ឆ្នាំទៅ២០ឆ្នាំ។

**ឧទាហរណ៍:** ចាប់មនុស្សយកមកចងរួចដាក់ឲ្យសម្រោចខាំ។ ចាប់មនុស្សមករួចយកកាំបិតអារសាច់ហើយក៏យកទឹកត្រីមកជះលើខ្លួន។

#### ខ. បទហិង្សាដោយចេតនា

បទហិង្សាដោយចេតនា គឺជាអំពើហិង្សាប្រព្រឹត្តដោយចេតនាលើអ្នកដទៃ ឬអំពើយាយី ឬបៀតបៀនលើរូបរណភាពរូបកាយរបស់អ្នកដទៃដោយចេតនាតាមគ្រប់មធ្យោបាយ បណ្តាលឲ្យមានរបួសឬគ្មានរបួស ឬខូចសុខភាព។ ហើយជនល្មើសមានចេតនាធ្វើឲ្យជនរងគ្រោះរងការឈឺចាប់លើរាងកាយ ឬសុខភាព។ យោងតាមមាត្រា២១៧ នៃក្រមព្រហ្មទណ្ឌ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ទៅ៣ឆ្នាំ និងពិន័យជាប្រាក់ពី ២លានរៀល ទៅ៦លានរៀល។

**ឧទាហរណ៍:** នៅក្នុងពិធីបុណ្យខួបកំណើតមួយម្ចាស់ផ្ទះបានរៀបចំឲ្យមានការរាំកំសាន្តនៅមុខផ្ទះរបស់ខ្លួន។ នៅពេលកំពុងតែរាំលែងកំសាន្ត ក៏មានជម្លោះមួយកើតឡើងដោយសារតែមានការរាំជាន់ជើងគ្នា។ ខណៈនោះក្រុមជនល្មើសដែលមានគ្នាប្រមាណជា៥នាក់ បានព្រួតគ្នាវាយជនរងគ្រោះម្នាក់បណ្តាលឲ្យមានការរងរបួសធ្ងន់ធ្ងរ។ ក្នុងករណីនេះក្រុមជនល្មើសមានគ្នាច្រើនក្នុងឋានៈជាសហចារី។ ម៉្យាងវិញទៀត ស្ថានភាពរបស់ជនរងគ្រោះក៏

ត្រូវបានក្រមព្រហ្មទណ្ឌយកមកបញ្ញត្តិដើម្បីកំណត់ពីស្ថានទម្ងន់ទោសដែរ។ យោងតាមមាត្រា២១៩ នៃក្រមព្រហ្មទណ្ឌត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ឆ្នាំទៅ៥ឆ្នាំ និងពិន័យជាប្រាក់ពី ៤លានទៅ១០លានរៀល ។

**គ .បទគំរាមកំហែង**

បទគំរាមកំហែង នៅក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ចាត់ទុកជាបទល្មើសចំពោះគ្រប់រូបភាពនៃការគំរាមកំហែង។ ការគំរាមកំហែងថានឹងប្រព្រឹត្តបទឧក្រិដ្ឋ ឬបទមជ្ឈិមប្រឆាំងនិងបុគ្គល កាលបើការគំរាមកំហែងនេះធ្វើឡើងម្តងហើយម្តងទៀត ឬ សម្តែងចេញតាមលិខិត រូបភាព ឬ វត្ថុអ្វីមួយ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ខែទៅ ៦ខែ និងពិន័យជាប្រាក់ពី ១សែនទៅ ១លានរៀល (មាត្រា២៣១ នៃក្រមព្រហ្មទណ្ឌ)។

ចំពោះការគំរាមកំហែងដោយមានបញ្ជាឲ្យបំពេញលក្ខខណ្ឌអ្វីមួយ ទោះបីជាការគំរាមកំហែងក្រោមទម្រង់ណាមួយក៏ដោយ ថានឹងប្រព្រឹត្តបទឧក្រិដ្ឋ ឬបទមជ្ឈិម ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៦ខែ ទៅ២ឆ្នាំ នឹងពិន័យជាប្រាក់ពី ១លាន ទៅ៤លានរៀល (មាត្រា២៣២ នៃក្រមព្រហ្មទណ្ឌ)។

**ឧទាហរណ៍:**ការគំរាមថានឹងសម្លាប់នេះធ្វើឡើងដោយផ្ទាល់មាត់ម្តងហើយម្តងទៀតដោយគ្មានដាក់លក្ខខណ្ឌអ្វីទាំងអស់ (កុំសូវចេះដឹងរឿងគេពេកប្រយ័ត្នងាប់ ហើយប្រយ័ត្នលែងបានជួបមុខកូនទៀតទៅ)។ ការគំរាមកំហែងថានឹងសម្លាប់ដោយមានបញ្ជាឲ្យបំពេញលក្ខខណ្ឌអ្វីមួយក្រោមទម្រង់ណាមួយក៏ដោយ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ឆ្នាំ ទៅ៣ឆ្នាំ និងពិន័យជាប្រាក់ពី ២លាន ទៅ៦លានរៀល (មាត្រា២៣៤ នៃក្រមព្រហ្មទណ្ឌ)។

**ឃ. បទបង្កឲ្យមានរបួសដោយអចេតនា**

បទល្មើសបង្កឲ្យមានរបួសដោយអចេតនា គឺជាអំពើដែលបណ្តាលឲ្យមានដល់អ្នកដទៃដោយ៖

•ការធ្វេសប្រហែស ការមិនប្រុងប្រយ័ត្ន ឬ ការខ្ជីខ្ជាដែលបង្កឲ្យមានអសមត្ថភាពក្នុងការធ្វើការងារស្មើ ឬលើសពី៨ ថ្ងៃ។

•ការបំពានលើកាតព្វកិច្ចសន្តិសុខ ឬ កាតព្វកិច្ចប្រុងប្រយ័ត្នដែលច្បាប់តម្រូវ។[41]

បទបង្កឲ្យមានរបួសដោយអចេតនា ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៦ខែ ទៅ២ឆ្នាំ និងពិន័យជាប្រាក់ពី ១លាន ទៅ៤លានរៀល។

**ឧទាហរណ៍:**

- អ្នកបរបាញ់សត្វម្នាក់តម្រង់កាំបិតគប់ទៅលើសត្វមួយក្បាលតែបែរជាត្រូវមនុស្សម្នាក់ទៅវិញដែលកំពុងដើរឆ្លងកាត់ផ្លូវក្បែរនោះទៅវិញ។
- វេជ្ជបណ្ឌិតដែលធ្វើការវះកាត់បណ្តាលឲ្យអ្នកជម្ងឺពិការដោយសារតែមានការធ្វេសប្រហែលដែលមិនបានពិនិត្យអាការៈអ្នកជម្ងឺជាមុនឲ្យល្អិតល្អន់នោះទេ។

**៣.១.៣ ការបំពានខាងផ្លូវភេទ**

**ក. បទរំលោភសេពសន្ថវ:**

បទរំលោភសេពសន្ថវៈ គឺគ្រប់អំពើបញ្ចូលអង្គជាតិ តាមបែបណាក៏ដោយ ឬអំពើបញ្ចូលឧបករណ៍ណាមួយទៅក្នុងអង្គជាតិ ដែលប្រព្រឹត្តទៅលើអ្នកដទៃ ទោះបីជាភេទដូចគ្នា ឬមិនដូចគ្នាក៏ដោយ ដោយការប្រើហិង្សា ឬ

[41] មាត្រា២៣៦ នៃក្រមព្រហ្មទណ្ឌ លេខ នស/រកម/១១០៩/០២២ ៣០ វិច្ឆិកា ២០០៩

ការបង្ខិតបង្ខំ ការគំរាមកំហែង ឬការឆ្មក់ឱកាស ។ ត្រូវផ្តន្ទាទោសជនដែលប្រព្រឹត្តបទរំលោភសេពសន្ថវៈឲ្យជាប់ពន្ធនាគារពី ៥ឆ្នាំ ទៅ១០ឆ្នាំ។

នីតិភាពនៃការរួមភេទត្រូវបានកំណត់ចាប់ពីអាយុ១៥ឆ្នាំឡើងទៅ។[42]

ជនល្មើសបានប្រព្រឹត្តអំពើនេះដោយៈ ប្រើប្រាស់អាវុធ ឬមិនប្រើអាវុធ គំរាមកំហែងជនរងគ្រោះនឹងអាវុធ និង ប្រើគ្រឿងញៀន ឬប្រើគ្រប់វិធីដែលនាំឲ្យជនរងគ្រោះបាត់បង់ ឬចុះខ្សោយលទ្ធភាពទប់ទល់។ ក្នុងករណីខ្លះ បើសិនជាជនលល្មើស និងជនរងគ្រោះអាចនិងមានភេទដូចគ្នាឬ ភេទផ្ទុយគ្នាក៏ដោយ ទោះបីជាអំពើប្រព្រឹត្តតាមបែបបទ និងមធ្យោបាយណាក៏ដោយ នៅក្នុងអំពើរំលោភសេពសន្ថវៈ គឺមិនកើតមាននូវឆន្ទៈព្រមព្រៀងពីជនរងគ្រោះទេ។

**ឧទាហរណ៍ៈ**

នារីម្នាក់បានចេញពីធ្វើការវិញក៏ត្រឡប់ទៅផ្ទះវិញ ក៏ត្រូវបានបុរសម្នាក់ចាប់អូសចូលទីកន្លែងស្ងាត់ក្នុងគុម្ពោតព្រៃ ហើយចាប់បង្ខំនាងដើម្បីរួមភេទ ទោះបីជារូបនាងប្រកែក និងរើបំរះយ៉ាងណាក៏ដោយ។ ក្នុងករណីនេះជនល្មើសបានប្រព្រឹត្តបទរំលោភសេពសន្ថវៈ ដោយស្ថានទំនង់ទោសណាមួយដូចមានចែងពីមាត្រា ២៤០ ដល់មាត្រា២៤៤ នៃក្រមព្រហ្មទណ្ឌ ជនល្មើសនឹងត្រូវទទួលរងនូវការផ្តន្ទាទោសដាក់ពន្ធនាគារពី ៧ឆ្នាំដល់១៥ឆ្នាំ។ ស្ថានទម្ងន់នេះមានដូចតទៅៈ ការប្រើប្រាស់អាវុធ ឬគំរាមកំហែង និង អាវុធ។

ជនរងគ្រោះត្រូវបានចារីជាច្រើននាក់ចាប់រំលោភ។ ក្រោយពីរំលោភសេពសន្ថវៈរួចហើយ ចារីទាំងអស់បានចាកចេញពីកន្លែងនិងទៅ ហើយចំណែកឯនារីរងគ្រោះវិញក៏បានស្លាប់បាត់បង់ជីវិត ដោយសារតែពុំមានអ្នកមកជួយសង្គ្រោះនាងទាន់ពេលវេលា និងដោយសារតែនាងមានសុខភាពទន់ខ្សោយផងដែរ។ យោងតាមមាត្រា ២៤៤ នៃក្រមព្រហ្មទណ្ឌ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១៥ឆ្នាំដល់៣០ឆ្នាំ។

### ក.១ បទប្រទូស្តកេរខ្មាស

គ្រប់អំពើប៉ះពាល់ ស្ទាប អង្អែលកេរភេទ ឬផ្នែកភេទផ្សេងទៀតរបស់បុគ្គលដទៃ តែបុគ្គលនេះមិនស្ម័គ្រផងទេ ឬបង្ខំបុគ្គលដទៃឲ្យប្រព្រឹត្តអំពើនេះមកលើខ្លួន ឬ ទៅលើតតិយបុគ្គលក្នុងគោលបំណងធ្វើឲ្យរំជួល ឬ រីករាយដល់ចំណង់ផ្លូវភេទរបស់ជនល្មើស គឺជាអំពើប្រទូស្តកេរខ្មាស។[43] អំពើប្រទូស្តកេរខ្មាសត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ឆ្នាំ ទៅ៣ឆ្នាំ និងពិន័យជាប្រាក់ពី ២លានរៀល ទៅ៦លានរៀល។ ជាបទប្រទូស្តកេរខ្មាសចំពោះអំពើដូចតទៅៈជនល្មើសប៉ះពាល់ ស្ទាប អង្អែលកេរភេទ ឬ ផ្នែកភេទផ្សេងទៀតរបស់ជនរងគ្រោះ។

**ឧទាហរណ៍ៈ** ជនល្មើសបានយកដៃទៅស្ទាបអង្អែលសុដនរបស់នារីរងគ្រោះ។

ជនល្មើសចង្ខំឲ្យជនរងគ្រោះប៉ះពាល់ ស្ទាប អង្អែលកេរភេទ ឬផ្នែកភេទផ្សេងទៀតរបស់ខ្លួន។

**ឧទាហរណ៍ៈ** ជនល្មើសបានបង្ខំឲ្យនារីរងគ្រោះទៅស្ទាបសឹង្គរបស់ខ្លួន។

ជននល្មើសបង្ខំឲ្យជនរងគ្រោះប៉ះពាល់ ស្ទាប អង្អែលកេរភេទ ឬផ្នែកផ្សេងទៀតរបស់តតិយជន។

**ឧទាហរណ៍ៈ** ជនល្មើសបានបង្ខំឲ្យនារីរងគ្រោះស្ទាបលឹង្គរបស់ក្មេងប្រុសម្នាក់ទៀត។

---

[42] មាត្រា២៣៩ នៃក្រមព្រហ្មទណ្ឌ លេខ នស/រកម/១១០៩/០២២ ៣០ វិច្ឆិកា ២០០៩

[43] មាត្រា២៤៦ នៃក្រមព្រហ្មទណ្ឌ លេខ នស/រកម/១១០៩/០២២ ៣០ វិច្ឆិកា ២០០៩

ជនល្មើសធ្វើអំពើខាងលើនេះ ក្នុងគោលបំណងធ្វើឲ្យរំជួល ឬរីករាយដល់ចំណង់ផ្លូវភេទរបស់ខ្លួន ដោយជនរងគ្រោះមិនព្រមបានស្ម័គ្រចិត្តនិងធ្វើអំពើបែបនេះទេ។

ក្នុងករណីដែលជនរងគ្រោះព្រមធ្វើអំពើដូចខាងលើ ពុំមានបទល្មើសប្រទូស្តកេរខ្មាសកើតឡើយ។ ក៏ប៉ុន្តែប្រសិនបើជនរងគ្រោះមានអាយុក្រោម១៥ឆ្នាំទោះបីជាជនរងគ្រោះយល់ព្រម ក៏នឹងមានបទល្មើសកើតឡើងដដែល ដោយបទល្មើសនេះមានឈ្មោះថា អំពើអាសប្រឆាំងននឹងនីតិជនអាយុក្រោម១៥ឆ្នាំ មានចែងនៅមាត្រា៤៣ នៃច្បាប់ស្ដីពីការបង្រ្កាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ និងមាត្រា៣៤១ បទអាសប្រព្រឹត្តទៅលើអនីតិជនអាយុតិចជាង១៥ឆ្នាំ នៃក្រមព្រហ្មទណ្ឌ។

មាត្រា៣៤១ នៃក្រមព្រហ្មទណ្ឌចែងថាៈ អំពើអាស គឺជាអំពើនៃការប៉ះពាល់ ឬការបង្ហាញកេរភេទ ឬផ្នែកភេទផ្សេងទៀតរបស់ជនដទៃ ឬការឲ្យជនដទៃប៉ះពាល់កេរភេទ ឬ ផ្នែកផ្សេងទៀតរបស់ជនល្មើស។ ជនណាដែលប្រព្រឹត្តអំពើអាសទៅលើអនីតិជនអាយុក្រោម១៥ឆ្នាំ ត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី ១ឆ្នាំទៅ៣ឆ្នាំ និងពិន័យជាប្រាក់ពី ២លានទៅ៦លានរៀល។

**ក.២ បទបង្ហាញកេរភេទ**

អំពើបង្ហាញកេរភេទដែលនាំឲ្យអ្នកដទៃមើលឃើញ នៅក្នុងទីកន្លែងមួយដែលសាធារណៈអាចមើលឃើញត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី ៦ថ្ងៃទៅ៣ខែ និងពិន័យជាប្រាក់១សែនទៅ៥សែនរៀល ។[44]

**ឧទាហរណ៍ៈ** បុរសម្នាក់បានឈរស្រាតនៅមុខផ្ទះរបស់ខ្លួន នៅពេលស្រវឹង។

**ក.៣ បទរុករកួនខាងផ្លូវភេទ**

អំពើរុកកួនខាងផ្លូវភេទ គឺជាអំពើដែលបុគ្គលរំលោភអំណាចដែលមុខងាររបស់ខ្លួនប្រគល់ឲ្យ ធ្វើការគាបសង្កត់ម្ដងហើយម្ដងទៀតទៅលើអ្នកដទៃក្នុងគោលបំណងទទួលការអនុគ្រោះខាងផ្លូវភេទ។បទល្មើសនេះត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី ៦ថ្ងៃទៅ៣ខែ និងពិន័យជាប្រាក់ពី ១សែទៅ៥សែរៀល។[45]

**ឧទាហរណ៍ៈ** ប្រធានក្រុមហ៊ុនម្នាក់ប្រើប្រាស់ឋានៈរបស់ខ្លួនដើម្បីគាបសង្កត់ឲ្យលេខាស្រីរបស់ខ្លួនយល់ព្រមរួមភេទជាមួយនិងខ្លួន។ ការធ្វើអំពើគាបសង្កត់គ្រប់ប្រភេទម្ដងហើយម្ដងទៀត គឺជាបទរុកកួនខាងផ្លូវភេទ។

**ខ. បទល្មើសពាក់ព័ន្ធនឹងអំពើជួញដូរមនុស្សនឹងអំពើអាជីវកម្មផ្លូវភេទ**

**ខ.១ សញ្ហារកម្ម**

សញ្ហារកម្មគឺជាៈ

- អំពើទាញយកអត្ថប្រយោជន៍ហិរញ្ញវត្ថុពីអំពើពេស្យាចាររបស់អ្នកដទៃ។
- ជួយ ឬការពារអំពើពេស្យាចាររបស់អ្នកដទៃ ឬរៀបចំតាមគ្រប់មធ្យោបាយនូវសកម្មភាពពេស្យាចារ។
- ជ្រើសរើស ពង្រត់ ឬអូសទាញបុគ្គលណាមួយឲ្យធ្វើអំពើពេស្យាចារ។
- ធ្វើការគាបសង្កត់លើបុគ្គលណាមួយ ដើម្បីឲ្យបុគ្គលនោះធ្វើពេស្យាចារ។[46]

---

[44] មាត្រា២៤៩ នៃក្រមព្រហ្មទណ្ឌ លេខ នស/រកម/១១០៩/០២២ ៣០ វិច្ឆិកា ២០០៩

[45] មាត្រា២៥០ នៃក្រមព្រហ្មទណ្ឌ លេខ នស/រកម/១១០៩/០២២ ៣០ វិច្ឆិកា ២០០៩

[46] មាត្រា២៨៤ នៃក្រមព្រហ្មទណ្ឌ លេខ នស/រកម/១១០៩/០២២ ៣០ វិច្ឆិកា ២០០៩

**ឧទាហរណ៍:** សកម្មភាពរបស់មេបន។

បទល្មើសនេះត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី២ឆ្នាំទៅ៥ឆ្នាំ និងពិន័យជាប្រាក់ពី ៤លានទៅ១០លានរៀល។

ក្នុងករណីដែលមានស្ថានទំងន់ទោសដូចមានចែងក្នុងមាត្រា ២៨៨ ដល់មាត្រា ២៩០ ការផ្តន្ទាទោសនឹងធ្ងន់ធ្ងរជាងនេះ ។ **ឧទាហរណ៍៖** ដូចជាករណីដែលជនរងគ្រោះដែលធ្វើ ពេស្យាចារជាអនីតិជនទោសដែលត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៧ឆ្នាំទៅ១៥ឆ្នាំ។

ការជួយសម្រួល ឬបិទបាំងធនធានដែលខ្លួនបានដឹងថាបានមកពីអំពើសញ្ចារកម្ម ក៏ជា បទល្មើសព្រហ្មទណ្ឌដែរ ហើយត្រូវផ្តន្ទាទោសដាក់ពន្ធនាគារដូចអំពើសញ្ចារកម្មដែរ(មាត្រា២៨៦)។

ការរារាំងដល់ការបង្ការ ការជួយ ឬការអប់រំជាថ្មី ដោយសេវាសាធារណៈ ឬដោយ អង្គការឯកជនដែលមាននីតិសម្បទា ដែលធ្វើឡើងដើម្បីអនុគ្រោះដល់បុគ្គលដែលប្រព្រឹត្ត ពេស្យាចារ ឬកំពុងមានគ្រោះថ្នាក់ដោយការធ្វើពេស្យាចារ ក៏ត្រូវផ្តន្ទាទោសដូចគ្នានឹងបទ ល្មើសសញ្ចារកម្មដែរ (មាត្រា ២៨៧)។

### ខ.២ ការរួមភេទជាមួយអនីតិជនអាយុក្រោម១៥ឆ្នាំ

ការរួមភេទជាមួយអនីតិជនអាយុក្រោម១៥ឆ្នាំ គឺជាបទល្មើសដែលមានចែងនៅ មាត្រា ៤២ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ។ ទោះបីជាអនីតិជនអាយុក្រោម១៥ឆ្នាំ ស្ម័គ្រចិត្តរួមភេទជាមួយក៏ដោយ ក៏ជនដែលមានអាយុ ចាប់ពី១៥ឆ្នាំឡើងទៅដែលបានរួមភេទដោយស្ម័គ្រចិត្តជាមួយនឹងអនីតិជនអាយុក្រោម ១៥ឆ្នាំ ត្រូវផ្តន្ទាទោសតាមមាត្រា ៤២ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទដែរ។ បទល្មើសនេះត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ឆ្នាំទៅ១០ឆ្នាំ។[47]

អំពើរួមភេទអាចស្តែងចេញឡើងតាមរូបភាព ជាការបញ្ចូលកេរភេទបុរសទៅក្នុងកេរ ភេទ មាត់ ឬរន្ធគូថរបស់ស្ត្រី ឬជាការបញ្ចូលនូវឧបករណ៍ណាមួយក្នុងកេរភេទរបស់អ្នក ដទៃ ទោះបីជាមានភេទដូចគ្នា ឬមិនដូចគ្នាក៏ដោយ។ ឧទាហរណ៍: ការដែលជនល្មើសឲ្យជនរងគ្រោះបៀមលឹង្គរបស់ខ្លួន ការរួមភេទតាមរន្ធគូថ ការយកលឹង្គសិប្បនិម្មិត ដាក់ចូលក្នុងកេរភេទ។

ក្រមព្រហ្មទណ្ឌពុំបានបញ្ញត្តិបទល្មើសប្រភេទនេះទេ។ ប៉ុន្តែក្រមព្រហ្មទណ្ឌចាត់ ទុកថា នីតិភាពនៃការរួមភេទត្រូវបានកំណត់ចាប់ពីអាយុ ១៥ឆ្នាំ ឡើងទៅ (មាត្រា ២៣៩ កថាខណ្ឌទី៣ នៃក្រមព្រហ្ម)។ ចំណុចនេះមានន័យថាប្រសិនបើមានការរួមភេទជាមួយអនី តិជនអាយុក្រោម ១៥ឆ្នាំ គឺសន្មតថាអនីតិជននោះមិនមានសមត្ថភាពតាមផ្លូវច្បាប់ក្នុងការ ផ្តល់ការយល់ព្រមនឹងការរួមភេទទេបានសេចក្តីថាត្រូវទុកជាបទល្មើស រំលោភសេពសន្ថវៈ កាលបើមានធាតុផ្សំគ្រប់គ្រាន់។

### ខ.៣ ការទិញពេស្យាចារកុមារ

ការទិញពេស្យាចារកុមារត្រូវបានហាមឃាត់ដោយច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរ មនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ។ មាត្រា ៣៤ នៃច្បាប់នេះចែងថា: ជនណារួមភេទ ឬធ្វើ អំពីគ្រប់រូបភាពផ្សេងទៀតដែលទាក់ទងនឹងអំពើភេទជាមួយអនីតិជនដែលមានអាយុ ចាប់ពី ១៥ឆ្នាំឡើងទៅដោយផ្តល់ឬសន្យាផ្តល់វត្ថុមានតម្លៃអ្វីមួយទៅឲ្យអនីតិជននោះ ឬទៅឲ្យអន្តរការី ឪពុកម្តាយ អ្នកអាណាព្យាបាល ឬជនដទៃទៀតគ្រប់គ្រង ឬត្រួតពិនិត្យ លើ

[47] មាត្រា ៤២ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើ ធ្វើអាជីវកម្មផ្លូវភេទ លេខ នស/រកម/០២០៨/០០៥ ១៨ មករា ឆ្នាំ ២០០៨

អនីតិជននោះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ឆ្នាំទៅ៥ឆ្នាំ។ ជនណាដែលប្រព្រឹត្តបទ ល្មើសខាងលើជាមួយ អនីតិជនដែលមានអាយុតិចជាង ១៥ឆ្នាំ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៧ឆ្នាំទៅ១៥ឆ្នាំ។

ការទិញពេស្យាចារជនដែលមានអាយុចាប់ពី១៨ឆ្នាំឡើងទៅពុំមែនជាបទល្មើសទេ។

**ឧទាហរណ៍:** ការហៅនារីពេស្យាអាយុ ១៩ឆ្នាំ មករួមភេទដោយស្ម័គ្រចិត្តជាថ្នូរនឹងប្រាក់។

ប៉ុន្តែការយកប្រាក់ ឬវត្ថុមានតម្លៃទៅដោះដូរជាមួយនឹងការរួមភេទ ឬអំពើទាក់ទង នឹងភេទផ្សេងទៀត ជាមួយអនីតិជន គឺជាបទល្មើសព្រហ្មទណ្ឌ។

**ឧទាហរណ៍:** បុរសម្នាក់បានហៅនារីពេស្យាអាយុ ១៧ឆ្នាំ ទៅរួមភេទជាមួយនៅសណ្ឋាគារ ដោយឲ្យប្រាក់ចំនួន ១០ដុល្លា។

**៣.១.៤ ការប៉ះពាល់ដល់សេរីភាព** (ការចាប់ ការឃុំឃាំង និងការបង្ខាំងដោយខុសច្បាប់)

ការចាប់ ការឃុំឃាំង និងការបង្ខាំងបុគ្គលផ្សេងទៀត ដោយគ្មានការបញ្ជាពីអាជ្ញាធរស្របច្បាប់ ឬក្រៅពីករណីដែលច្បាប់អនុញ្ញាត[48] គឺជាបទល្មើសព្រហ្មទណ្ឌ។

ជនល្មើសបានចាប់ ជនរងគ្រោះម្នាក់ ឬច្រើននាក់ដោយគ្មានបញ្ជាពីអាជ្ញាធរស្រប ឬដោយគ្មានច្បាប់អនុញ្ញាតទោះបីមានរយៈពេលវែង ឬខ្លីយ៉ាងណាក៏ដោយ។ ជនល្មើសបានឃុំឃាំង ឬបង្ខាំងដោយខុសច្បាប់ នូវជនរងគ្រោះម្នាក់ ឬច្រើននាក់ដោយគ្មានបញ្ជាពីអាជ្ញាធរស្រប ឬដោយគ្មានច្បាប់អនុញ្ញាតទោះបីមានរយៈពេលវែង ឬខ្លីយ៉ាងណាក៏ដោយ។ ទោះបីជាខ្លួនគ្មានសិទ្ធិអំណាចតាមផ្លូវច្បាប់ដើម្បីធ្វើ ឬមិនមានបញ្ជាពីអាជ្ញាធរស្របច្បាប់ ឬក៏មិនមានការអនុញ្ញាតដោយច្បាប់ក៏ដោយ។

តាមមាត្រា២៥៣ នៃក្រមព្រហ្មទណ្ឌ ទោសដែលត្រូវផ្តន្ទាទោសចំពោះបទល្មើសនេះអាស្រ័យទៅតាមរយៈពេលនៃការឃុំឃាំង ឬបង្ខាំងៈ

- បើការចាប់ ការឃុំឃាំង ឬការបង្ខាំងមានរយៈពេលតិចជាង ៤៨ម៉ោង ដាក់ពន្ធនាគារពី ១ឆ្នាំទៅ៣ឆ្នាំ។
- បើការចាប់ ការឃុំឃាំង ឬការបង្ខាំងមានរយៈពេលចាប់ពី ៤៨ម៉ោងដល់តិចជាង១ខែ ដាក់ពន្ធនាគារពី ១ឆ្នាំទៅ៣ឆ្នាំ។
- បើការចាប់ ការឃុំឃាំង ឬការបង្ខាំងមានរយៈពេលស្មើ ឬលើសពីខែ ដាក់ពន្ធនាគារពី ៥ឆ្នាំទៅ១០ឆ្នាំ។

**ឧទាហរណ៍៖** ឈ្មោះ ក បានលួចទ្រព្យសម្បត្តិរបស់អ្នកដទៃ។ បុគ្គលគ្រប់រូបអាចចាប់ខ្លួនឈ្មោះ ក យកទៅប្រគល់ឲ្យមន្ត្រីមានសមត្ថកិច្ចដែលនៅក្បែរនោះភ្លាម។ ការចាប់ខ្លួននេះត្រូវបានអនុញ្ញាតដោយច្បាប់។ ប៉ុន្តែក្នុងករណីដែលជនម្នាក់ចាប់ខ្លួនឈ្មោះ ក វាយខ្នោះហើយទុលឈ្មោះ ក ឲ្យនៅក្នុងផ្ទះរបស់ខ្លួនរយៈពេល ១ថ្ងៃពេញ ជននោះអាចមានទោសក្នុងរឿងព្រហ្មទណ្ឌ។ អំពើនេះមិនត្រូវបានអនុញ្ញាត្តោយច្បាប់ទេ។

## ៣.២ ការប៉ះពាល់សេចក្តីថ្លៃថ្នូរ

### ក. បទប៉ះពាល់ដល់បូរណភាពនៃសាកសព និងប្រមាថទីបញ្ចុះសព

នៅក្រមព្រហ្មទណ្ឌចាត់ទុកអំពើប៉ះពាល់ដល់បូរណភាពនៃសាកសព និងប្រមាថទីបញ្ចុះសពជាបទល្មើស ហើយត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១ខែទៅ១ឆ្នាំ និងពិន័យជាប្រាក់ពី ១សែរៀលទៅ២លានរៀល ។

[48] មាត្រា២៥៣ នៃក្រមព្រហ្មទណ្ឌ លេខ នស/រកម/១១០៩/០២២ ៣០ វិច្ឆិកា ២០០៩

**ឧទាហរណ៍:** ការរំលោភសាកសព ការបំផ្លាញផ្នូរខ្មោច ជាដើម។

**ខ.បទស្រវឹងជាក់ស្តែង**

បុគ្គលណាដែលស្ថិតនៅក្នុងភាពស្រវឹងជាក់ ស្តែងនៅលើផ្លូវសាធារណៈ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ៥០០០រៀលទៅ១០.០០០មុឺនរៀល។ **ឧទាហរណ៍:** បុរសម្នាក់ស្រវឹងដើរទ្រេតទ្រោតនៅលើដងផ្លូវសាធារណៈ។

**គ. បទហៅអ្នកដទៃនៅទីសាធារណៈ**

បុគ្គលណាដែលហៅអ្នកដទៃនៅទីសាធារណៈ ដើម្បីញុំាងឲ្យមានទំនាក់ទំនងផ្លូវភេទត្រូវផ្តន្ទាទោសពិន័យ ជាប្រាក់ពី៥០០០រៀលទៅ៥០.០០០មុឺនរៀល។

**ឧទាហរណ៍:** នារីពេស្យាឈរហៅភ្ញៀវនៅមុខភោជនីយដ្ឋានមួយ ក្នុងគោលបំណង បានរួមភេទ។

## ៣.៣ ការប៉ះពាល់ដល់គ្រួសារ

**ក. បទទ្វេពន្ធភាព**

អំពើដែលចុះបញ្ជីអាពាហ៍ពិពាហ៍ថ្មី មុនការរំលាយអាពាហ៍ពិពាហ៍ចាស់ គឺជាបទទ្វេពន្ធភាព ដែលត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១ខែទៅ១ឆ្នាំ និងពិន័យជាប្រាក់ពី ១សែន ទៅ២លានរៀល។ មន្ត្រីអត្រានុកូលដ្ឋានដែលដឹងហេតុការណ៍នោះច្បាស់ហើយ នៅតែ អនុញ្ញាតឲ្យរៀបអាពាហ៍ពិពាហ៍ ឬចុះបញ្ជីអាពាហ៍ពិពាហ៍ មុនការរំលាយអាពាហ៍ពិពាហ៍ ចាស់ក៏ត្រូវផ្តន្ទាទោសដូចគ្នាដែរ (មាត្រា ៣៥០ នៃក្រមព្រហ្មទណ្ឌ)។

បទទ្វេពន្ធភាពក៏មានចែងនៅក្នុងច្បាប់ស្តីពីឯកពន្ធភាពដែរ។ មាត្រា ៩ នៃច្បាប់ស្តីពី ឯកពន្ធភាពផ្តន្ទាទោសបទទ្វេពន្ធភាព ដាក់ពន្ធនាគារពី ៦ខែទៅ១ឆ្នាំ និងពិន័យជាប្រាក់ពី ២សែនរៀលទៅ១លានរៀល។

**ឧទាហរណ៍:** ឈ្មោះ ក បានរៀបការជាមួយនារីឈ្មោះ ខ ដោយបានចុះសំបុត្រ អាពាហ៍ពិពាហ៍នៅឆ្នាំ ២០០៩ នៅរាជធានីភ្នំពេញ។ លុះនៅឆ្នាំ២០១០ ឈ្មោះ ក បានចុះ សំបុត្រអាពាហ៍ពិពាហ៍ជាមួយនារីឈ្មោះ គ នៅខេត្តស្វាយរៀង ដោយឈ្មោះ ក មិនទាន់ បានលែងលះជាមួយនារីឈ្មោះ ខ នៅឡើយ។ អំពើរបស់ឈ្មោះ ក គឺជាបទទេពន្ធភាព។

**ខ. បទរួមភេទជាមួយអនីតិជនដោយបុព្វញាតិ** (រវាងឪពុកម្តាយ និងកូន) និងបទរួមភេទរវាងញាតិលោហិត(រវាងបងប្អូនបង្កើត)ឬញាតិពន្ធ (រវាងបងប្អូនសាច់ថ្លៃ)

ការរួមភេទជាមួយអនីតិជនអាយុក្រោម ១៨ឆ្នាំ ដោយចារីដែលជាបុព្វញាតិរបស់អនីតិជននោះ ជាបទល្មើសឧក្រិដ្ឋដែលត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ឆ្នាំទៅ១០ឆ្នាំ (មាត្រា ២៥១នៃក្រមព្រហ្មទណ្ឌ)។ **ឧទាហរណ៍:** ឪពុករួមភេទជាមួយនឹងកូនរបស់ខ្លួនបង្កើតដែល មានអាយុ១៧ឆ្នាំ ។

ការរួមភេទជាមួយញាតិលោហិតក្នុងបីថ្នាក់ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១ខែទៅ ១ឆ្នាំ និងពិន័យជាប្រាក់ពី ១សែនទៅ២លានរៀល (មាត្រា ៣៥២ នៃក្រមព្រហ្មទណ្ឌ)។ ការព្រមព្រៀងក្នុងការរួមភេទ មិនមែនជាធាតុផ្សំនៃបទល្មើសនេះទេ មានន័យថាទោះបីជា មានការព្រមព្រៀងរួមភេទក៏បទល្មើសនៅតែមានជានិច្ច។

**ឧទាហរណ៍:**

- ឪពុកមារួមភេទជាមួយនឹងក្មួយស្រីបង្កើតរបស់ខ្លួន (ឪពុកមា និងក្មួយស្រីបង្កើតគឺជា សាខាញាតិថ្នាក់ទី៣)។

- បងប្អូនបង្កើតរួមភេទជាមួយគ្នា (បងប្អូនបង្កើតគឺជាសាខាញាតិថ្នាក់ទី២)។ ការរួមភេទរវាងញាតិពន្ធ(សាច់ថ្លៃ) ក្នុងបីថ្នាក់ ក៏ជាបទល្មើសដែរ ហើយត្រូវផ្តន្ទាទោសដូចគ្នានឹងការរួមភេទរវាងញាតិលោហិតក្នុងបីថ្នាក់ដែរ។

ប៉ុន្តែបើសិនជាសហព័ន្ធណាម្នាក់ស្លាប់ ហើយសហព័ន្ធដែលនៅរស់បានរួមភេទជាមួយសាខាញាតិពន្ធថ្នាក់ទី២ ឬថ្នាក់ទី៣ គឺមិនមានបទល្មើសទេ។

## ៣.៤ បទល្មើសប្រឆាំងនឹងទ្រព្យសម្បត្តិ

### ក. អំពើលួច

ការលួច គឺជាអំពើដកហូតដោយទុច្ចរិតនូវទ្រព្យសម្បត្តិ ឬវត្ថុផ្សេងទៀតរបស់អ្នកដទៃ តាមគ្រប់មធ្យោបាយក្នុងគោលបំណងយកមកធ្វើជាកម្មសិទ្ធិរបស់ខ្លួន។ ការលួចថាមពល ដូចជាការលួចចរន្តអគ្គិសនី ក៏ចាត់ទុកជាបទល្មើសដែរ។ អំពើលួច ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៦ខែទៅ៣ឆ្នាំ និងពិន័យជាប្រាក់ពី ១លានទៅ៦លានរៀល។ **ឧទាហរណ៍:**ចាប់មាន់របស់អ្នកជិតខាងយកទៅចំអិនមកបរិភោគ។ មួយវិញទៀត ការបេះផ្លែស្វាយ របស់អ្នកដទៃ ដោយមិនបានសុំការអនុញ្ញាត។

ការលួចប្រព្រឹត្តឡើងមុនពេល ក្នុងពេល ឬក្រោយពេលប្រើអំពើហិង្សាត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៣ឆ្នាំទៅ១០ឆ្នាំ។ **ឧទាហរណ៍:** ពេលលួចទ្រព្យសម្បត្តិគេបានហើយ ម្ចាស់ទ្រព្យសម្បត្តិមកទាន់ក៏បានប្រើហិង្សាទៅលើម្ចាស់ទ្រព្យ ដើម្បីកុំឲ្យគេដេញតាមខ្លួនជាដើម។

ការកាប់គាស់ទម្លុះទម្លាយ គឺជាអំពើបង្ខំឲ្យខូចខាត ឬបំផ្លិចបំផ្លាញគ្រឿងបិទទ្វារ ឬរបង ទោះបីមានប្រភេទយ៉ាងណាក៏ដោយ។ ត្រូវចាត់ទុកដូចជាការកាប់គាស់ទម្លុះទម្លាយ:

- ការប្រើប្រាស់កូនសោរក្លែង។
- ការប្រើប្រាស់កូនសោរដែលបានមកដោយឧបាយកកលទុច្ចរិត។
- ការប្រើប្រាស់គ្រប់ឧបករណ៍ ដើម្បីធ្វើឲ្យគ្រឿងបិទមានដំណើរការដោយគ្មានការបង្ខំការខូចខាតឬការបំផ្លិចបំផ្លាញ។

ការលួចធ្វើឡើងដោយមានគ្នាច្រើន មិនត្រូវបានក្រមព្រហ្មទណ្ឌចាត់ទុកថាជាស្ថានទម្ងន់ទោសដែលនាំឲ្យមានការផ្តន្ទាទោសធ្ងន់ធ្ងរជាងធម្មតាឡើយ។ ក្រៅពីស្ថានទម្ងន់ទោសខាងលើ អំពើលួចដែលមានស្ថានទម្ងន់ទោសផ្សេងទៀតដែលមានចែងចាប់ពីមាត្រា៣៥៨ ដល់មាត្រា៣៦០ ត្រូវផ្តន្ទាទោសធ្ងន់ធ្ងរជាងអំពើលួចធម្មតាដូចជាអំពើលួចដែលប្រព្រឹត្តមុនពេល ក្នុងពេល ឬក្រោយពេលប្រើហិង្សាដែលបណ្តាលឲ្យជន រងគ្រោះស្លាប់ដោយគ្មានចេតនាសម្លាប់ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១៥ឆ្នាំទៅ៣០ឆ្នាំ។

### ខ. បទកំហែងយក

ការកំហែងយក គឺជាអំពើដែលប្រព្រឹត្តដែលប្រព្រឹត្តដោយប្រើហិង្សា ការគំរាមកំហែងថានឹងប្រើហិង្សា ឬដោយការបង្ខិតបង្ខំដើម្បីទទួលបាននូវៈ

- ហត្ថលេខា ឬស្នាមម្រាមដៃ
- ការសន្យា ឬការបោះបង់ចោលអ្វីមួយ
- ការបង្ហាញអាថ៌កំបាំងណាមួយ
- ការប្រគល់មូលនីធិ តម្លៃ ឬទ្រព្យសម្បត្តិអ្វីមួយ។

ការកំហែងយកត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី២ឆ្នាំទៅ៥ឆ្នាំ និងពិន័យជាប្រាក់ពី៤លានទៅ១០លានរៀល។

ករណីដែលជាការកំហែងយក ដើម្បីទទួលបាននូវការប្រគល់មូលនិធិ តម្លៃ ឬទ្រព្យសម្បត្តិអ្វីមួយ ធាតុផ្សំនៃបទល្មើសប្រហាក់ប្រហែលនិងអំពើលួចដោយប្រើប្រាស់ហិង្សាដែរ។ ប៉ុន្តែបទល្មើសទាំងពីរនេះខុសគ្នាត្រង់ថា ចំពោះបទល្មើសកំហែងយក ជនរងគ្រោះប្រគល់មូលនីធិ តម្លៃ ឬទ្រព្យសម្បត្តិអ្វីមួយដោយស្ម័គ្រចិត្ត ចំណែកឯអំពើលួចវិញ ជនល្មើសបានធ្វើការដកហូតវត្ថុ ឬទ្រព្យសម្បត្តិរបស់ជនរងគ្រោះដោយទុច្ចរិត ដោយមិនឲ្យម្ចាស់ទ្រព្យដឹង។

**គ. បទគំរាមកំហែងហែកកេរ្តិ៍**

ការគំរាមកំហែងហែកកេរ្តិ៍ គឺជាអំពើប្រព្រឹត្តដោយគំរាមកំហែងបើកកកាយ ឬទម្លាក់កំហុសទៅលើអំពើដែលនាំឲ្យប៉ះពាល់ដល់កិត្តិយស ឬការរាប់អានដើម្បីទទួលបាននូវ៖

- ហត្ថលេខា ឬស្នាមម្រាមដៃ
- ការសន្យា ឬការបោះបង់ចោលអ្វីមួយ
- ការបង្ហាញអាថ៌កំបាំងណាមួយ
- ការប្រគល់មូលនីធិ តម្លៃ ឬទ្រព្យសម្បត្តិអ្វីមួយ។

បទល្មើសនេះត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ឆ្នាំទៅ៥ឆ្នាំ និងពិន័យជាប្រាក់ពី ៤លានទៅ១០លានរៀល។ បទល្មើសនេះមានលក្ខណៈប្រហាក់ប្រហែលដែលជនល្មើសកំហែងយកដែរខុសគ្នាត្រង់មធ្យោបាយនៃការគំរាមកំហែងដែលជនល្មើសប្រើប្រាស់ គឺការគំរាមកំហែងបើកកកាយ ឬទម្លាក់កំហុសទៅលើអំពើដែលនាំឲ្យប៉ះពាល់ដល់កិត្តិយស ឬការរាប់អាន ចំណែកឯការកំហែងយក គឺជាជនល្មើសប្រើហិង្សា ឬគំរាមកំហែងនឹងហិង្សា ឬបង្ខិតបង្ខំ។

**ឃ.បទឆបោក**

ការឆបោក គឺជាអំពើបន្លំចំពោះរូបវន្តបុគ្គល ឬនីតិបុគ្គលណាមួយដោយប្រើឈ្មោះក្លែង ដោយអះអាងទៅលើឋានៈក្លែង ដោយរំលោភលើឋានៈពិតប្រាកដ ឬដោយប្រើឧបាយកលទុច្ចរិត ហើយដូច្នេះបានទទួលពីបុគ្គលនេះ ដែលនាំឲ្យខូចប្រយោជន៍របស់បុគ្គលនេះឬរបស់តតិយជននូវៈ

- ការប្រគល់មូលនិធិ តម្លៃ ឬទ្រព្យសម្បត្តិអ្វីមួយ
- ការផ្តត់ផ្គង់សេវា
- ការធ្វើលិខិតដែលមានតម្លៃជាកាតព្វកិច្ច ឬជាការឲ្យរួចពីកាតព្វកិច្ច។

អំពើឆបោកត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៦ខែទៅ៣ឆ្នាំ និងពិន័យជាប្រាក់ពី ១លានទៅ៦លានរៀល (មាត្រា ៣៧៨ នៃក្រមព្រហ្មទណ្ឌ)។ ក្នុងករណីមានស្ថានទម្ងន់ទោសដូចមានចែងចាប់ពីមាត្រា ៣៧៩ដល់មាត្រា ៣៨០នឹងត្រូវផ្តន្ទនាទោសដាក់ពន្ធនាគារពី២ឆ្នាំទៅ៥ឆ្នាំ។

**ឧទាហរណ៍៖** ឈ្មោះ ក បានក្លែងថាខ្លួនជាប្រធានក្រុមហ៊ុនមួយដែលអាចជួយរត់ការឲ្យពលករអាចទៅធ្វើការនៅប្រទេសកូរ៉េបាន។ ឃើញដូច្នេះឈ្មោះ ខ ដែលមានបំណងទៅធ្វើការនៅប្រទេសកូរ៉េ បានប្រគល់ប្រាក់ចំនួន ១០០០ដុល្លាឲ្យទៅឈ្មោះកដើម្បីបំពេញការងារ។

**ខ. ការរំលោភលើទំនុកចិត្ត**

អំពើរំលោភលើទំនុកចិត្ត គឺជាអំពើគេបំបាត់មូលនិធិ តម្លៃ ឬ ទ្រព្យសម្បត្តិអ្វីមួយនាំ ឲ្យខូចប្រយោជន៍អ្នកដទៃ ប្រព្រឹត្តដោយបុគ្គលណាម្នាក់ដែលគេបានប្រគល់ឲ្យបុគ្គលនោះ ហើយបុគ្គលនោះបានយល់ព្រម ដោយមានភារកិច្ចប្រគល់សងវិញ បង្ហាញ ឬយកមូលនិធិ តម្លៃ ឬទ្រព្យសម្បត្តិនោះ ទៅធ្វើការប្រើប្រាស់ជាកំណត់ (មាត្រា ៣៩១ នៃក្រមព្រហ្មទណ្ឌ)។

អំពើរំលោភលើទំនុកចិត្តត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៦ខែទៅ៣ឆ្នាំ និងពិន័យជា ប្រាក់ពី ១លានទៅ៦លានរៀល (មាត្រា ៣៩២ នៃក្រមព្រហ្មទណ្ឌ)។ ក្នុងករណីមានស្ថានទម្ងន់ទោសដូចមានចែងចាប់ពី

មាត្រា ៣៩៣ដល់មាត្រា ៣៩៤ ការផ្តន្ទាទោសនឹងកើនរហូត ដល់ការដាក់ទោសពន្ធនាគារចាប់ពី ២ឆ្នាំទៅ៥ឆ្នាំ។

**ឧទាហរណ៍៖** ឈ្មោះ ក បានខ្ចីម៉ូតូរបស់មិត្តភក្តិឈ្មោះ ខ ។ ឈ្មោះ ក បានយកម៉ូតូ នេះទៅបញ្ចាំ នៅកុងស៊ីយកប្រាក់មកចាយវាយអស់។ ឈ្មោះ ក បានប្រព្រឹត្តបទ រំលោភ លើទំនុកចិត្ត ។

**ច. បទទទួលផលចោរកម្ម**

អំពើទទួលផលចោរកម្ម គឺជាអំពើទទួល លាក់បំបាំង រក្សាទុក ឬបញ្ជូនវត្ថុអ្វីមួយ ដោយដឹងថាវត្ថុនោះបានមកពីបទឧក្រិដ្ឋ ឬបទមជ្ឈិម។ ត្រូវចាត់ទុកជាអំពើទទួលផលចោរ កម្មផងដែរ៖

- អំពើធ្វើជាអន្តរការីដើម្បីបញ្ជូនវត្ថុអ្វីមួយ ដោយដឹងថារបស់នោះបានមកពីបទឧក្រិដ្ឋ ឬបទមជ្ឈិម។
- អំពើដែលបានទទួលផលពីផលនៃបទឧក្រិដ្ឋ ឬបទមជ្ឈឹមដោយបានដឹងហេតុការណ៍ច្បាស់។

បទល្មើសនេះត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ឆ្នាំទៅ៥ឆ្នាំ និងពិន័យជាប្រាក់ពី៤ លានទៅ១០លានរៀល (មាត្រា ៤០០ នៃក្រមព្រហ្មទណ្ឌ)។

**ឧទាហរណ៍៖**

- ទទួលទិញរថយន្តដែលដឹងថារថយន្តនេះបានមកពីការលួច។
- យករថយន្តដែលបានមកពីការលួច មកលាក់បំបាំងនៅក្នុងផ្ទះរបស់ខ្លួន។
- អំពើរបស់ប្រពន្ធចាយវាយទ្រព្យសម្បត្តិដែលប្តីខ្លួនបានដៃបន្លំពីក្រុមហ៊ុនដោយដឹង ច្បាស់ពីអំពើរបស់ប្តី។

ក្នុងករណីមានស្ថានទម្ងន់ទោសដូចមានចែងក្នុងមាត្រា ៤០១ នៃក្រមព្រហ្មទណ្ឌ ទោសដែលត្រូវផ្តន្ទាគឺដាក់ពន្ធនាគារពី ៥ឆ្នាំទៅ១០ឆ្នាំៈ

- បទល្មើសបានប្រព្រឹត្តឡើងជាទម្លាប់
- បទល្មើសបានប្រព្រឹត្តឡើងដោយប្រើប្រាស់ភាពងាយស្រួលដែលការប្រកប សកម្មភាពវិជ្ជាជីវៈផ្តល់ឲ្យ។

**ឧទាហរណ៍:** អ្នកលក់រថយន្តចាស់ៗបានទិញរថយន្តពីចោរ។

- ជាក្រុមមានការចាត់តាំង (តាមមាត្រា ៧៧ នៃក្រមព្រហ្មទណ្ឌ ក្រុមមានការ ចាត់តាំង គឺជាក្រុមប្រមូលផ្តុំដែលបានបង្កើតឡើង ឬជាសន្ធិដ្ឋិភាព(ការព្រមព្រៀង) ដែល បានធ្វើឡើងដើម្បីត្រៀមរៀបចំ ឬប្រព្រឹត្តបទល្មើសមួយ ឬច្រើន) ។

**ឆ. បទបន្លំ**

បទបន្លំ គឺជាបទល្មើសប្រភេទថ្មីមួយទៀតដែលទើបតែមានចែងនៅក្នុងក្រមព្រហ្មទណ្ឌ។ មាត្រា ៣៨៤ ចាត់ទុកបទបន្លំ គឺជាអំពើរបស់បុគ្គលដែលដឹងខ្លួនថាគ្មានលទ្ធភាព ដាច់ខាតនឹងបង់ថ្លៃ ឬដែលសម្រេចចិត្តមិនបង់ថ្លៃ:

- ឲ្យគេបម្រើម្ហូបអាហារ ឬភេសជ្ជៈនៅក្នុងរង្គសាល ភោជនីយដ្ឋាន ឬនៅក្នុងគ្រឹះស្ថាន ដទៃទៀត ដែលបើកចំហរដល់សាធារណៈជន។

- ឲ្យគេប្រគល់បន្ទប់មួយ និងកាន់កាប់បន្ទប់នេះនីក្នុងសណ្ឋាគារ ឬគ្រឹះស្ថានដទៃ ទៀត ដែលបើកចំហរដល់សាធារណៈជន។

- ឲ្យគេដឹកជញ្ជូនខ្លួនតាមត្រីចក្រយាន តាមរថយន្តឈ្នួល ឬតាមមធ្យោបាយដឹក ជញ្ជូន ផ្សេងទៀត។

អំពើបន្លំត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៦ថ្ងៃទៅ៣ខែ និងពិន័យជាប្រាក់ពី ១សែន ទៅ ៥សែនរៀល។

**ឧទាហរណ៍:**

- ជនម្នាក់ពុំមានប្រាក់សម្រាប់ជួលផ្ទះសំណាក់ដើម្បីស្នាក់នៅទេ តែគាត់បែរជាទៅ ជួលបន្ទប់ផ្ទះសំណាក់ ហើយស្នាក់នៅមួយយប់។
- ជនម្នាក់ឡើងជិះរថយន្តក្រុងដោយមិនទិញសំបុត្រ។

**ជ. បទធ្វើឲ្យខូចខាតដោយចេតនា**

អំពើប្រព្រឹត្តដោយចេតនា ដោយបំផ្លិចបំផ្លាញ ធ្វើឲ្យទ្រុឌទ្រោម ឬធ្វើឲ្យខូចខាតទ្រព្យសម្បត្តិរបស់អ្នកដទៃនោះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៦ខែទៅ២ឆ្នាំ និងពិន័យជាប្រាក់ពី ១លានទៅ៤លានរៀល លើកលែងតែការខូចខាតមានលក្ខណៈស្រាល ។ ករណីដែលការខូចខាចមានលក្ខណៈស្រាលការផ្តន្ទាទោសត្រូវបន្ថយមកជាការដាក់ពន្ធនាគារពី ១ថ្ងៃទៅ៦ថ្ងៃ និងពិន័យជាប្រាក់ពី ១០០០រៀលទៅ១០០០០ម៉ឺន
រៀល។

**ឧទាហរណ៍:**

- យកកូនសោរទៅឆ្កូតរថយន្តរបស់អ្នកដទៃដែលចតចោលនៅមុខផ្ទះរបស់ខ្លួន។
- ដោយសារតែខឹងនឹងអ្នកលក់យកអាហារមកឲ្យខ្លួនមានការយឺតយ៉ាវ បុរសម្នាក់បានបោកកែវដែលបានដាក់នៅលើតុបានបែកខ្ទេច។

ក្រមព្រហ្មទណ្ឌមិនត្រឹមតែធ្វើការផ្តន្ទាទោស ចំពោះបទធ្វើឲ្យខូចខាចដោយចេតនាតែប៉ុណ្ណោះទេ ថែមទាំងចាត់ទុកជាបទល្មើសចំពោះការធ្វើឲ្យខូចខាតដោយអចេតនាទៀតផង។ មាត្រា៤១៩ នៃក្រមព្រហ្មទណ្ឌចែងថា: អំពើបំផ្លិចបំផ្លាញ ធ្វើឲ្យទ្រុឌទ្រោម ឬធ្វើឲ្យខូចខាតទ្រព្យសម្បត្តិដែលជាកម្មសិទ្ធិរបស់អ្នកដទៃ ដោយអានុភាពនៃគ្រឿងផ្ទុះ ឬអគ្គិភ័យ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ខែទៅ១ឆ្នាំ និងពិន័យជាប្រាក់ពី ១សែទៅ២លានរៀល កាលបើអំពើនេះបណ្តាលមកពីការធ្វេសប្រហែស ការមិនប្រុងប្រយ័ត្នដែលច្បាប់តម្រូវ។

**ឧទាហរណ៍:** ដោយសារតែការធ្វេសប្រហែស ចិន្តា មិនបានពន្លត់ភ្លើងចង្ក្រានរបស់ខ្លួន ក្រោយពីបានដាំស្លរួចហើយក៏បណ្តាលឲ្យ ឆេះឆាបរាលដាលដល់ផ្ទះរបស់នាង និងផ្ទះរបស់អ្នកជិតខាង។ អំពើរបស់ចិន្តា គឺជាការធ្វើឲ្យខូចខាតដល់ផ្ទះរបស់អ្នកដទៃដោយអានុភាពនៃអគ្គិភ័យដោយសារតែការធ្វេសប្រហែសរបស់នាង។

## ៣.៥ ការប៉ះពាល់ដល់សន្តិសុខសាធារណៈ

### ក. ក្រុមជនប្រដាប់អាវុធ

ក្រុមជនប្រដាប់ គឺជាក្រុមបុគ្គលមានកាន់កាប់អាវុធដែលមានការចាត់តាំងជាលំដាប់ថ្នាក់ និងដែលអាចនាំអោយច្របូកច្របល់ដល់សណ្តាប់ធ្នាប់សាធារណៈ។ ការចូលរួមក្នុងក្រុមជនប្រដាប់អាវុធ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ឆ្នាំទៅ៣ឆ្នាំ និងពិន័យជាប្រាក់ពី២លានទៅ៦លានរៀល (មាត្រា ៤៨៥ នៃក្រមព្រហ្មទណ្ឌ)។ ចំពោះការរៀបចំចាត់តាំងជនប្រដាប់អាវុធវិញ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ឆ្នាំទៅ៥ឆ្នាំ និងពិន័យជាប្រាក់ពី ៤លានទៅ១០លានរៀល។

បទល្មើសក្រុមជនប្រដាប់អាវុធ ខុសប្លែកពីបទល្មើស ការបង្កើតដោយខុសច្បាប់នូវកម្លាំងប្រដាប់អាវុធ ដែលមានចែងនៅមាត្រា ៤៦៣ នៃក្រមព្រហ្មទណ្ឌ ហើយត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១៥ឆ្នាំទៅ៣០ឆ្នាំ។

ក្រុមជនប្រដាប់អាវុធមានចែងនៅមាត្រា ៤៨៤ នៃក្រមព្រហ្មទណ្ឌស្ថិតនៅក្នុងជំពូក៣ ស្តីពីការប៉ះពាល់ដល់សន្តិសុខសាធារណៈ។ ចំណែកឯបទបង្កើតដោយខុសច្បាប់នូវកម្លាំងប្រដាប់អាវុធវិញមានចែងនៅមាត្រា ៤៦៣ ស្ថិតនៅក្នុងជំពូក២ នៃក្រមស្តីពីការប៉ះពាល់ដល់សន្តិសុខរដ្ឋ។ ហេតុនេះ បទបង្កើតដោយខុសច្បាប់នូវកម្លាំងប្រដាប់អាវុធ ជាបទល្មើសដែលមានលក្ខណៈធ្ងន់ធ្ងរជាង បទចូលរួមក្នុងក្រុមជនប្រដាប់អាវុធ ដោយហេតុថា ការបង្កើតដោយខុសច្បាប់នូវកម្លាំងប្រដាប់អាវុធមានគោលបំណងធ្វើអោយប៉ះពាល់ដល់សន្តិសុខនៃរដ្ឋតែម្តង។

### ខ. បទល្មើសក្នុងវិស័យអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវ

ក្រមព្រហ្មទណ្ឌចាត់ទុកជាបទល្មើសនូវការផលិត ការនាំចូល ការនាំចេញ និងការសន្និធិ (ការស្តុកទុក) អាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទដោយគ្មានការអនុញ្ញាតពីអាជ្ញាធរមានសមត្ថកិច្ច។ បទល្មើសនេះត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ឆ្នាំទៅ១០ឆ្នាំ (មាត្រា ៤៨៨ នៃក្រមព្រហ្មទណ្ឌ) ។ មាត្រា ៤៨៨ នៃក្រមព្រហ្មទណ្ឌ សំដៅទៅលើអាវុធ គ្រឿងផ្ទុះ និងគ្រាប់ រំសេវ ដូចជាកាំភ្លើង ជាដើម ចំណែកឯ មាត្រា ៤៨៩ នៃក្រមព្រហ្មទណ្ឌ សំដៅទៅលើអាវុធ សម្រាប់ប្រហារផ្សេងទៀតដូចជា ចំពុះទុង ដាវ ស្នាប់ដៃ ជា
អាទិ៍។ ការផលិត ការនាំចូល ការនាំចេញ និងសន្និធិអាវុធសម្រាប់ប្រហារផ្សេងទៀតនេះក៏ជាបទល្មើសដែរ កាលបើពុំមានការ អនុញ្ញាតពីអាជ្ញាធរមានសមត្ថកិច្ចហើយត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី២ឆ្នាំទៅ៥ឆ្នាំ និងពិន័យជាប្រាក់ពី ៤លានរៀលទៅ១០លានរៀល។

### គ បទចូលរួមសមាគមជនទុច្ចរិត

ជាគោលការណ៍ច្បាប់ ការផ្តន្ទាទោសព្រហ្មទណ្ឌអាចធ្វើទៅបានលុះត្រាតែជនល្មើសបានចាប់ផ្តើមអនុវត្តបទល្មើសរបស់ខ្លួនហើយមិនបានបញ្ឈប់សកម្មភាពល្មើសរបស់ខ្លួនទៅវិញដោយស្ម័គ្រចិត្តនៅមុខការសម្រេចបទល្មើស ។ ប៉ុន្តែដោយសារតែការចូលរួមក្នុងសមាគមជនទុច្ចរិតមានចរិតគ្រោះថ្នាក់ធ្ងន់ធ្ងរដល់សង្គមជាតិជាពិសេសសន្តិសុខសាធារណៈក្រមព្រហ្មទណ្ឌបានបង្កើតអោយមានជាបទល្មើសមួយដាច់ដោយឡែកសម្រាប់ការចូលរួមសមាគមនៃជនទុច្ចរិតដែលសមាគម(ក្រុម ឬសន្និដ្ឋភាព)នេះត្រូវបានបង្កើតឡើងដើម្បីប្រព្រឹត្តបទ

ឧក្រិដ្ឋមួយចំនួនប្រឆាំងនិងបុគ្គល និងប្រឆាំងនឹងទ្រព្យសម្បត្តិ ។ ការបង្កើតអោយមានបទល្មើសនេះ គឺមានសារៈសំខាន់សម្រាប់ការប្រយុទ្ធប្រឆាំងនឹងបទល្មើស ជាពិសេសនៅមុនពេលដែលបទឧក្រិដ្ឋដែលបានគ្រោងទុកដោយក្រុមជនទុច្ចរិតនេះត្រូវបានប្រព្រឹត្ត ឬចាប់ផ្តើមអនុវត្ត។ទន្ទឹម នឹងនេះដោយសារការលំបាកក្នុងការស្វែងរកបទល្មើស និងដើម្បីប្រសិទ្ធភាពនៃការបង្ក្រាបនៅមុនពេលដែលបទឧក្រិដ្ឋដែលបានគ្រោងទុកដោយក្រុមនៃជនទុច្ចរិតត្រូវបានប្រព្រឹត្ត ឬចាប់ផ្តើមអនុវត្តក្រមព្រហ្មទណ្ឌក៏បានចែងកំណត់ផងដែរអំពីការលើកទឹកចិត្ត និងការពារផ្លូវច្បាប់ចំពោះបុគ្គលដែលមានការភ្ញាក់រលឹក ហើយបានសហការជាមួយអាជ្ញាធរមានសមត្ថកិច្ច ដើម្បីឈានទៅបង្ក្រាបសមាជិកនៃក្រុមជនទុច្ចរិតផ្សេងទៀត។

# សេចក្តីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

ក្រោយពីការស្រាវជ្រាវនៅប្រធានបទ បទល្មើសព្រហ្មទណ្ឌ មកបានបង្ហាញអោយឃើញថា ដើម្បីកំណត់នូវបទល្មើសណាមួយបាន គឺលុះត្រាតែមានធាតុផ្សំគ្រប់គ្រាន់ នោះទើបអាចចាត់ទុកេជាបទល្មើសមួយបាន។ ហើយធាតុផ្សំនៃបទល្មើសដូចជាៈ **(១) ធាតុនីត្យានុកូល (២)ធាតុសត្យានុម័ត និង (៣) ធាតុអត្តនោម័ត។** ផ្ទុយទៅវិញប្រសិនបើពុំមានធាតុផ្សំគ្រប់គ្រាន់នោះទេ នោះគេពុំអាចចាត់ទុកថាជាបទល្មើសមួយបាន ( ក្នុងចំណោមធាតុផ្សំនៃបទល្មើសព្រហ្មទណ្ឌទាំងបីខាងលើ ប្រសិនបើខ្វះនូវធាតុផ្សំណាមួយនោះ គឺពុំអាចចាត់ទុកថាជាបទល្មើសមួយបានទេ)។ មួយវិញទៀតសោតទាក់ទងនឹងធាតុផ្សំនៃបទល្មើសក៏មានសារៈសំខាន់ណាស់ដែរ។ ការបែងចែកនូវចំណាត់ថ្នាក់នៃបទល្មើសមានដូចជាៈ **(១)បទឧក្រិដ្ឋ (២)បទមជ្ឈិម និង(៣)បទលហុ។** ក្នុងនេះប្រសិនបើគេពុំបានបែងចែកនូវចំណាត់ថ្នាក់នៃបទល្មើសនោះទេ គឺវាមានលក្ខណៈស្មុគស្មាញខ្លាំងក្នុងការចោទប្រកាន់បទល្មើសេ ពីព្រោះបទល្មើសខ្លះមានស្ថានទម្ងន់ទោសស្រាល និងបទល្មើសខ្លះទៀតក៏មានស្ថានទម្ងន់ទោសធ្ងន់ធ្ងរ។ មួយវិញទៀត ការប្រព្រឹត្តបទល្មើសមាន៤ដំណាក់កាល មានដូចជា ដំណាក់កាលនៃការគិត ដំណាក់កាលនៃការត្រៀមរៀបចំ ដំណាក់កាលនៃការប្រព្រឹត្ត។ គ្រប់បទល្មើសអាចមានសភាពធ្ងន់រឺស្រាល អាស្រ័យទៅលើការប្រព្រឹត្តនៃចារី។

ជាចុងបញ្ចប់ គឺចង់បង្ហាញថា បទល្មើសព្រហ្មទណ្ឌ ពិតជាមានសារៈសំខាន់ណាស់ ជាពិសេសនោះអាចធានា ដែលអាចជួយសម្រួលសុខសុវត្ថិភាពនឹងស្ថេរភាពនយោបាយដល់សង្គមទាំងមូល។

# អនុសាសន៍

# អនុសាសន៍

បន្ទាប់ពីបានឆ្លងកាត់ការសិក្សាស្រាវជ្រាវទៅលើប្រធានបទ បទល្មើសព្រហ្មទណ្ឌ រួចមកយើងសង្កេតឃើញថា ដើម្បីឲ្យការអនុវត្តបទល្មើសមួយបានត្រឹមត្រូវ ចាំបាច់ណាស់ត្រូវតែអនុវត្តទៅតាមនីតិវិធីដែលបានកំណត់នៅក្នុងខ្លឹមសារច្បាប់។ នៅពេលដែលមានបទល្មើសមួយបានកើតឡើង ជនដែលប្រព្រឹត្តបទល្មើសត្រូវតែទទួលខុសត្រូវចំពោះអំពើរបស់ខ្លួន ទោះស្ថិតនៅក្នុងឋានជាចារី ជាសហចារីជាអ្នកផ្ដើមគំនិត ឬ ជាអ្នកសមគំនិតក្ដី។ កាលបើមានធាតុផ្សំទាំងបី ក្នុននោះរួមមាន ធាតុផ្សំនីត្យានុកូល(ធាតុច្បាប់) ធាតុផ្សំសត្យានុម័ត(ធាតុផ្សំសម្ភារៈ) និងធាតុផ្សំអត្តនោម័ត(ធាតុចេតនាប្រព្រឹត្ត) ហើយជនដែលបានប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌត្រូវតែទទួលខុសត្រូវចំពោះអំពើរបស់ខ្លួន។

ជាការពិតណាស់ច្បាប់បានចែងយ៉ាងលំអិតអំពីបទល្មើសព្រហ្មទណ្ឌ និងទោសទៅលើជនបានប្រព្រឹត្តបទល្មើស ដើម្បីជានាកុំឲ្យខូចសណ្ដាប់ធ្នាប់របៀបរៀបរយសាធារណៈ ឬ អំពើប្រឆាំង និងមនុស្សអំពើដែលប៉ះពាល់ នៃបូរណភាពនៃបុគ្គលប៉ះពាល់ដល់សេចក្ដីថ្លៃថ្នូរ សេរីភាព ឬ សិទ្ធិរបស់មនុស្សអំពើបំផ្លាញទ្រព្យសម្បត្តិអ្នកដទៃ លួច ឆក់ ប្លន់ជាដើម។ បើទោះបីជាច្បាប់បានចែងយ៉ាងលំអិតយ៉ាងណាក៏ដោយ អ្វីដែលសំខាន់ គឺការអនុវត្តផ្ទាល់ដើម្បីធានាបានថាជនដែលបានប្រព្រឹត្ត គឺត្រូវទទួលទោសទៅតាមទំហំនៃអំពើខ្លួន។ ម៉្យាងវិញទៀតការប្រតិបត្តិរបស់ភ្នាក់ងារអនុវត្តច្បាប់ ព្រះរាជអាជ្ញា និងតុលាការ ត្រូវតែធ្វើការពិនិត្យវិនិច្ឆ័យឲ្យបានត្រឹមត្រូវចំពោះការគោរពតាមច្បាប់ជាតិ និងបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ។ ដើម្បីធានាឲ្យការអនុវត្តច្បាប់របស់មន្ត្រីមានសមត្ថកិច្ចកាន់តែមានប្រសិទ្ធភាពនោះ គឺត្រូវតែះ

- ចៅក្រមត្រូវតែរក្សាភាពមិនលំអៀង និងចៀសវាងការវិនិច្ឆ័យរឿងក្ដីមុនសេចក្ដីសម្រេច។
- ពង្រឹងការអនុវត្តនីតិវិធីនៅគ្រប់ដំណាក់កាល និងធានាការជំនុំជម្រះក្ដីដោយយុត្តិធម៌ដែលធ្វើឡើងដោយតុលាការមានសមត្ថកិច្ចឯករាជ្យ និងឥតលំអៀង។
- ពង្រឹងសមត្ថភាពរបស់មន្ត្រីនគរបាលយុត្តិធម៌ក្នុងការអនុវត្តតួនាទី និងភារកិច្ចរបស់ខ្លួនឲ្យបានត្រឹមត្រូវតាមច្បាប់កំណត់ ជាពិសេសចំពោះការឃាត់ខ្លួន ចាប់ខ្លួន ឃុំខ្លួន និងសួរចម្លើយ។
- មន្ត្រីសាធារណៈ (រួមមានមន្ត្រីនគរបាលយុត្តិធម៌ និងព្រះរាជអាជ្ញា) ត្រូវធ្វើសេចក្ដីថ្លែងការណ៍ទាក់ទងនឹងភាពមានឬ គ្មានពិរុទ្ធរបស់ជនជាប់ចោទណាម្នាក់ មុនពេលបើកកិច្ចជំនុំជម្រះក្ដីត្រូវបានបញ្ចប់ជាស្ថាពរ។
- ពង្រឹងផ្សព្វផ្សាយច្បាប់ទៅឲ្យពលរដ្ឋ លើកកម្ពស់ការអានសៀវភៅ និងការចូលរួមនៅក្នុងកិច្ចការសង្គម។
- ពង្រឹងវិស័យអប់រំ កាត់បន្ថយអត្រាបោះបង់ចោលការសិក្សា និងលើកទឹកចិត្តអោយឪពុកម្ដាយបញ្ជូនកូនៗទៅសិក្សាអោយបានគ្រប់ៗគ្នា។

ជារួមមកយើងមិនចង់ឃើញប្រទេសដែលមានច្បាប់ល្អ ហើយពលរដ្ឋប្រព្រឹត្តអំពើល្មើសនោះទេ ការយល់ដឹងរបស់ប្រជាពលរដ្ឋពិតជាមានសារៈសំខាន់ណាស់ក្នុងការចូលរួមអភិវឌ្ឍប្រទេសជាតិដោយមានការរីកចម្រើន។

# ឯកសារយោង

❖ **លិខិតបទដ្ឋានគតិយុត្តនានា**

•ក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី៣០ វិច្ឆកា ឆ្នាំ២០០៩។

•ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ១០ សីហា ឆ្នាំ២០០៧។

•ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០៨ ធ្នូ ឆ្នាំ២០០៧។

•ច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរ នឹងអំពើធ្វើអាជីវកម្ម ចុះថ្ងៃទី១៨ មករា ឆ្នាំ២០០៨។

❖ **ឯកសារចងក្រងជាសៀវភៅ និងឯកសារសិក្សាផ្សេងៗទៀត**

•សៀវភៅសាស្ត្រាចារ្យ ហ៊ាង ឡេង នីតិព្រហ្មទណ្ឌទូទៅ ឆ្នាំ២០១០

•សៀវភៅសាស្ត្រាចារ្យ សេង ស៊ីវិត្ថា នីតិព្រហ្មទណ្ឌខ្មែរ ឆ្នាំ២០១៣

•សៀវភៅសាស្ត្រាចារ្យ រុន ពណ្ណរិទ្ធ នីតិព្រហ្មទណ្ឌ និងនីតិគ្រួសារ ឆ្នាំ២០១៧

# ឧបសម្ព័ន្ធ